Free

សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា

KhmerPost USA

E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

មាតិការឿង

Issue 196 from .March 4th - 17th, 2016

១-កម្មវិធីប្រកួតគំនិតអាជីវកម្មសម្រាប់សហគមន៍ខ្មែរ.....០៣
២-ផ្ទុះបាតុកម្មនៅសហគមន៍ចិនអាមេរិក..................០៦
៣-ទស្សនាប្រជុំកោះការ៉ាអ៊ីប..............................០៩
៤-សប្ដាហ៍សម្រាប់ក្មេងឡូវែល..............................១១
៥-បន្តផលិតខ្សែភាពយន្តរឿង "ដំបូងគេសលាប់ឪពុក"......១២
៦-បូស្តុនត្រូវបានជាប់ជាទីក្រុងដ៏បំផុតលេខ២...............២០
៧-ភូមាកំពុងស្វែងរកប្រធានាធិបតី..........................២១
៨-ម្ហូបត្រកួនត្រីពង..............................................២៨

Office: Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852

# ស៊ូពើធូស្ដេយ៍ អ្នកឈ្នះគឺ ហ៊ីឡារី គ្លីងតុន នឹង ឌណាល់ ត្រុម

## The winners of "Super Tuesday": Hillary Clinton and Donald Trump







**ដោយ ពិន សំខុន**

ថ្ងៃអង្គារទី១មិនានេះ ជាថ្ងៃបោះឆ្នោតក្នុងគណបក្ស ដើម្បីជ្រើសយកបេក្ខជនម្នាក់ក្នុងបក្សនិមួយៗដែលបានសន្លឹកឆ្នោតគាំទ្រខ្ពស់ជាងគេឱ្យមកប្រកួតអ្នកឈ្នះទល់នឹងអ្នកឈ្នះដូចគ្នាដែលចេញពីគណបក្សខុសគ្នានៅចុងឆ្នាំ២០១៦នេះ។

ស៊ូពើធូស្ដេយ៍ជាការបោះឆ្នោតបឋមសម្រាប់ជ្រើសរើសប្រធានាធិបតីនៃសហរដ្ឋអាមេរិក។ ការបោះឆ្នោតនេះ ប្រព្រឹត្តទៅក្នុង១ថ្ងៃ ឬច្រើនថ្ងៃទៅតាមចំនួនរដ្ឋច្រើនឬតិច ។ ថ្ងៃទី១មិនានេះ មានរដ្ឋចំនួន១០បានចូលរួម ហើយនៅសល់៣៥ទៀត ដែលមិនទាន់ដល់ពេលបោះឆ្នោតនៅឡើយ។

គេដឹងថាខាងគណបក្សសាធារណរដ្ឋមានបេក្ខជនឈរឈ្មោះ១៣នាក់ បានចេញធ្វើការឃោសនាក្នុងរយពេល៦ខែចុងក្រោយ ដើម្បីឱ្យប្រជាពលរដ្ឋវិនិច្ឆ័យថាតើនរណាខ្លះដែលមានលទ្ធភាពនឹងក្លាយជាប្រធានាធិបតីបាននោះ បានត្រូវជម្រុះជាបន្តបន្ទាប់ នៅសល់តែប្រមាណ៥នាក់ដែលនៅតស៊ូបន្តរនៅឡើយ។

ខាងគណបក្សប្រជាធិបតេយ្យវិញ មានបេក្ខជន៤នាក់ ឥឡូវនេះនៅសល់តែ២នាក់ប្រកួតគ្នាក្នុងបក្សគឺ ហ៊ីឡារី នឹង សាំនឌឺ។

លទ្ធផលសម្រាប់ "ស៊ូពើធូស្ដេយ៍" ក្នុងចំណោម១០រដ្ឋដែលបោះឆ្នោតរួចហើយ (គិតជាតំណាង)

**គណបក្សប្រជាធិបតេយ្យ:**

**១-គ្លីងតុន** បាន ៨៨៣ តំណាង
**២-សាំនឌឺ** បាន ២៣២

**ខាងគណបក្សសាធារណរដ្ឋ**

**១-ត្រុម** បាន ២២១ តំណាង
**២-គ្រូស៍** បាន ៦៩

**តទៅទំព័រទី ០៩**

## វិចារណកថា

### បើ សម រង្ស៊ី អាចឃាត់បាតុករបានអាចនឹងធ្វើដូចគ្នានឹង ហ៊ុន សែន



ពិន សំខុន

**ដោយ ពិន សំខុន**

●●●ជ័យលាភីរង្វាន់ណូបែលប្រឆាំងនឹងរបប "តាលិបាន" ម្នាក់ឈ្មោះ "ម៉ាឡាឡា" និយាយថា "រស់នៅមានសេរីភាពតែ១ថ្ងៃក៏ប្រសើជារស់នៅជាទាសករ១០០ឆ្នាំដែរ" ពាក្យនេះធ្វើឱ្យខ្ញុំនឹកទៅដល់ សម រង្ស៊ី ដែលបានចេញបញ្ជាឱ្យបាតុករគណបក្សសង្គ្រោះជាតិកុំចេញទៅធ្វើបាតុកម្មប្រឆាំងនឹង ហ៊ុន សែន នៅកាលីហ្វ័រញ៉ាខាងត្បូង កាលពីថ្ងៃទី១៦កុម្ភៈមុន តែបាតុកម្មនៅតែកើតឡើងដដែលរួមមានទាំងសមាជិកគណបក្សនឹងមិនមែនគណបក្សផង។

បាតុករមិនបានស្ដាប់បញ្ជា សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិទេ បាតុករប្រមាណជិត២ពាន់នាក់ បានមកជូនពរមេដឹកនាំដឹកនាំផ្ដាច់ការនៅប្រទេសអាស៊ាន៧ប្រទេសមានទាំងកម្ពុជាផង "ឱ្យបានឆាប់ធ្លាក់ពីដំណែង" មិនខ្វល់នឹងការសងសឹករបស់មេដឹកនាំទាំងនោះទៅលើពលរដ្ឋស្លូតត្រង់ដែលគេចង់បានការផ្លាស់ប្ដូរដែរ នៅកម្ពុជានោះទេ។ ប្រសិនបើ សម រង្ស៊ី អាចបញ្ឈប់បាតុកម្មនៅកាលីហ្វ័រញ៉ាបាន

**តទៅទំព័រទី ១៨**

CENTURY PHARMACY & OPTICAL
937 Gorham St ALL MAJOR INSURANCES ACCEPTED Tel: 978-455-6554

ឱសថស្ថានសេនជូរី :
យើងជា
អ្នកបំរើលោក
អ្នកយ៉ាងប្រសើរ!




▸ ផ្ដល់សេវាដល់ទីលំនៅ
▸ ខ្ចប់ឱសថតាមបំណង
▸ ជាឱសថស្ថានដែលលោកអ្នកអាចជឿជាក់ក្នុងចិត្ត

937 Gorham St Lowell, MA, 01852

លេខទូរស័ព្ទ 978-455-6554 / លេខហ្វាក់ 978-455-9476

REMEDIUM PHARMACY
ឱសថស្ថានរ៉ឺមីឌៀម
2 Vinal Square. North Chelmsford, MA 01863
ជាឱសថស្ថានបំរើការគ្រប់យ៉ាងដល់អ្នក
• ផ្ទេរឬផ្លាស់ប្ដូរសេវាកម្ម • ការវេចខ្ចប់ឱសថ
• ការលាយផ្សំឱសថ • បញ្ជូនឱសថដល់ផ្ទះដោយឥតគិតថ្លៃ
• ជួយធ្វើសំបុត្រទិញថ្នាំ • ផ្លាស់ប្ដូរយោបល់ដោយរាក់ទាក់
ឱសថស្ថានយើងខ្ញុំនិយាយភាសាខ្មែរ
FREE daily delivery | Blisterpack Packaging | Compounding Medication
Friendly consultations | Easy Transfers
Tel: 978-251-7070 | Fax: 978-251-7071


SAVE THE DATE
APA HERITAGE MONTH CELEBRATION
MAY 6, 2016
6:00-11PM
SAMPAO MEAS Hall
450 Chelmsford St.Lowell, MA 01851
Lowell, MA
The 6th Annual
KhmerPost USA
Media & Community Gala
For sponsorship opportunity, please contact Soben Pin at 978-656-8141
or visit our website at www.khmerpostusa.com

# កម្មវិធីប្រកួតគំនិតអាជីវកម្មសម្រាប់សហគមខ្មែរ និងអាមេរិក

**ដោយ ណារ៉េង មួង**

**ទីក្រុងឡូវែល រដ្ឋម៉ាសាឈូសេតះ** កាលពីថ្ងៃទី ២៤ ខែកុម្ភៈ កន្លងទៅនេះ អង្គការសហគ្រិនភាពសម្រាប់ទាំងអស់គ្នា (ឬហៅកាត់ថា EforAll) សហការគ្នាជាមួយសមាគមខ្មែរ (ឬហៅកាត់ថា CMAA) រៀបចំកម្មវិធីប្រកួតប្រជែងគំនិតអាជីវកម្មលើកទី២០ នៅភោជនីយដ្ឋានសាន់នីដា នាទីក្រុងឡូវែល។ ភ្ញៀវចូលរួមមានចំនួនជាង១00នាក់។ អាជីវកម្មខ្នាតតូចចំនួន១៥បានចូលរួមតាំងបង្ហាញផលិតផល និងគំនិតអាជីវកម្មរបស់ខ្លួន។ ក្នុងចំណោមនោះមានម្ចាស់អាជីវកម្ម និងអ្នកមានគំនិតបើកអាជីវកម្មចំនួន៨នាក់ បានប្រកួតប្រជែងគំនិតអាជីវកម្មរបស់ខ្លួន ដើម្បីឱ្យចៅក្រម៤នាក់ជាអ្នកដាក់ពិន្ទុ។



រូបពីឆ្វេងទៅស្តាំ ១) លោកស្រី ហ្វ្រែងឃី ដេកូតូ ប្រធានអង្គការ EforAll, ២) កញ្ញា អានី វង់ ៣) លោក ឌេវិន ម៉េហ្វី ៤) លោកស្រី សុភី ឆៀម ៥) លោក ភីដេ អាណាន់ ៦) លោក សុវណ្ណា ពៅ ប្រធានសមាគមខ្មែរ







គោលបំណងនៃកម្មវិធីប្រកួតប្រជែងគំនិតអាជីវកម្មនេះ គឺដើម្បីលើកស្ទួយគំនិតអាជីវកម្ម និងជួយបង្កើតមុខរបរថ្មីៗបន្ថែមទៀតសម្រាប់បងប្អូនពលរដ្ឋខ្មែរ-អាមេរិក និងជនជាតិអាមេរិកទូទៅ។

អ្នកចូលរួមប្រកួតប្រជែងគំនិតអាជីវកម្មដែលមានរយៈពេលបីនាទីសម្រាប់បេក្ខជនម្នាក់ៗ រួមមាន ៖

**១-** Letriah Masters តំណាងឱ្យ ˚errimack Valley Music and Arts Inc។ ជាអង្គការមិនរកប្រាក់កម្រៃផ្តល់សេវាដើម្បីដោះស្រាយបញ្ហាសិស្សដែលបណ្តាលមកពីការកាត់ថវិកាផ្នែកអប់រំ វិបត្តិសេដ្ឋកិច្ច និង បញ្ហាហិរញ្ញវត្ថុ

**២-** ខូ តារាឫទ្ធិជាជនខ្មែរ-អាមេរិក តំណាងឱ្យគំនិតបង្កើតកម្មវិធីមួយឈ្មោះថា Cambodian Culture After School Program ផ្តល់សេវាដើម្បីជួយសិស្សសាលាក្រោយម៉ោងសិក្សា ដូចជាកិច្ចការ Homework ជួយបង្ហាត់រាំ និង របាំខ្មែរ របៀបចម្អិនអាហារខ្មែរ អក្សរសាស្ត្រខ្មែរ ប្រដាល់ក្បាច់គុណខ្មែរបុរាណ ។

**៣-** Daniel Rajczyk តំណាងឱ្យ Asperger Works Inc។ ជាអង្គការមនុស្សធម៌ផ្តល់សេវាដើម្បីដោះស្រាយបញ្ហាគ្មានការងារធ្វើក្នុងចំណោមអ្នកដែលមានជំងឺ Autism Spectrum Disorders (ASD)

**៤-** David Tetreault, Henry DeLima, Terry Fox-Koor, **តទៅទំព័រទី ០៧**

ការិយាល័យ មេធាវី
ចំមាស ស្តាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852
• Immigration •អន្តោប្រវេសន៍
• Auto Crash •គ្រោះថ្នាក់រថយន្ត
• Divorce •លែងលះប្តីប្រពន្ធ
សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766

ការិយាល័យច្បាប់
រ៉ូសា និង តាំង





Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ ស៊ីស្កូ ជេ.រ៉ូសា
Andrew ´Bunna´ Taing, Esq.
មេធាវី អែន ទ្រីវប៊ុណ្ណា តាំង
Law Office of
Rosa & Taing
ATTORNEY AT LAW
SERVICES
• Auto Accidents/ Personal Injury
• Bankruptcy
• Immigration
• Consumer Protection
• Real Estate Closings/Disputes
• Divorces Child Custody
តំណាងក្តីដូចខាងក្រោម
• គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ
• ក្ស័យធន
• អន្តោប្រវេសន៍
• ការពារអតិថិជន
• ទំនាស់ផ្នែកអចលនវត្ថុ
• លែងលះ និងអាណាព្យាបាលកិច្ច
1550 Middlesex Street Lowell, MA 01851
Phone: 978-458-0934 | at@rosataing.com

Allstate. You're in good hands.
Veasna Chhay
Licensed Sales Producer
Home/Auto/Life MA & RI
Allstate Insurance Company
1535 Smith Street
North Providence, RI 02911
Phone 508-282-5820/Cell 401-588-4358
veasnachhay2@allstate.com



Personalized service.
Trusted advice.
" Also I do income tax return service for MA and RI for "Veasna Tax Preparation Serivices'."

# CENTURY PHARMACY & OPTICAL

937 Gorham St ALL MAJOR INSURANCES ACCEPTED Tel: 978-455-6554

យើងជា
ឱសថ
ស្ថានមួយ
ដែលអាចផ្តល់
ភាពជឿជាក់
ដល់គ្រួសារ
លោកអ្នក



យើងខ្ញុំ
សូមជូនពរ
មហាប្រសើរ
ដល់លោក
អ្នក

- យើងខ្ញុំមានផ្តល់សេវាបំរើការជូនឱសថដល់ទីលំនៅ ។
- យើងខ្ញុំទទួលកាតម៉ាសហ៊ារ៉, និងកាតធានារ៉ាប់រងសុខភាពផ្សេងៗទៀត
- សេវាបំរើការល្អ,អតិថិជនមានភាពជឿជាក់ ។
- យកចិត្តទុកដាក់លើបញ្ហាផ្ទាល់ខ្លួននៃអតិថិជនរាល់រូប ។
- វេចខ្ចប់ឱសថសមតាមបំណងនៃអតិថិជន ។
- មានផលិតកម្មពិសេសរបស់អូធីស៊ីជារៀងរាល់ខែ ។
- យើងខ្ញុំទទួលការផ្សំថ្នាំតាមបទបញ្ជាជូនដល់អស់លោកអ្នក ។ ជាឱសថស្ថានមួយអាចផ្តល់ភាពជឿជាក់ដល់គ្រួសារអ្នក ។






យើងខ្ញុំនិយាយភាសាខ្មែរ ។

លេខទូរស័ព្ទ 978-455-6554

លេខហ្វាក់ 978-455-9476

## 937 Gorham St Lowell, MA, 01852

## តមកពីទំព័រទី ០១ ស៊ូពឺធូស្ដេយ៍ អ្នកឈ្នះគឺ ហ៊ីឡារីគ្លីងតុន




**៣-រុយប៊ីយ៉ូ** បាន ៤១

**៤-កាស៊ីក** បាន ១៩

**៥-កាសុន** បាន ៧

បេន កាសិន ១៥.៤៩២

ដូច្នេះមកត្រឹមតែដំណាក់ការណ៍នេះ មនុស្ស ២នាក់បានលេចធ្លោមក គឺ ហ៊ីឡៃរី គ្លីងតុន នឹង ឌុណាល់ ត្រុម ។

ហ៊ីឡារី គ្លីងតុន ឈ្នះលើ សាំនឌឺ នៅរដ្ឋ អាឡាបាម៉ា, ជចចា, អាកិនសាស, ម៉ាសាឈូសិត, ថិណេស៊ី, នឹង វើជីនា ។

ឌុណាល់ ត្រុម ឈ្នះនៅរដ្ឋ អាឡាបាម៉ា, ជចជា, វើម៉ន, អាកិនសាស, ម៉ាសាឈូសិត, ថិណេស៊ី នឹង វើជីនា ។

លទ្ធផលសន្លឹកឆ្នោតនៅរដ្ឋម៉ាសាឈូសិត (គិតជាសន្លឹកឆ្នោត)

**ក-ខាងគណបក្សប្រជាធិបតេយ្យ**

ហ៊ីឡារី គ្លីងតុន ៥៧៨.៧១០

ប៊ីនី សាំនឌឺ ៥៨៨.២៩៣

រ៉ុគី ឌឺឡាហ្វូអង់តេ ១.២៨៣

**ខ-គណបក្សសាធារណរដ្ឋ**

ឌុណាល់ ត្រុម ២៩២.១៧៧

ជន កាស៊ីក ១០៨.០២៩

ម៉ាកូ រូប៊ីយ៉ូ ១០៧.១៧៩

ថេត គ្រូស៍ ៥៧.០៩៥




LOWELL

សមាគមបាល់ទាត់ យុវជននៅឡូវែល

Lowell Youth Soccer Association

Fall Registration — ចុះឈ្មោះសម្រាប់រដូវរងា

Teams are available for — នៅសល់កន្លែងទំនេរ

Ages 3-11 Recreation League — អាយុ ៣-១១ឆ្នាំ ក្រុមហាត់ទាត់បាល់

9-14 Travel League - — អាយុ ៩-១៤ ឆ្នាំ ចាប់ផ្ដើមប្រកួត

* Limited positions are available - Boys and Girls Under-10 - - Under-14

កំណត់កន្លែងដែលនៅសល់ -ក្មេងស្រី និងក្មេងប្រុសអាយុតិចជាង១០ឆ្នាំ -អាយុតិចជាង១៤ឆ្នាំ



Register On-line at:
lowellsoccer.com
978-918-0460



LEGEND
AUTO BODY INC.
(978) 458-2085

**Services**

- Auto Body
- Auto Mechanics
- Foreign and Domestics
- State and Insurance Certified

Towing - **978-815-9957** (K.C)

**មានបម្រើ**

- ជួសម៉ាស៊ីនយានយន្ត
- ប្រភេទយានយន្តក្នុង និងក្រៅប្រទេស

**កូយានយន្ត**

- បញ្ជាក់ប័ណ្ណធានារ៉ាប់រងទទួលស្គាល់ដោយរដ្ឋ

**ដឹកឡានត្រូវចងូវ៍** 978-815-9957 (ខេ-ស៊ី)



115 Rock St. Unt #7 Lowell, MA 01854

# ផ្ទុះបាតុកម្មនៅសហគមន៍ចិនអាមេរិកនៅប្រូកលីន ញ៉ូវយ៉ក

អ្នកធ្វើបាតុកម្មរាប់ពាន់នាក់ភាគច្រើនជាចិនកាត់អាមេរិក បានជួបជុំគ្នានៅឯឧទ្យានដោនថោន (downtown) កាលពីរសៀលថ្ងៃសៅរ៍ ដើម្បីបង្ហាញការគាំទ្រចំពោះលោក ភីតថើរ លាំង (Peter Liang) ដែលជាអតីតមន្ត្រីប៉ូលីសនៅឯក្រសួងមន្ត្រីប៉ូលីសទីក្រុងញូវយ៉កដែលត្រូវបានគេថ្កោរទោសពីបទមនុស្សឃាតកំរិតទីពីរ នឹងកំហុសវិជ្ជាជីវៈជាផ្លូវការនៅក្នុងការបាញ់សម្លាប់បុរសម្នាក់ដែលគ្មានអាវុធការនៅឯគម្រោងលំនៅដ្ឋានតំបន់ ប្រូកក្លីន Brooklyn ។

ខណៈពេលដែលពួកបាតុករបានបង្ហាញការអាណិតអាសូរចំពោះគ្រួសារគូរលី ពួកគេក៏រិះគន់ទៅលើការកាត់ក្តីនេះ ដោយនិយាយថា ការបាញ់បោះនោះគឺជារឿងអចេតនា ហើយនឹងលោកលាំងដែលមានអាយុ២៨ឆ្នាំមិនមានអារម្មណ៍ភ័យខ្លាចអ្វីទេបន្ទាប់ពីមានការផ្ទុះអាវុធ ខណៈពេលដែលកំពុងដើរយាមល្បាត a pitch-dark stairwell នៅឯ លូអ៊ីសភីងហោស(Louis H. Pink Houses) នៅឯប្រ៊ូក្លីន។

ដោយមានការជួបជុំគ្នានៅឯប្រ៊ូក្លីន បាតុករចិន អាមេរិកាំងខ្លះបានលើកទង់ជាតិអាមេរិកាំង នឹងសញ្ញាដែលនិយាយថា "គ្រោះថ្នាក់មួយជនរងគ្រោះ២នាក់"។ មនុស្សមួយចំនួនបាននិយាយថា ពួកគេជឿជាក់ថាលាំងដែលជាចិន អាមេរិកាំងបានត្រូវបានគេចោទប្រកាន់ឱ្យរងកំហុសជំនួសនាក់ឯទៀត ដើម្បីបិទបាំងនូវរឿងមន្ត្រីស្បែកសមួយចំនួនដែលមិនត្រូវបានគេចោទប្រកាន់ក្នុងឧបត្តិហេតុកាលពីឆ្នាំ២០១៤ ដែលទាក់ទងទៅនឹងបុរសជនជាតិស្បែកខ្មៅមួយនាក់ដែលត្រូវបានគេសំលាប់នឹងរួមបញ្ចូលទាំង អេរិក ងាន់នី (Eric Garner) ដែលត្រូវបានគេដាក់ចហ្សកហៀលដនឹងលោកមៃឃើរប្រោន ដែលជាយុវជនដែលត្រូវបានបាញ់សំលាប់ដោយប៉ូលីស នៅឯវឺរគឺរសុន (Ferguson) នៅឯរដ្ឋមីសសួរី (Missouri)។

វីកទូរៀ ហាន (Victoria Han) ដែលជាម្នាក់ក្នុងចំនោមអ្នករៀបចំនៅការជួបជុំនៅឯមីឈីងាន់ (Michigan) ដែលមានអ្នកចូលរួមច្រើនជាង៤០០នាកពី អ៊ីដាយអាណា (Indiana) បានប្រាប់សារព័ត៌មាន អ៊ីនបីសីថា បញ្ហានោះ គឺមិនមែនលាំងគួរតែមិនត្រូវទទួលទោសតែ ប៉ុន្តែការកាត់ទោសនោះគួរតែមានក្រឹតក្រំត្រឹមត្រូវនឹងយុត្តិធម៌ទៅតាមផ្លូវច្បាប់។ ហានបន្ថែមទៀតថាឪការថ្កោរទោសបែបនេះចំពោះលាំងបានបំផ្លាញនូវប្រព័ន្ធរបស់ពួកយើង ហើយរឿងនេះនឹងបំបាក់ទឹកចិត្ត នឹងជំនឿរបស់ជនអន្តោប្រវេសន៏មកលើប្រទេសមួយនេះ។

កាលពីថ្ងៃ សៅរ៍ ប្រជាជនប្រហែលជា ១២៤០០០ នាក់បានចុះហត្ថលេខានៅលើញាតិ ដោយបានធ្វើអោយសេតាក់វិមានឆ្លើយតបដោយនិយាយថា ខ្លួនគ្មានតួនាទីក្នុងការសំរេចចិត្តឱ្យព្រះរាអាជ្ញារដ្ឋ ឬក៏តំបន់ថាតើការកាត់ក្តីបែបនេះត្រឹមត្រូវ ឬក៏អត់។






បើយោងទៅតាមសាកស្សីបានអោយដឹងថា កាលពីថ្ងៃ ទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ គូរលី (Gurley) បានចូលទៅស្ទះវិល (stairwell) តាមជាន់ទីប្រាំពីរជាមួយនឹងមិត្តភក្តិរបស់គាត់ឈ្មោះ មេលីសា បាត់លឺរ (Melissa Butler) ប៉ុន្តែភ្លាម១ក្រោយពេលម៉ោង១១យប់លាំងដែលកំពុងបំពេញភារះកិច្ចដើរយាមល្បាតពីជាន់ទី៨ជាមួយនឹងដៃគូររបស់គាត់ឈ្មោះ សន លេនដៅ (Shaun Landau) បានបាញ់មួយគ្រាប់ ប៉ុន្តែគ្រាប់កាំភ្លើងនោះបានផ្លាតពីជញ្ជាំងទៅចំលោក គូរលី (Gurley) ដួលសន្លប់នឹងស្លាប់មួយរំពេចពេលតែកំពុងដើរចុះទៅជាន់ទី៥ ជាមួយមិត្តភក្តិរបស់គាត់ឈ្មោះ បាត់លឺរ (Butler)។

លោក វីលលាម ប្រាតុន (William Bratton) ដែលជាស្នងការនៅក្រសួងមន្ត្រីប៉ូលីសញូយ៉កបាននិយាយថា ការបាញ់បណ្តាលឱ្យមានគ្រោះថ្នាក់បែបនោះគឺបណ្តាលមកពីភាពមិនប្រក្រតីជាមួយនឹងកាំភ្លើងរបស់លាំង។

លាំងដែលនៅមិនទាន់ទទួលបាននូវការកាត់ទោសនោះនឹងអាចជាប់ពន្ធធានាគាររយះពេល១៥ឆ្នាំ នៅពេលដែលតុលាការយុត្តិធម៌រដ្ឋកំពូល ដេនីឈុន (Danny Chun) អនុម័តនៅការកាត់ក្តីនេះ នាថ្ងៃទី១៤ ខែមេសា ខាងមុខនេះ។ រេកូសហិត (Rae Koshetz) នឹង រូប៊ីតប្រោន (Robert Brown) បាននិយាយថា ពួកគេនឹងសើរើរនូវការកាត់ទោសនេះ ប្រសិនបើឈុនមិនបានទទួលនៅញត្តិឱ្យទុកសាលក្រមនេះទៅម្ខាងដែលអនុម័តដោយក្រុមប្រឹក្សាតុលាការដែលមានប្រុសប្រាំពីរនាក់នឹងស្ត្រីប្រាំនាក់ កាលពីថ្ងៃទី ១១ ខែកុម្ភៈ។

ប៉ុន្តែព្រះរាអាជ្ញាអមតុលាការបានគូសបញ្ជាក់ថា សកម្មភាពរបស់លាំងសមស្របដោយ ប្រាប់ទៅក្រុមប្រឹក្សាតុលាការថា លាំងបានរំលោភបំពាននៅការបណ្តុះបណ្តាលនៃសារះសំខាន់នៃជីវិតនឹងការស្លាប់ដ៏ធ្ងន់ធ្ងរនៅពេលគាត់បានដកអាវុធបាញ់ឡើងដោយគ្មានហេតុផល ហើយនឹង មិនគួរត្រូវបានគេកាត់ទោសពីបទមនុស្សឃាតនោះទេ ប៉ុន្តែគាត់បានបន្ថែមថា "ពួកយើងពិតជាភ័យខ្លាចនូវលទ្ធផលចាប់ពីការចាប់ផ្តើមមក"

គាត់ក៏បានបន្ថែមថា "មានទូវឃ្លាធម្មតាមួយ ឈ្លោះប្រកែកជាមួយដៃគូទៅលើការស្នើរឱ្យមានការជួយបន្ទាប់ពី គូរលេ បានដេកស្លាប់។

ចនលៀវ (John Liu) ដែលជាអតីតអ្នកត្រួតពិនិត្យមើលទីក្រុងនេះ ហើយក៏ជា អាស៊ីអាមេរិកាំងលើកតំបូង ដែលត្រូវបានតែងតាំង Citywife office បានប្រាប់អ្នកចូលរួមថា លាំង នៅក្នុងប្រទេសអាមេរិកាំងរយះពេល១៥០ឆ្នាំមកហើយ ដែលគេនិយាយថា មិន "មែនជាឱ្កាសរបស់បុរសចិន" (not a Chinama’s chance) វាមានន័យថា ប្រសិនបើអ្នកជាជនជាតិចិនសង្ឃឹមនឹងមិនមានសំរាប់អ្នកទេ៕




Clemente Park Chiropractic

Chetra A. Keo, D.C.

851 Middlesex Street. Lowell, MA 01851
(978) 937-1492

Treatments

- Neck Pain
- Back Pain
- Lower Back Pain

- ឈឺ-ក
- ឈឺខ្នង
- ឈឺចង្កេះ-ខ្នង

- Automobile Injuries
- Personal Injuries
- Work Related Injuries

- គ្រោះថ្នាក់រថយន្ត
- រងរបួស
- របួសនៅកន្លែងធ្វើការ

## តមកទំព័រទី ០៣ កម្មវិធីប្រកួតគំនិតអាជីវកម្ម...

Ann McGill និង Brian Holt តំណាងឱ្យក្រុមហ៊ុន Veterans QRF ផ្ដល់សេវាដើម្បីដោះស្រាយបញ្ហារបស់អតីតយុទ្ធជនដែលរងការលំបាកក្នុងការទទួលបានប្រាក់ពិការ ។

**៥-**Michael Underwood តំណាងឱ្យ MyAl Software ជាកម្មវិធីថ្មីដែលផ្ដល់សេវាដើម្បីបិទកុំឱ្យកុមារបើកមើលរូបភាពអាសអាភាសប្លែកៗ។

ចៅក្រមទាំងបួនរូបដែលចូលរួមផ្ដល់ពិន្ទុរួមមាន:

**១-** លោក ខេវិន មើហ្វី មន្ត្រីគ្រប់គ្រងក្រុងឡូវែល

**២-**កញ្ញា អានី វង់ ម្ចាស់ហាងសម្លៀកបំពាក់ឈ្មោះ Humanity Boutique











តាមអ៊ិនធើណិត

**៦-** Ryan Wu តំណាងឱ្យ Buy Time ផ្ដល់សេវាផ្នែកវេជ្ជសាស្ត្រដោយប្រើឧបករណ៍បញ្ចុះកំដៅក្នុងខ្លួនអ្នកជំងឺឱ្យបានឆាប់ ។

**៧-** Jennifer Shao តំណាងឱ្យ Jennifer Shao’s Paintings ផ្ដោតលើផ្នែកវិចិត្រកម្មយកតាមលំនៅសិល្បៈរបស់ជនជាតិចិន និងសិល្បៈសហសម័យ និងលើកទឹកចិត្តឱ្យកុមារស្រលាញ់សិល្បៈ និងអ្នកទី ។

**៨-**ជាបេក្ខជនដែលជ្រើសរើសដោយឥតព្រាងទុក ជាជនជាតិថៃ-អាមេរិក។ អ្នកទី ៨ នេះមានគំនិតបង្កើតកម្មវិធីមួយឈ្មោះថា Take-In ដែលចងក្រងមនុស្សជាបណ្ដាញ ដើម្បីចែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹងអាហារឆ្ងាញ់ និង

**៣-** លោក ភីជេ អាណាន់ ម្ចាស់ក្រុមហ៊ុន Alcyone និង

**៤-**លោកស្រី សុភី ធៀម (មន្ត្រីគ្រប់គ្រងផ្នែកបណ្ដុះបណ្ដាល និងអភិវឌ្ឍន៍ និង ជានាយិការងនៃធនាគារ Enterprise Bank ។

ជាលទ្ធផលបេក្ខជនបួនរូបទទួលបានរង្វាន់ដូចខាងក្រោម:

**១-** រង្វាន់ទី ១ ទឹកប្រាក់ ១ 000 ដុល្លាបានទៅ Asperger Works Inc ។

២-រង្វាន់ទី ២ ទឹកប្រាក់ ៧៥0 ដុល្លារ បានទៅលោក ខូ តារាឫទ្ធិនៃ Cambodian Culture After-School Program

**៣-** រង្វាន់ទី ៣ ទឹកប្រាក់៥00ដុល្លារបានទៅ Take-In

### ដំណឹងខ្លីៗ

## សាលាបឋមសិក្សា "ហ្វ្រង់កូអាមេរិកាំងស្គូល" នឹងត្រូវបិទទ្វារ

**ឡូវែល:** បង្កើតឡើងតាំងពីឆ្នាំ១៩០៨ សាលា "ហ្វ្រង់កូ" នឹងត្រូវបិទទ្វារជាស្ថាពរ បន្ទាប់ពីបើកទ្វារទទួលសិស្សសិក្សាប្រកបដោយជោគជ័យ១០៨ឆ្នាំរួចមក។ សាលាមានលក្ខណ:សាសនាកតូលិកនេះ បើកបង្រៀនសិស្សពី "ថ្នាក់មតេយ្យ-ដល់ថ្នាក់ទី៨" បានត្រូវគេទទួលស្គាល់ថា ជាសាលាមានកម្មវិធីអប់រំកីឡាតល្អបំផុត "Excellence" នៅឡូវែលនេះ។

ដឹកនាំការអប់រំនៅក្នុងអាគារដែលមានប្រវត្តិរាប់រយឆ្នាំមកហើយ គណកម្មការនាយកបានធ្វើសេចក្ដីសម្រេចរបៀបនេះ ដោយយោងទៅតាមស្ថានភាពថវិការជាក់ស្ដែងសម្រាប់ទ្រទ្រង់សាលា "ហ្វ្រង់កូអាមេរិកាំង" នៅឆ្នាំ២០១៦-១៧ខាងមុខ។ ការបិទទ្វារប្រកបដោយភាពទោមនស្សសោកស្ដាយ សាលា "ហ្វ្រងង់កូ" កំពុងរៀបចំបង្វែរការសិក្សារបស់កុមារទៅសាលា "កាតូលិកស្គូល Cathilic School" ដែលមានរបៀបអប់រំសិស្សប្រហាក់ប្រហែលគ្នា។

សីស្ទ័រ ឡូរ៉ែន រីកឆើត ជានាយកសាលា នឹងលោក រ៉ូបើត អដេត ជាប្រធានគណកម្មការសាលាបានចុះហត្ថលេខាលើលិខិតប្រកាសព័ត៌មានសម្ដែងការយោគយល់ពីការរំជួលចិត្តពីសំណាក់ប្រជាជនជាច្រើនដែលប៉ះពាល់ពីសេចក្ដីសម្រេចនេះ ហើយបញ្ជាក់ថា "រួមជាមួយនឹងកាតូលិកស្គូលយើងនៅតែបង្ហាញនូវការបន្តផ្ដល់គុណភាពអប់រំ សុវត្ថិភាព នឹងការថែទាំបរិយាកាសនាខែបន្តទៅមុខទៀតនោះ"។



ក្រៅពីចៅក្រមអ្នកចូលរួមត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតដាក់ពិន្ទុបេក្ខជនដែលខ្លួនពេញចិត្តផងដែរ។ ជាលទ្ធផល Veterans QRF ឈ្នះរង្វាន់ពេញចិត្តពីអ្នកចូលរួម។

ចំពោះអ្នកដែលមានគំនិតចង់បង្កើតអាជីវកម្មថ្មី ឬមានអាជីវកម្មរួចហើយ និងចង់ពង្រីកអាជីវកម្ម ឬចង់ធ្វើឱ្យអាជីកម្មមានភាពល្អប្រសើរជាងមុន សូមដាក់ពាក្យចូលរៀនក្នុងវគ្គបណ្ដុះបណ្ដាលរបៀបផ្នែកអាជីវកម្ម។ វគ្គបណ្ដុះបណ្ដាលនេះ មានរយ:ពេល១២ ខែ និងផ្ដល់ជូនដោយឥតគិតថ្លៃ។ ថ្ងៃទទួលពាក្យសុំចូលរៀន គឺថ្ងៃទី ២១ ខែមីនា ឆ្នាំ២០១៦ ដល់ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០១៦។ ទាក់ទងសូមលោក ណារ៉េត មួង តាមរយ:លេខទូរស័ព្ទ ៩៧៨-៤៥៤-៦២00 (ខ១០១៨) ឬតាមរយ:អ៊ីម៉េល nmuong @cmaalowell.org ឬ www.EforAll.org ប្រសិនបើលោកអ្នកចង់ដឹងព័ត៌មានបន្ថែមអំពីការដាក់ពាក្យចូលរៀនកម្មវិធីបណ្ដុះបណ្ដាលផ្នែកអាជីកម្មនេះ៕



# ដកស្រង់សារព័ត៌មានថ្ងៃទី២៨ វិច្ឆិកា ២០១៥ ដល់ ១៥មករា២០១៦

**ដោយៈ ហ្វ្រង់ស្វា ប៉ុងស្ហ**
**បកប្រែពីភាសាបារាំងដោយខ្មែរផុសស.រ.អា.**
**វិស័យសង្គមកិច្ចខ្មែរ**

**ចលនាសង្គម**

*ថ្ងៃ១៦ធ្នូ ចលនាហឹង្សាដែលទំនងជាកើតនៅក្រៅសហជីពទាំងអស់ ធ្វើឱ្យរង្គោះរង្គើតំបន់សេដ្ឋកិច្ចទាំង២នៅបាវិត(ម៉ាហាត់តាន់ នឹងថៃសេន) ដែលម្ចាស់រោងចក្រតែងមានទំនាក់ទំនងមិនល្អជាមួយសហជីព។ អជ្ញាធរខេត្តបានបញ្ជាឱ្យបិទរោងចក្រទាំង៤៧ចំនួន២ថ្ងៃ។ សហជីពម្ចាស់រោងចក្រ"GMAC"បានតវ៉ាថា ខ្លួនខាតបង់២លានដុល្លារក្នុងមួយថ្ងៃ។ ការទាមទាររបស់កម្មករមិនច្បាស់លាស់ តែនៅទេលើបញ្ហាប្រាក់ខែ។ កម្មករ៤នាក់ត្រូវចាប់ខ្លួនពីបទ "ញុះញង់ឱ្យធ្វើកូដកម្ម"។ រោងចក្រត្រូវបានបិទម្តងទៀតនៅថ្ងៃ២៣-២៤ធ្នូ ដោយអាជ្ញាធរខេត្ត ដើម្បីឱ្យមានការស្ងប់ស្ងាត់ តែម្ចាស់រោងចក្រមិនពេញចិត្តទេ។ ថ្ងៃ២៣ធ្នូ កូដកម្មប្រែក្លាយទៅជាហឹង្សា កូដករបានដោយដុំថ្មលោះក្រុមប៉ូលិសធ្វើឱ្យបែកបង្អួចកញ្ចក់រោងចក្រតែបានត្រូវច្រានបំបែកដោយបាញ់ទឹកទៅលើ។ អាជ្ញាធរខេត្ត ម្ចាស់រោងចក្រនឹងសហជីពកម្មករ បានមករួមប្រជុំជាបន្ទាន់ៈ គេបានសុំឱ្យដោះលែងកម្មករទសង៤នាក់។ អ្នកដឹកនាំសហជីពនិយាយជាថ្មីថា ខ្លួនមិនមានអ្វីពាក់ពាន្ធនឹងការបះបោរនោះទេ ហើយសន្យាថានឹងនឹងធ្វើអ្វីគ្រប់យ៉ាង ដើម្បីឱ្យស្ងប់មកវិញ។ កម្មករបើកឡាន៦នាក់ដែលបានបើករថយន្តឈ្នួលដឹកកម្មករ បានត្រូវចាប់ខ្លួននៅថ្ងៃ២៤ធ្នូ។ រោងចក្របានសន្យារបើកប្រាក់ពាក់កណ្តាលនៃថ្ងៃដែលបិទ២ថ្ងៃដោយអាជ្ញាធរខេត្ត លុះត្រាតែកម្មករមកធ្វើការឱ្យបានទៀងទាត់រហូតដល់ថ្ងៃបើកប្រាក់ខែ។ សហជីពខ្លះទាមទារប្រាក់ខែ១០០%ផ្ទាប់ដោយគម្រាមធ្វើកូដកម្ម(ខ.ដ២២.១២.១៥)។ ដោយមិនចង់ទទួលស្គាល់សហជីពស្របច្បាប់ម្ចាស់រោងចក្រប្រឈមមុខនឹងការផ្ទុះហឹង្សាដែលគ្រប់គ្រងមិនបាន ។

*ថ្ងៃទី៧ធ្នូ កម្មករ៤០នាក់សម្លប់បាត់ស្មារតីនៅក្នុងរោងចក្រតម្បាញ- ២ថ្ងៃទៀតមាន៧២នាក់ទៀតសម្លប់នៅកំពុងចាម- ១៤ នៅថ្ងៃ ១៦-៣៨នាក់ នៅថ្ងៃ១៦ធ្នូ "ខ.ដ.១៧.១២.១៥"

*ថ្ងៃទី២៣ធ្នូ អ្នកបើកបរឡានធំជាង៤០០ដែលមានឡានចង្កូតស្តាំ បានធ្វើឱ្យគាំចរាចរផ្លូវធំៗនៅភ្នំពេញ បន្ទាប់ពីមានបញ្ជាពីក្រសួងដឹកជញ្ជូនឱ្យប្តូរចង្កូតឡានមកខាងឆ្វេងវិញ។ ឡានទាំងនោះច្រើនតែនាំចូលដោយខុសច្បាប់។ ម្ចាស់ឡានសុខចិត្តបង់ថ្លៃពន្ធដារ តែមិនចង់ប្តូរប្រព័ន្ធចង្កូតទេ។ ពួលគេបានតវ៉ាឈ្នះ "ខ.ដ.២៤.១២.១៥"

*ចាប់ពីថ្ងៃទី២៥ធ្នូ កម្មករកាត់ដេរ "អាស៊ុលស៊ីទ័រ"ចំនួន៨០០នាក់បានធ្វើបាតុកម្មដោយសន្តិភាពដើម្បីទាមទារបង្កើនគុណភាពនៅកន្លែងធ្វើការ។ ពួកគេបាត្រូវវាយប្រហារដោយក្រុម"ខូចខិល" ធ្វើឱ្យរបួស៥នាក់ នឹងចាប់ខ្លួន៥នាក់ទៀត ចំណែកឯជន"ខិលខូច"ត្រូវបន្តដេញតាមចាប់។ កម្មករប្រមាណ៤០០នាក់ធ្វើញត្តិទាមទារឱ្យដោះលែងមិត្តពួកគេមកវិញ"ខ.ដ.១៥.១.១៦"។

*កូដកម្ម៣សប្តាហ៍បានរំខានដំណើរការសណ្ឋាគារ"វិកតូរីយ៉ាអង្គរ" ដែលមានទីស្នាក់ការនៅប៉ារីសគេតវ៉ាប្រឆាំងនឹងការការបណ្តេញនិយោជិក១៧នាក់ កាលពីខែកញ្ញា "ខ.ដ.១៣.១.១៦"

*ថ្ងៃទី១២មករា ឡានធំ២ ដឹកកម្មករជាង១០០នាក់ទៅធ្វើការបានត្រូវក្រឡាប់ ធ្វើឱ្យមានស្លាប់៥នាក់របួស៦៧នាក់ ក្នុងនោះមាន១៥នាក់របួសធ្ងន់ -បញ្ហាសន្តិសុខដឹកជញ្ជូន គឺជាបញ្ហាធំមួយរបស់កម្មករ"ខ.ដ.១៣.១.១៦"។

**និរទ្ទេស-ដីសម្បទាន-កាប់ព្រៃឈើ**

*ការកាប់ព្រៃឈើនៅតែបន្ត បើទោះជាអាជ្ញាធរក្នុងតំបន់សាកនឹងទប់ស្កាត់ក៏ដោយៈ ថ្ងៃទី២៨វិច្ឆិការ ឡាន៣ ដឹកឈើមានតម្លៃ៣ម៉ែត្រគូប ត្រូវចាប់បានតែអ្នកបើកបានរត់រួច- ថ្ងៃទី១៩ធ្នូ មេប៉ូលីសម្នាក់ត្រូវស្លាប់នឹងម្នាក់ទៀតរងរបួសបន្ទាប់ពីត្រូវបុកដោយចេតនាដោយរថយន្តមួយទៀតដែលការពារឡានដឹកឈើមានតម្លៃមួយរថយន្តនោះមានផ្លាកលេខសំគាល់យោធា- ថ្ងៃទី២០ធ្នូ ក្រុមប៉ូលិសចាប់បានឈើ៣០ដុំដឹកដោយត្រាក់ទ័រ៥ នៅ១០ម៉ែត្រពីព្រំប្រទល់ដែនវៀតណាម...។ល។ នៅយប់ទី៣១ធ្នូ ក្រុមកាប់ឈើវៀតណាម បានត្រូវគេប្រទះកំពុងកាប់ឈើប្រណិតនៅ២០គ.ម.ក្នុងដីខ្មែរ ។ ពួកគេបានរត់ចោលប្រដាប់ប្រដារទាំងអស់អ្នកភូមិចោទប៉ូលិសនឹងទាហ៊ានថា ជាអ្នករួមគំនិត "ខ.ដ.៨.១.១៥"។

*ថ្ងៃទី១០ធ្នូ ភ្នងនៅមណ្ឌលគីរីប្រមាណ៣០០នាក់តវ៉ាឱ្យលប់ដីសម្បទានដែលមានអណ្តូងមានអនុញ្ញាត្តទៅឱ្យក្រុមហ៊ុនចិន រ៉ុង ចេង ដែលប្រើជាតិគីមីដ៏គ្រោះថ្នាក់"ខ.ដ.១១.១២.១៥"។ ក្រុមប៉ូលិស៧០នាក់ បានចុះទៅឆែកអណ្តូងសិប្បកម្ម៤នៅក្នុងតំបន់"សន្ទាន់"នៅព្រៃឡុងអ្នកជីកអណ្តូងរត់ទៅបាត់អស់"ខ.ដ.២៥.១២.១៥"។

*ថ្ងៃទី១៤ធ្នូ អ្នកភូមិប្រហែល២០០នាក់នៅភ្នំ"អូរ៉ាល់"តំណាងឱ្យ៤២១គ្រួសារ នាំគ្នាធ្វើបាតុកម្មប្រឆាំងនឹងការរឹបអូសយកដីរបស់ពួកគេកាលពីឆ្នាំមុន ដោយព្រឹទ្ធសមាជិក លីយ៉ុងផាត់ បើម្បីយកទៅដាំអំពៅ។ កាលពីខែសីហា គណកម្មការសិទ្ធិមនុស្សនៃសភាជាតិបានសរសេរលិខិតទៅអភិបាលខេត្តដើម្បីសុំឱ្យត្រឡប់ដីនោះទៅឱ្យគ្រួសារគេវិញ។ បើតាមអាជ្ញាធរគ្រួសារ៧០%បានត្រូវឱ្យប្តូរទីលំនៅឱ្យ រីឯ៣០%មិនបានសំណងទេ ដោយរស់នៅលើដីរដ្ឋ "ខ.ដ.១៥.១២.១៥"

*ថ្ងៃទី២៤ធ្នូ "ខេមបូឌាដេលី" បានបង្ហាញផែនទីនឹងឈ្មោះជាភស្តុតាងថា មានដី៤ម៉ឺនហិកតា បានត្រូវផ្តល់ជាសម្បទានដល់ក្រុមហ៊ុនវៀតណាមនៅ៤០គ.ម។ ក្នុងខេត្តមណ្ឌលគិរី ដែលតាមការពិតគឺជាកម្មសិទ្ធរបស់កងទ័ពវៀតណាម។ រូបថតតាម"សាទរឡាយ"បានបង្ហាញពីផ្លូវជាច្រើននាំឆ្ពោះទៅប្រទេសវៀតណាម៕

## ដំណឹងខ្លីៗ

# ចាប់បុរស៤នាក់នៅ"បេដហ្វឹត"

បុរស៤នាក់ប្រឈមមុខនឹងតុលាការសង្កាត់"ខនខូត"នាថ្ងៃចន្ទ ចោទប្រកាន់ពីបទលួចចូលផ្ទះគេ នៅផ្លូវ "ហ្គេលឈី"កាលពីព្រឹកថ្ងៃសុក្រមុន។ ប៉ូលិសបានទៅដល់កន្លែងកើតហេតុនៅម៉ោង ១១:៤៧ បន្ទាប់ពីមានសេចក្តីរាយការណ៍ប្រាប់មកថា "មានផ្ទះកំពុងត្រូវគេគាស់បង្អួចចូលក្នុងផ្ទះ"។

មេបញ្ជាការប៉ូលិស"បនត័រណូ"និយាយថា ចាប់បានម្នាក់នៅក្នុងឡាន ដែលចាំនៅមុខផ្ទះនៅពេលដែលអ្នកឯទៀតនៅក្នុងផ្ទះនៅឡើយ។ អ្នកទាំង៤នឹងត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋគាស់ចូលផ្ទះគេទាំងថ្ងៃ ដោយមានឧបករសម្រាប់គាស់ទ្វារមួយចំនួន- អ្នកទាំង៤នោះឈ្មោះ

**១-យី វ៉ី អាយុ៣**
**២-ឆេង នី អាយុ៤៣ នៅបូស្តុន**
**៣-មឹង ហួរ អាយុ៥០ នៅគ្វីនស៊ី**
**៤-ស៊ូ តាន់ហៀង អាយុ២១ នៅបូស្តុន**

ប៉ូលិសបានឆែកឡានហ្ស៊ីប២០១៥"ឆេរ៉គី"ពណ៌ខ្មៅរបស់ជនសង្ស័យមានឃើញកូនសៀវភៅដែលមានអស័យដ្ឋានជាច្រើននៅជុំវិញតំបន់"ញូតនគ្លិន"នេះ -គេសង្ស័យថា ជាអស័យដ្ឋានដែលជនទាំងនោះអាចមានទាក់ទងទៅនឹងការលួចប្លន់ក្នុងផ្ទះផ្សេងទៀត។

មេប៉ូលីស"បនត័រណូ"និយាយបន្ថែមថា បើនរណាមានពត៌មានអ្វីទាក់ទងទៅនឹងជនសង្ស័យទាំងនោះ សូមឱ្យដំណឹងទៅប៉ូលិសស៊ើបអង្កេតនៅ"បេតហ្វិត"៨៧១-២៧៥ ១២១២។

# "ថេសបូរី"ប៉ូលិសចាប់បានអ្នករត់ពន្ធមនុស្ស

**ឡូវែលៈ**ប៉ូលិសបានចាប់ខ្លួននឹងចោទប្រកាន់បុរសម្នាក់ឈ្មោះ លាវរិទ្ធសាធ អាយុ៥៥ឆ្នាំ នៅ៥៥ផ្លូវ"វីភូល"ពីបទនាំមនុស្សស្រីក្មេង២នាក់អាយុលើស១៨ឆ្នាំ មកពី "ប្រូវិដង់" ទៅបំរើភ្ញៀវផ្លូវភេទដោយយកកំរៃនៅសណ្ឋាគារមួយនៅផ្លូវ"អន់ឌូវ័រ-ផ្លូវ១៣៣"ក្នុងពេលដែលស្ត្រីទាំង២នាក់នោះ កំពុងបន្តរទិដ្ឋាការស្នាក់អាស្រ័យនៅស.រ.អា.។



ប៉ូលិសបានទទួលដំណឹងពីបុគ្គលិកសណ្ឋាគារដែលសង្ស័យថា ស្ត្រីក្មេង២រូបនោះ បានត្រូវដឹកនាំដោយ លាវរិទ្ធ សាធ ដើម្បីមកបំរើផ្លូវភេទយកកម្រៃសម្រាប់ចែកដល់ខ្លួន។ សាធ បានត្រូវចាប់ខ្លួនពីថ្ងៃសុក្រ ហើយចោទប្រកាន់ពីរត់ពន្ធមនុស្សឱ្យធ្វើពេស្យាចារបំរើផ្លូវភេទសម្រាប់រកកម្រៃ។

សាធ បានត្រូវនាំមកបង្ហាញខ្លួននៅមុខតុលាការក្រុងឡូវែលដែលចៅក្រម "ដាន ក្រេន" ដាក់តម្លៃ៥.០០០ដុល្លារ សម្រាប់កក់ឱ្យនៅក្រៅឃុំ ហើយចេញបញ្ជាមិនឱ្យទៅទាក់ទង ឬទៅជិតអ្នករងគ្រោះឡើយបន្ទាប់ពីបានដាក់ប្រាក់កក់៕



# ទស្សនាប្រជុំកោះការ៉ាអ៊ីប










**ដោយ សុបិន ពិន**

ប្រជុំកោះ"ការាអ៊ីប"ឬ"ការីប៊ីន"ជាគោលដៅទេសចរណ៍ពិលោកដ៏ធំមួយដែលស្ថិតនៅខាងជើងឈៀងខាងកើតនៃអាមេរិកខាងត្បូង គឺនៅពីខាងត្បូងនៃប្រទេស"គូបា" គឺជាប្រទេសដែលមានធាតុអាកាស"ត្រូពិកាល" ដូចគ្នានឹងធាតុអាកាសនៃប្រទេសកម្ពុជាដែរ។

ថ្ងៃទី១៩កុម្ភៈ២០១៦នេះ យើងធ្វើដំណើរទៅដល់កោះនេះម្តងទៀត ដើម្បីសម្រាកកាយមួយសប្តាហ៍ ពីព្រោះកាលពី២ខែមុនយើងបានយកពេលទៅសម្រាកកាយមួយសប្តាហ៍ដែរទៅ"ហ្វ្លរីដា"តែខកចិត្តបន្តិច ពីព្រោះតែគេចពីព្រិលនៃឡូវែលបែរជាទៅប៉ះឯធាតុអាកាសត្រជាក់នឹងមេឃភ្លៀង នៅលើតំបន់លំហែរកាយនោះទៅវិញ- សង្ឃឹមថា លើកក្រោយនេះនឹងមានសំណាងគ្រាន់បើជាងមុន។

យើងជិះយន្តហោះដឹកមនុស្សប្រមាណ ២០០នាក់ ពី"ន្ញូយ៉ក"សំដៅទៅកាន់ចំណតអាកាសយាន្តអន្តរជាតិ"សាំងដូមិនគោ"ក្នុងរយៈពេលតែ២ម៉ោងកន្លះតែប៉ុណ្ណោះ។ យើងរីករាយដោយបានទទួលចំហាយក្តៅធម្មជាតិភាយៗជាលើកដំបូងបង្អស់គិតចាប់តាំងពីរដូវរងាចូលមកដល់នៅពេលយើងចេញពីយន្តហោះភ្លាម។ ប្រជាពលរដ្ឋនៅទីនោះសម្បុរខ្មៅស្រស់ស្អាតស្តមខ្ពស់ខុសគ្នាស្រឡះពីពលរដ្ឋអាហ្វ្រិកា-គេច្រើននិយាយភាសា "ស្ប៉ានីស" ជាង"អង់គ្លេស" តែក៏មានភាសា "គ្រាម" នៃជនជាតិគេសម្រាប់ទាក់ទងគ្នាដែរ។ មិនត្រឹមតែខ្ញុំទេ ដែលរំភើបនឹងទស្សនីយភាពថ្មីដ៏ប្រណិតរៀបចំនឹងចាំទទួលយើងជាភ្ញៀវទេសចរនោះទេ សូម្បីតែប៊ុណ្ណារ៉ូ កូនខ្ញុំអាយុ៦ឆ្នាំ ក៏រីករាយខ្លាំងណាស់ដែរ សួរខ្ញុំចប់តាមផ្លូវថា "ពេលណាបានទៅដល់-ៗ" និយាយនឹងលេងតាមផ្លូវរហូតគ្មានឈប់-ពេលខ្ញុំឱបគេនៅនឹងទ្រូង ទើបខ្ញុំដឹងថាបេះដូងគេដើរញាប់ខ្លាំងណាស់ ទាល់តែមកដល់គោលដៅហើយសម្រាកបន្តិច ទើបបង្អន់ភាពពុះកញ្ជ្រោលនោះបាន។ មានអ្នកចាំមកទទួលយើងពីយន្តហោះទៅ "ភូមិសំណាក់" ឈ្មោះ"បាយ៉ាព្រិនស៊ីប"ដែលគេត្រូវបើករថយន្តប្រមាណ១ម៉ោងទៀត ទើបបានទៅដល់"ភូមិបាយាព្រិនស៊ីប"លាតសន្ធឹងរាប់គីឡូម៉ែត្រក្រឡា នៅដាច់ស្រយ៉ាលពីភូមិនៃម្ចាស់ស្រុកនោះភូមិនោះមានលទ្ធភាពនឹងទទួលភ្ញៀវ១ពាន់នាក់ក៏បានដែរ។ ក្នុងបរិវិណនោះអ្វីៗសុទ្ធតែសង់សិប្បនិមិត្ត ប្រឌិត បង្កើតឡើង ចេញពីសេចក្តីស្រម័យចង់បានរបស់មនុស្សលោកធម្មតាទាំងអស់ យើងអាចនិយាយបានថា "យើងបានមករស់ក្នុងឋានសួគ៌បាន១សប្តាហ៍ដោយមិនមានខ្វល់អ្វីទាំងអស់"បាន។ តើមិនខ្វល់ពីលុយបានទេ?

បើនិយាយពីលុយ ដែលជាទម្លាប់ "ឋានកណ្តាល" របស់យើងវិញនោះ ខ្ញុំបានទិញដំណើរនេះក្នុងតម្លៃ៣ពាន់ដុល្លារសម្រាប់ខ្លួនខ្ញុំ ប្តីខ្ញុំ នឹងប៊ុណ្ណារ៉ូ តាំងពីចេញពីផ្ទះ រហូតដល់ត្រឡប់មកដល់ផ្ទះវិញ យើងគ្មានចំណាយប្រាក់អ្វីទៀតទាំងអស់។ មកដល់ "បាយ៉ា..." មិនទាន់បាន១ម៉ោងផង យើងទទួលបានវិញ នូវបន្ទប់ដេកម៉ាស៊ីនត្រជាក់ដ៏ស្រស់ច្រឡឹងមួយមានគ្រែ៣ បន្ទប់ទឹកអនាម័យស្អាតថៃស... បន្តិចមកយើងចេញទៅទទួលទានអាហារពេលល្ងាចក្នុងភោជនីយដ្ឋានដ៏ធំទូលាយមួយក៏រីតគុណភាពផ្កាយ៥ ដែលយើងអាចបរិភោគឈ្ងុយឆ្ងាញ់ក្នុងចំណោយម្ហូបរយមុខមានមនុស្សបំរើឆ្វេងស្តាំបំរើទាំងភេសជ្ជៈផង។ បរិភោគអាហារល្ងាចចប់ហើយ នៅមានទស្សនីភាពដោយក្រុម "សៀក"មកលេងក្នុងរោងល្ខោន នារាត្រីនោះដែរ... ហើយទាំងអស់នោះស្ថិតនៅក្នុងបរិវេណ "បាយ៉ាព្រិនស៊ីព"ទាំងអស់។ យប់នោះយើងនាំគ្នាសម្រាក ក្នុងបន្ទប់ត្រជាក់ មានក្លិនក្រអូបលុងលក់ក្នុងដំណេកយ៉ាងស្កប់ស្កល់មួយនារាត្រីពេញបូរមី បន្ទាប់ពីសកម្មភាពមួយថ្ងៃយ៉ាងពេញណែនមកលែងរវល់នឹងក្រុមតន្ត្រី ២វង់ទៀត **តទៅទំព័រទី ១០**







# ការវិភាគ

របស់ព្រះតេជព្រះគុណបណ្ឌិត ហុក សាវ័ណ្ណ

**ព្រះពុទ្ធសាសនានិងពិធីកម្ម**

ព្រះពុទ្ធសាសនាតែងមានពិធីកម្មក្នុងពេលបុណ្យទាន ដូចរៀបចំរោងបុណ្យ បើពិធីបុណ្យក្រៅពីវត្តហើយមានមនុស្សច្រើនចូលរួម។ ការដាក់បាត្រ នមស្ការព្រះរតនត្រ័យ សមាទានសីល ទេសនា វេរចង្ហាន់ ព្រះសង្ឃអ្នកទទួលតែងសូត្រធម៌អនុមោទា ជាដើម។ អត្ថន័យនៃពិធីកម្មនេះ គឺការសង់រោងបុណ្យនិងតាក់តែងលំអដើម្បីតម្រូវចំនួនមនុស្សដែលមកចូលរួមក្នុងពិធីបុណ្យ។ ការដាក់បាត្រដើម្បីគោរពដល់ការបញ្ញត្តិជាដំបូងរបស់ព្រះពុទ្ធដែលជាមូលបញ្ញត្តិថា បព្វជិត(អ្នកបួស) ត្រូវនិមន្តបិណ្ឌបាត្រអស់មួយជីវិត លុះក្រោយមកព្រះអង្គបញ្ញត្តិម្តងទៀតជាអនុបញ្ញត្តិថា បើមានគេប្រគេនចង្ហាន់ ទទួលចុះមិនបាច់បិណ្ឌបាត្រក៏បាន។ការនមស្ការព្រះរតនត្រ័យតែងសូត្រជាដំបូងនៅគ្រប់ពិធីកម្មដើម្បីគោរពដល់ព្រះពុទ្ធព្រះធម៌ព្រះសង្ឃជាអង្គនៃត្រៃសរណគមន៍។ ការសមាទានសីលមានសីល៥ជាដើមក៏ត្រូវទទួលគ្រប់ពិធីកម្មព្រោះធ្វើទានត្រូវមានសីលផង។ ការសំដែងធម៌ទេសនាចាត់ជាការសំខាន់ចាំបាច់ជាធម្មទាន សម្រាប់ពន្យល់បំភ្លឺធម៌អាថ៌ ជាពិសេសផលប្រយោជន៍នៃការធ្វើបុណ្យដែលកំពុងប្រព្រឹត្តទៅនេះ។ ការវេរចង្ហាន់ជាការប្រសើរមួយទៀត ចាត់ទុកជាសុន្ទរកថា ប្រគេនចង្ហាន់ដោយវាចាមុនប្រគេនដោយកាយ ហើយទូលព្រះសង្ឃថា ចង្ហាន់នេះ បានមកដោយធម៌ប្រកបដោយធម៌ កុំឲ្យព្រះសង្ឃសង្ស័យឆាន់ទៅត្រូវអាបត្តិ ហើយគេប្រាថ្នាឧទ្ទិសកុសលនេះដល់អ្នកដែលចែកស្ថានទៅ។ ព្រះសង្ឃសូត្រធម៌ជូនពរជាកិច្ចសំខាន់មួយទៀត ជាការលើកទឹកចិត្តអ្នកបំពេញកុសល ដោយការអនុមោទនាត្រេកអរឲ្យម្ចាស់បំពេញកុសលសម្រេចតាមប្រាថ្នានេះជាលក្ខណៈសុជីវធម៌។

នេះជាពិធីកម្មដ៏ល្អផូរផង់របស់ពុទ្ធសាសនាខ្មែរ បែរជាគណបក្សនយោបាយខ្មែរតូចមួយ ដែលគេស្គាល់ថាជាគណបក្សជេរព្រះសង្ឃថាអាចោរចង់យាម បាននិយាយរិះគន់ពិធីកម្មទាំងនេះ។ ទំនងជាយល់ច្រឡំគំនិតលោកគ្រូបង្រៀនវិបស្សនា១០ថ្ងៃម្នាក់ឈ្មោះលោកគ្រូ **ហ្គោឥនកា** ដែលពោលថា វិបស្សនានេះ មានលក្ខណៈជាធម្មជាតិ អាចឲ្យគ្រប់សាសនាគ្រប់ប្រពៃណីចូលមកពិសោធន៍បាន។ គំនិតបែបនេះរបស់គាត់បំណងទាញពួកអឺរ៉ុបឲ្យមកប្រតិបត្តិវិបស្សនា ពុំមែនគាត់បង្ខំគេឲ្យលះបង់សាសនាប្រពៃណីរបស់គេឡើយបែរជាគណបក្សតូចនេះរិះគន់ចង់រំលាយពិធីកម្មពុទ្ធសាសនាខ្មែរទៅវិញ។

វត្តខ្មែរកាណាដា,ថ្ងៃ២៦កុម្ភៈ២០១៦;www.hoksavann.org;savannhok@yahoo.com


**MARCOTTE LAW FIRM**

**ក្រុមហ៊ុនមេធាវី Marcotte**

45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីអន្តរាយដល់បុគ្គល
- សំណងបុគ្គល
- ពិការភាពដោយសន្តិសុខសង្គម
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បណ្តឹងវិវាទទូទៅ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍
- ច្បាប់ធានារ៉ាប់រង
- ការរំលោភបទព្រហ្មទណ្ឌ
- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅការដ្ឋាន
- បំណុលអចលទ្រព្យ

**មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទ**
**មកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ**

**(978) 458-1229**

**www.marcottelawfirm.com**


តមកពីទំព័រទី ០៩

## ទស្សនាប្រជុំកោះការ៉ាអ៊ីប...

ដែលគំពុងតែលេងភ្លេងកំដរភ្ញៀវនៅទីធ្លាខាងក្រៅនៅឡើយ ។

ស្អែកឡើង ព្រឹករបស់យើងផ្តើមនៅម៉ោង៩ មានកម្លាំងកំហែងគ្រប់គ្រាន់នឹងទៅចូលរួមអាហារពេលព្រឹកជុំគ្នានឹងភ្ញៀវរាប់រយនាក់ទៀត ដែលកំពុងរីករាយជាមួយក្រុមគ្រួសារតែរៀង១ខ្លួន ស្រស់ស្រូបម្ហូបចំណីព្រឹករបស់គេ បំរើដោយក្រុមអ្នកទទួលភ្ញៀវដែលរួសរាយជាទំនៀមទម្លាប់ទៅហើយ ។ តែភាពអស្ចារ្យបានបង្ហាញខ្លួនថែមទៀតដោយសារពន្លឺថ្ងៃនៃប្រទេស"ត្រូពីកាល់"នាំឱ្យយើងឃើញសួនច្បារដ៏ធំធេង រំលេចពណ៌ចម្រុះដូចផ្ទាំងគំនូរ លំអរដោយដើមដូង ដើមថ្នោត ឬដើមស្លា ជាសញ្ញានៃប្រទេសក្តៅនៅមិនឆ្ងាយពីសមុទ្រ។ វិចិត្រករបានបន្ថែម អាងហែលទឹកធំ១ សម្រាប់មនុស្សចាស់ អាងតូច១សម្រាប់ក្មេងតូចលេង ទឹកពណ៌ខៀវថ្លាឆ្វង់ ធ្វើឱ្យ"ទឹកមេឃ នឹងសមុទ្រ" នៅជាប់បន្តគ្នាយ៉ាងទូលំទូលាយ ។ ទេសភាពនៃសំណង់ផ្ទះរាប់សិបខ្នងរួមគ្នានឹងឧទ្យានត្រកាលមានមនុស្សធ្វើការទំនងជាដល់ពាន់នាក់ សម្រាប់ដំណើរការមណ្ឌល "បាយ៉ាព្រិនសីព"សម្រាប់បំពេញសេចក្តីត្រូវការរបស់ភ្ញៀវដែលមកពីគ្រប់តំបន់នៃសាកលលោក បានមកជួបនឹងក្តីស្រម័យរបស់គេនៅពេលមកដល់ភូមិសិប្បនិមិត្តនេះភ្លាម ។

យើងបាននិយាយពីខាងដើមបន្តិចហើយថា ប្រជុំកោះ"ការីប៊ីន"គឺជាគោលដៅដ៏ធំមួយនៃទេសចរពិភពលោក ដូចគ្នានឹងសៀមរាបអង្គរវត្តនៃប្រទេសកម្ពុជាដែរមានការផ្សព្វផ្សាយជាសាធារណនឹងទូលំទូលាយ របស់ប្រទេស "រេពូយប្លិក ឌូមីនីកែន" ទាំងមូល គឺសំដៅទៅរកមណ្ឌលភូមិសិប្បនិមិត្តដ៏ច្រើនកន្លែង ដូចគ្នានឹង"បាយ៉ាព្រិនស៊ិព" នោះជាដើម ។ **(នៅមានត)**





# "សប្តាហ៍សម្រាប់ក្មេងឡូវែល"

**ដោយ មូនីផល បឹង**

**បកប្រែពីភាសាអង់គ្លេសដោយ តារាយុទ្ធ ហង្ស**

**ឡូវែល**–សូមគិតម្តងទៀតបើសិនជាវិស្សមកាលខែកុម្ភៈជាពេលវេលាមួយសប្តាហ៍សំរាប់ក្មេងនៅតែផ្ទះ ហើយមើលវីដេអូតាមអ៊ីនធើណេតពេញមួយថ្ងៃតាមទូរស័ព្ទដៃរបស់ពួកគេ។ អង្គការមួយចំនួនមកពីទីក្រុងឡូវែលបានរៀបចំព្រឹត្តិការណ៍សប្តាហ៍ប្រចាំឆ្នាំរបស់ពួកគេដែលមានឈ្មោះថា "សប្តាហ៍សម្រាប់ក្មេងឡូវែល Lowell Kids Week" សំរាប់ក្រុមគ្រួសារ និងក្មេងៗឱ្យបានទទួលបទពិសោធន៍ពីសកម្មភាពសប្បាយៗពីតំបន់ដែលពួកគេរស់នៅ។ "កម្មវិធី"សាកល្បងនូវអ្វីថ្មី Try Something New"ត្រូវបានរៀបចំដោយ Lowell National Historical Park នៅថ្ងៃទី១៥ ខែកុម្ភៈ វេលាម៉ោង១១ព្រឹក ដល់ម៉ោងពាររសៀលនៅឯ"សារៈមន្ទីរោងចក្រតម្បាញ Boott Cotton Mills museum" ដែលបានអញ្ជើញប្រជាជនក្នុងតំបន់ ដើម្បីបង្កើតទំនាក់ទំនងជាមួយធនធានសហគមន៍ចែករំលែកភាពរំភើបជាមួយអ្នកជិតខាងក្នុងតំបន់ស្វែងរកអ្វីដែលថ្មីៗនៅជុំវិញសហគមន៍ឡូវែល ហើយ និងអនុញ្ញាតឱ្យក្មេងៗបានទទួលនៅភាពសប្បាយរីករាយពីសកម្មភាពអ្នកលក់តាមតូប។ ឪពុកម្តាយ និងក្មេងៗក៏បានចំណាយពេលវេលារបស់ពួកគេ ដើម្បីស្វែងយល់ពីសារមន្ទី និងបានរៀនពីប្រវត្តិសហគមន៍អំពីបដិវត្តិឧស្សាហកម្មប្រទេសអាមេរិកមូលធននិយម និងការងារពលកម្មរបស់ស្ត្រី។

លោក"គ្រីសស្តប់ផើរ ហាននឺរ Christopher Horner" ដែលលោកជាសមាជិកសេវាកម្មនៃ "មិលស៊ីទីគ្រោ Mill City Grow" បាននិយាយថា "ខ្ញុំមិនបានដឹងទេថា មានសារមន្ទីនៅទីក្រុងឡូវែលនេះទេ"។ "ហានឺរ"បានកើត និងធំដឹងក្តីនៅទីក្រុងឡូវែលគាត់សប្បាយចិត្តណាស់ដែលបានធ្វើការជួយដល់សហគមន៍របស់គាត់។ លោក "គូឡីអានា កាពូស៊ីអ៊ុល iana Cappucci" ក៏មកពី "មីលស៊ីទីគ្រោ" ហើយ និងធំដឹងក្តីនៅទីក្រុងតូចមួយជិតទីក្រុង"ខេបខត Cape Cod" បាននិយាយថា ព្រឹត្តិការណ៍នេះ បានផ្តល់បរិយាកាសដ៏មានផាសុខភាព និងអ្នកលក់តាមតូបជាច្រើនបានធ្វើការជាមួយឪពុកម្តាយនិងក្មេងៗយ៉ាងល្អ។ "ខ្ញុំមិនដែលបានចូលរួមព្រឹត្តិការណ៍ដែលនាំឱ្យក្មេងៗបានមកលេងជាមួយគ្នានៅថ្ងៃវិស្សមកាលរបស់ពួកគេទេ" លោក"កាពូស៊ី"បានមានប្រសាសន៍ថា "ខ្ញុំសប្បាយចិត្តដែលបានមកទីនេះ"។ សកម្មភាពរបស់ពួកគេគឺធ្វើឱ្យប្រជាជនក្នុងតំបន់បានសាកនៅសាឡាដគំរូដោយមិនគិតថ្លៃរបស់ពួកគេជាមួយ "កាលេស កាលសេ"ការ៉ុត ផ្លែប៉ោម ខ្ទឹមបារាំង គ្រាប់ល្ពៅ ទឹកឃ្មុំ និងទឹកខ្មេះ។ គ្រឿងផ្សំ ត្រូវបានដាំជាលក្ខណៈធម្មជាតិនៅឯចំការរបស់ពួកគេផ្ទាល់ ហើយគ្រឿងផ្សំផ្សេងទៀតគឺបានទិញមកពីផ្សារក្នុងតំបន់។

ឪពុកម្តាយនិងក្មេងៗដែលទើបនឹងផ្លាស់មកនៅទីក្រុងឡូវែលឬបានរស់នៅទីក្រុងនេះពេញមួយជីវិតពួកគេ មិនបានរំពឹងថានឹងមានសកម្មភាពខុសប្លែកដែលនឹងកើតមានទេនៅទីនេះទេ។ "ខ្ញុំមិនបានដឹងថា មានកម្មវិធីពីសកម្មភាពផ្សេងៗនៅក្នុងទីក្រុងទេ" អ្នកស្រី "អេព្រៀលស្តារ April Starr"បាននិយាយថា អ្នកស្រីជាប្រជាជនម្នាក់នៅទីក្រុងឡូវែល ហើយបានរស់នៅទីនេះជាមួយនឹងកូនៗដែលពួកគេទទួលការរៀនសូត្រនៅឯសាលានៅផ្ទះ។ មិនថាក្មេងៗលេងប៊ូលីង ឬធ្វើ សិល្បៈ និងសិប្បកម្មឪពុក

**តទៅទំព័រទី ២៣**

# "Lowell Kids Week"

**By Moniphal Bing**

**LOWELL** -- If February school vacation is a week for kids to stay home and watch online videos all day long from their mobile device, think again. Several organizations from the city of Lowellhave



been coordinating their annual week event called Lowell Kids Week, for family and children to experience fun activities around the local areas. "Try Something New," hosted by Lowell National Historical Park on Feb 15, 11 a.m. to 3 p.m. at Boott Cotton Mills Museum, invited local residents to make connection with community resources, sharing the excitement with other local neighbors, exploring new things around the Lowell community, and allowing their kids to enjoy the activities from booth vendors. Parents and children had also take the time to explore the museum and learned the community history about the American industrial revolution, capitalism, and women's work labors.

"I didn't know there was a museum here in Lowell," said Christopher Horner, Service Member of Mill City Grow. Horne was born and raised here in Lowell, and he is happy to work for his community.GuilianaCappucci, also from Mill City Grow and raised in the small town near Cape Cod, said how this event is a relaxing atmosphere and many booth vendors enjoyed working with parents and kids. "I'd never been to an event that provide kids to get together during their school vacation," said Cappuci. "I'm happy to be here." Their activity was to have the local community--trying out their free sample salads with a mixture of kales, carrots, apples, onions, pumpkin seeds, honey, and vinegar. Some of the ingredients were grow organically from their farms, and some were gathered from their local markets.

Parents and children who have recently moved to Lowell or have been living in Lowell their entire life didn't expect the different activities happening here in this community. "I didn't know there are some activities here in downtown," said April Starr, one of the Lowell resident who lived in downtown and a mother with kids who are currently taking homeschool. Whether kids played bowling or done arts and crafts, some parents and booth vendors explained how children are engaged to the activities, but doesn't comprehend the purposes of the resources itself.

"Children are not here to understand about the community organization, but rather experience the fun activities from them," said Leslie Wong, one of the Lowell resident and a mother with kids. She explained how organizations are here to take the opportunity to get some connections with each other.

"Lots of people doesn't know the resources here in this community, and how there are many opportunities for kids to get involved," said Aurora Erickson, Program Coordinator of the Coalition for a Better Acre. Their activity booth had children or parents to write or draw something on two separated posters about what they like or dislike about their neighborhood. Erickson loves working with kids from different neighborhood, and it is meaningful for her to see a diverse community to come together in this event.

Lowell Kids Week's lasted from Feb 14th to Feb 20th. The next Lowell Kids Week will begin on April school vacation.Schedule will be posted soon.





# បន្តផលិតខ្សែភាពយន្តរឿង“ដំបូងគេសំលាប់ឪពុករបស់ខ្ញុំ”

**ដកស្រង់ពី** sltrib.com -

**ប្រែសំរួលដោយៈ តារាយុទ្ធ ហង្ស**

**បាត់ដំបងប្រទេសកម្ពុជាៈ** អ្នកស្រី អេនចូលីនាចូលីភីត (Angelina jolie Pitt) បានមានប្រសាសន៍ថា "កាលពីអតីតកាលភាពច្របូកច្របល់នៃប្រទេសនេះបានផ្លាស់ប្តូរជីវិតរបស់នាង"។ អ្នកស្រីអេនចូលីនាចូលីភីតធ្លាប់មកកាន់ព្រះរាជាណាចក្រកម្ពុជាកាលពី១៦ឆ្នាំមុនដើម្បីសំដែងនូវខ្សែភាពយន្ត"ថមរាយដឺ (Tomb RaiderLara Croft)"។ ប៉ុន្តែឥលូវនេះនាងបានត្រលប់មកវិញម្តងទៀតក្នុងនាមជាចាងហ្វាង ដើម្បីដឹកនាំសំដែងនូវរឿងថ្មីមួយខុសឆ្ងាយពីរឿងចាស់ដែលនាងបានដើរជាតួសំដែង។

"ដំបូងគេសំលាប់ឪពុករបស់ខ្ញុំ (First They Killed My Father)" គឺចាប់ផ្តើមថតដោយយកទៅតាមសៀវភៅដែលនិពន្ធដោយឡុងអ៊ឹង (Loung Ung) ដែលប្រើនូវទស្សនះវិស័យរបស់គាត់កាលពីវ័យកុមារភាពក្នុងកំឡុងពេលរបបប្រល័យពូជសាសន៍ខ្មែរក្រហម នាឆ្នាំ១៩៧០ ដើម្បីបង្កើតបានជាសៀវភៅនេះឡើង។ ខ្សែភាពយន្តនេះ





នឹងត្រូវគេបានចាក់បញ្ចាំងលើ នេតផ្លិច (Netflix) ជាភាសាខ្មែរដោយមានតួអង្គជាជនជាតិកម្ពុជា ហើយបើយោងទៅតាម ចូលលីភីត ខ្សែភាពយន្តនេះគឺជារឿងដ៏សំខាន់បំផុតក្នុងជីវិតរបស់នាង។

ចូលលីភីត ក៏បានបន្ថែមទៀតថា "នៅពេលដែលខ្ញុំបានមកដល់ប្រទេសកម្ពុជាដំបូងវាបានផ្លាស់ប្តូរខ្ញុំ។ វាបានផ្លាស់ប្តូរទស្សនះរបស់ខ្ញុំ។ ខ្ញុំបានដឹងថាមានប្រវត្តិសាស្រ្តជាច្រើន ដែលខ្ញុំមិនត្រូវបានគេបង្រៀននៅសាលារៀននិងមេរៀនអំពីឆាកជីវិតដ៏ទៃទៀត ដែលខ្ញុំត្រូវយល់ទេ ហើយខ្ញុំពិតជារំជួលក្នុងចិត្តណាស់ដោយសារវា"

អ្នកផលិតខ្សែភាពយន្តដែលល្បីបំផុតរបស់ប្រទេសកម្ពុជាលោកប៉ានរិទ្ធី បាននិយាយថារឿង "ដំបូងពួកគេសម្លាប់ឪពុករបស់ខ្ញុំ" នឹងក្លាយជាវីរភាពខ្សែភាពយន្តហូលីវូដដំបូងដែលបានថតនៅក្នុងប្រទេសកម្ពុជាអំពីអំពើប្រល័យពូជសាសន៍របស់ប្រទេសនេះ បានមានប្រសាសន៍ថា " ចំណង់ចំណូលចិត្តរបស់នាង(ចូលលីភីត)សំរាប់ប្រទេសកម្ពុជាគឺជាការយកចិត្តទុកដាក់គ្នាទៅវិញទៅមក។ "នាងរំពឹងថានឹងវិលត្រឡប់មកឱ្យទាន់នូវការបញ្ចាំងខ្សែភាពយន្តនេះនៅក្នុងប្រទេសកម្ពុជានាចុងឆ្នាំ២០១៦នេះ មុនពេលដាក់រឿងនេះបញ្ចាំងនៅក្នុងក្រុមហ៊ុន Netflix Inc ៕

# ក្រុមសិល្បៈ១៩៧៥

**By Moniphal Bing**

**បកប្រែដោយ ៖ តារាយុទ្ធ ហង្ស**

ដោយមានការជំលាសជនស៊ីវិលនៅក្នុងទីក្រុងភ្នំពេញនឹងមានការសំលាប់នូវជនស្លូតត្រង់អំឡុងពេលរបបខ្មែរក្រហមសមាជិកគ្រួសារដែលបាក់បែកគ្នា នឹងរស់នៅក្នុងជំរុំជនភៀសខ្លួន នៅឯប្រទេសថៃបានខ្លាយទៅជាការជំរុញទឹកចិត្តទៅដល់ក្រុមសិល្បៈ ហៅថា "១៩៧៥"។ បដិសណ្ឋារកិច្ចមួយបានចាប់ផ្តើមនៅថ្ងៃ ទី១១ ខែកុម្ភៈ ដែលធ្វើឡើងដោយនាយកដ្ឋានសិល្បៈ ច្នៃប្រឌិតសាលាសកលវិទ្យាល័យញ៉ូម៉ាសឡូវែល (UML) នឹងមជ្ឈមណ្ឌលសំរាប់ការសិក្សារបស់អាស៊ីអាមេរិកាំងនឹងការបង្ហាញនូវសិល្បៈសហសម័យ នៅឯបន្ទប់បណ្ណាល័យ អូល្សើរី លេខ២២២ (O’Leary Library Room 222) ដោយ អាមី លី សាន់វ៉ដ (Amy Lee Sanford) លីនដា សាផាន់ (LinDa Saphan) នឹង អានីដា យូ អាលី (AnidaYoeu Ali) ជាសិល្បៈករ។

មិនដូចជាសិល្បៈប្រពៃណីរបស់កម្ពុជាដែលត្រូវបានដាក់កម្រិតទៅលក្ខណៈពិសេសនៃវប្បធម៌របស់ខ្លួនទេ សិល្បៈរបស់វិចិត្រករស្រ្តីទាំងបីនាក់គឺបានបង្ហាញនូវស្នាដៃសិល្បៈសហសម័យនិងការសម្តែងដែលមើលឃើញដែលមានប្រធានបទទាក់ទងទៅនឹងបញ្ហាបន្ទាន់នៃសង្រ្គាមការចងចាំការភៀសខ្លួន និងសកលភាវូបនីយកម្ម។ គោលដៅនៃស្នាដៃសិល្បៈ និងការសំដែងរបាំនេះ គឺដើម្បីអនុញ្ញាតឱ្យអ្នកទស្សនារបស់ពួកគេធ្វើការវិភាគលម្អិតទៅលើការសំដែងទាំងអស់នេះ បន្ថែមពីនេះទៅទៀតការសំដែងនេះគឺផ្តោតទៅលើបញ្ហាបន្ទាប់ពីមានការបញ្ចប់សង្រ្គាម។

ក្នុងអំឡុងពេលពិភាក្សាជាមួយ និងសាស្រ្តាចារ្យនិស្សិតសាកលវិទ្យាល័យ និងទស្សនិកជនក្នុង




ស្រុក"សាន់វ័ត"បង្ហាញការសម្តែងស្នាដៃសិល្បៈរបស់នាងដោយបំបែកសន្លឹកនៃកញ្ចក់ហើយដាក់ពួកវាត្រឡប់មកវិញជាមួយគ្នា។ "សាន់វ័ត"បានឱ្យដឹងថា "នេះគឺជាការឆ្លុះបញ្ចាំងនៃបំណែកគំនិតដែលបង្ហាញពីព័ត៌មានផ្សេងគ្នាដែលលាក់នូវអត្ថន័យដ៏មានន័យ នាងបន្ថែមថា "មើលរបស់នៅថ្ងៃផ្សេង"។

សាផាន់ បានបកស្រាយថា "ដំបូងឡើយ ការ

**តទៅទំព័រទី២២**

# 1975 Group Exhibition of Diasporic cambodia Art

**By Moniphal Bing**

LOWELL- Evacuating the civilians in Phnom Penh and executing million innocent victims during the KR period, separating family members and living in the refugee camps in Thailand has become an inspiration to a group of artists called 1975.When the reception and panel discussion began on Thursday Feb. 11th, hosted by the UML Department of Art & Design and the Center for Asian American Studies, Amy Lee Sanford, LinDaSaphan, and AnidaYoeu Alishowcase their contemporary artworks at the O'Leary Library Room 222.

Unlike traditional Cambodian art that is restricted to its cultural features, these three women artistshave been displaying contemporary artworks and visual performances subjectively to expose the urgent issue of war, memory, displacement, and globalization.The goal of their artworks and performances is to allow their spectators to critically analyze the details with a combination of abstraction and contemporary issues. Additionally, the messages parallel to the aftermath of the war.

During the discussion panels with university students, professors, and local audiences, Sanford presented her performing artwork by breaking sheets of glass and put them back together. "This is the reflection of the moments of time - fragment ideas present different kind of information and hidden meaning," said Sanford. "Looking things in different days."

Saphan explained about her drawings on rice paper, originally used for consumption such as Spring Roll, depicted vernacular apartment buildings and architectural monuments in the current day of Phnom Penh with a combination of barred wires and fences overlapping the artwork. Having images depicted like prison cells, shewanted to pay tribute to the victims who were forced to leave home by the anti-capitalist KR.

Ali also presented her performing artwork from her still-frame video calledThe Buddhist Bug. Although she is a Muslim Khmer woman, her absurdity and humorous costume as a giant orange caterpillar, **Continued to Page 22**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ព្រះអង្គម្ចាស់ក្សត្រីយ៍ថៃយាងទៅកាន់ខេត្តរតនគិរីដើម្បីចូលរួមពិធីសម្ពោធមណ្ឌលសុខភាព

**ដោយឃី សុវុឌ្ឍី ឮ** February 23, 2016

ព្រះអង្គម្ចាស់ក្សត្រីយ៍ថៃ មហាចក្រីសិរិន្ធថន បានយាងចេញពីរាជធានីភ្នំពេញទៅកាន់ខេត្តរតនគិរីនិងយាងទៅជាថ្មីម្តងទៀតកាលពីម្សិលមិញដោយទ្រង់សោយព្រះក្រយាថ្ងៃត្រង់ក្បែរមាត់បឹង និងយាងចូលរួមសម្ពោធមណ្ឌលសុខភាពនៅថ្ងៃដំបូងនៃព្រះរាជដំណើរបំពេញទស្សនកិច្ចរយៈពេលបីថ្ងៃមកកាន់ប្រទេសកម្ពុជា។

បន្ទាប់ពីជួបពិភាក្សាការងាររយៈពេលមួយម៉ោងជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅអគារការិយាល័យរបស់លោកព្រះអង្គម្ចាស់ក្សត្រីយ៍ សិរិន្ធថន បានយាងតាមឧទ្ធម្ភាគចក្រទៅកាន់បឹងយក្ខឡោមដ៏ពេញនិយមស្ថិតក្នុងក្រុងបានលុងទីដែលបង្គន់អនាម័យដ៏ទំនើបមួយត្រូវបានសាងសង់តាមសំណើរបស់ព្រះអង្គ ហើយតាមការប៉ាន់ប្រមាណគឺចំណាយទឹកប្រាក់អស់ចំនួនជាង៤០.០០០ដុល្លារ។ ប៉ុន្តែព្រះអង្គម្ចាស់ក្សត្រីយ៍អង្គនេះមិនបានប្រើប្រាស់បង្គន់អនាម័យនេះឡើយអំឡុងដំណើរឈប់សំចតរយៈពេលខ្លីរបស់ព្រះអង្គ។

លោក ញ៉ែម សំអឿន អភិបាលរងខេត្តបានមានប្រសាសន៍ថា "ព្រះអង្គម្ចាស់ក្សត្រីយ៍មិនបានប្រើបង្គន់អនាម័យនេះទេ...ប៉ុន្តែព្រះអង្គបានយាងទៅទតបង្គន់អនាម័យនេះ។ នៅពេលព្រះអង្គយាងត្រឡប់ទៅរាជធានីភ្នំពេញវិញ ពួកគេបានរុះបង្គន់អនាម័យដ៏ទំនើបនេះ"។

បង្គន់អនាម័យដែលសាងសង់ឡើងប្រើពេល ១៩ថ្ងៃដោយកម្មករថៃមួយក្រុមដែលជួលដោយក្រុមហ៊ុន Siam Cement Group (SCG) មានមូលដ្ឋាននៅទីក្រុងបាងកកបានធ្វើឱ្យអន្តរជាតិបានការចាប់អារម្មណ៍កាលពីចុងសប្តាហ៍។ នៅក្នុងបទសម្ភាសន៍កាលពីថ្ងៃសុក្រលោក Andrew MacGregor បានចាត់ទុកសំណង់នេះថាជា "ការប្រមាថដល់ពលរដ្ឋកម្ពុជា"។ លោក សំអឿន បានថ្លែងថា ដោយមិនមានបង្គន់អនាម័យអគារទំហំ៨ម៉ែត្រក្រឡានេះនឹងត្រូវទុកឱ្យសហគមន៍យក្ខឡោមប្រើប្រាស់។

យោងតាមលោក ប៉ាក់ សុន អភិបាលខណ្ឌបានឱ្យដឹងថា ខណៈពេលស្ថិតនៅក្នុងខេត្តរតនគិរី ព្រះអង្គម្ចាស់ក្សត្រីយ៍បានយាងចូលរួមជាអធិបតីក្នុងពិធីកាត់ខ្សែបូសម្ពោធមណ្ឌលសុខភាពសាធារណៈមួយក្នុងសង្កាត់អូរជុំដែលជាព្រះរាជអំណោយរបស់ព្រះរាជវង្សថៃ។

លោកបានថ្លែងថា "ឥឡូវនេះ ប្រជាពលរដ្ឋរស់នៅក្បែរមណ្ឌលសុខភាពនោះអាចទៅរកសេវាសុខាភិបាលបានដោយស្រួល"។

យោងតាមលោក អ៊ុង រតនា ប្រធានមន្ទីរសុខាភិបាលខេត្តបានឱ្យដឹងថា មណ្ឌលសុខភាពនេះត្រូវបានសាងសង់កាលពីឆ្នាំមុន និងចំណាយទឹកប្រាក់អស់ជាង២៦០.០០០ដុល្លារ ហើយមានគិលានុបដ្ឋាក៦នាក់ និងបុគ្គលិកគាំពារសុខភាពផ្សេងទៀត"។

លោក កៅ គឹមហួន រដ្ឋមន្ត្រីអមនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា ក្នុងរយៈពេលពីរថ្ងៃក្រោយ



ព្រះអង្គម្ចាស់ក្សត្រីយ៍ មហាចក្រី សិរិន្ធថន យាងពីមុខលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្រោយពីជួបប្រជុំនៅឯការិយាល័យលោកនាយករដ្ឋមន្ត្រីក្នុងក្រុងភ្នំពេញ កាលពីម្សិលមិញ។
រូបថតៈ ស៊ីវ ចាន់ណា, The Cambodia Daily

ព្រះអង្គម្ចាស់ក្សត្រីយ៍ សិរិន្ធថន នឹងយាងទៅពិនិត្យមើលគម្រោងទាក់ទងនឹងចំណាប់អារម្មណ៍របស់ព្រះអង្គគឺបច្ចេកវិទ្យា។

លោកបានថ្លែងថា ព្រះអង្គម្ចាស់ក្សត្រីយ៍នឹងយាងចូលរួមបើកការដ្ឋានសាងសង់វិទ្យាស្ថានបច្ចេកវិទ្យានៅខេត្តកំពង់ស្ពឺដែលក៏ជាព្រះរាជអំណោយរបស់ព្រះរាជវង្សថៃផងដែរនៅថ្ងៃអង្គារ និងយាងទៅកាន់វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាលក្នុងខេត្តកំពង់ធំនៅថ្ងៃពុធ។

លោក កៅ គឹមហួន បានថ្លែងថា អំឡុងជំនួបជាមួយព្រះអង្គម្ចាស់ក្សត្រីយ៍កាលពីព្រឹកម្សិលមិញ លោក ហ៊ុន សែន បានថ្លែងអំណរគុណដល់ព្រះអង្គម្ចាស់ក្សត្រីយ៍ចំពោះការរួមចំណែកជួយដល់វិស័យអប់រំ និងសុខាភិបាលនៅកម្ពុជា។

លោកបានមានប្រសាសន៍ថា "លោក ហ៊ុន សែន បានថ្លែងអំណរគុណដល់ព្រះអង្គម្ចាស់ក្សត្រីយ៍ចំពោះការរួមចំណែកជួយដល់វិស័យអប់រំ និងសុខាភិបាលជាពិសេសទាក់ទងវិទ្យាស្ថានបច្ចេកវិទ្យា"៕ **សារុន**

# THAI PRINCESS HELICOPTERS TO RATANAKKIRI, INSPECTS BATHROOM

**by KhySovuthy | February 23, 2016**

Thai Princess MahaChakriSirindhorn flew from Phnom Penh to Ratanakkiri province and back again on Monday, alighting for a lakeside lunch and the opening of a health center on the first day of her three-day visit to the country.

Following an hourlong meeting with Prime Minister Hun Sen at his office building, Princess Sirindhorn flew by hel-icopter to the popular Yeak Lom Lake in Banlung City, where a luxurious outhouse had been constructed at her request-and at an estimated cost of more than $40,000.

The princess, however, did not make use of the bathroom during her brief sojourn.

"She did not use the toilet…but she went to see the bathroom," said deputy provincial governor Nhem Sam Oeun. "When she went back to Phnom Penh, they removed the modern toilet."

The bathroom, which was built over the course of 19 days by a team of Thai laborers hired by the Bangkok-based Siam Cement Group (SCG), made inter-national head-lines over the weekend. In an interview on Friday, author Andrew MacGregor Marshall described the structure as "an insult to the Cambodian people."

Absent its toilet, Mr. Sam Oeun said, the 8-square-meter building would be put to other use by the Yeak Lom community.

While in Ratanakkiri, the princess presided over a ribbon-cutting ceremony for a public health center in O'Chum district that had been donated by the Thai royal fam-ily, according to district governor Pak Son.

"Now, the people who live near the health center can enjoy easy access to health services," he said.

The center was constructed last year at a cost of more than $260,000 and would be staffed by six "nurses and other health care professionals," said Ung Rattana, director of the provincial health department.

Kao Kim Huorn, a minister attached to the prime minister, said that over the next two days, Princess Sirindhorn would pay visits to projects related to her area of interest: technology. He said she would attend a groundbreaking ceremony for the KompongSpeu Institute of Technology-also donated by the Thai royal family-today and tour the KompongChheuteal Technology Institute in Kompong Thom province on Wednesday.

Mr. Kim Huorn said that during his meeting with the princess on Monday morning, Mr. Hun Sen thanked the princess for her contributions to health and education in Cambodia.

"Samdech Prime Minister Hun Sen thanked her for helping in the education and health sectors, especially related to technology institutes," he said.



ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# លោក ហ៊ុន សែន រិះគន់រដ្ឋមន្ត្រីមួយចំនួន និងជំរុញឱ្យគណៈរដ្ឋមន្ត្រីដុសក្អែល

**ដោយឃួន ណារិម** | **February 26, 2016**

ដោយគណបក្សប្រជាជនកម្ពុជាកំពុងខិតខំប្រឹងប្រែងធ្វើឱ្យសេវាកម្មរដ្ឋកាន់តែប្រសើរឡើង និងធ្វើកំណែទម្រង់សំខាន់ៗមួយចំនួននៅមុនការបោះឆ្នោតឃុំ-សង្កាត់នៅឆ្នាំក្រោយនោះ កាលពីម្សិលមិញលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាឱ្យរដ្ឋមន្ត្រីពីររូបក្នុងចំណោមរដ្ឋមន្ត្រីទាំងអស់ធ្វើការងាររបស់ខ្លួនឱ្យបានល្អប្រសើរបើមិនដូច្នោះទេប្រឈមនឹងការបណ្តេញចេញ។

ថ្លែងនៅសន្និបាតបូកសរុបការងារប្រចាំឆ្នាំនៅក្រសួងមហាផ្ទៃក្នុងរាជធានីភ្នំពេញ លោកកុំទៅខ្វល់ពីក្រសួងសាធារណការ។ ធ្វើខ្លួនឯងទៅ"។

បើទោះជាលោក ហ៊ុន សែន ប្រើពាក្យសម្តីធ្ងន់ៗទៅលើលោក ត្រាំ អ៊ីវតឹក ក៏ដោយក៏លោកលើកឡើងថា លោក អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងកសិកម្មស្ទើរតែអន់ដូចគ្នាដែរ។

លោកបានមានប្រសាសន៍ថា "ថ្ងៃមិញស៊ីបាយថ្ងៃត្រង់ខ្ញុំរាប់ចំណាត់ថ្នាក់ក្រសួងណាស្ថិតក្នុងចំណាត់ថ្នាក់ A, B, C ដល់ S អា F ហ្នឹងគឺក្រសួងសាធារណការហ្នឹងតែម្តងហើយដោយទាំងអ៊ុក រ៉ាប៊ុន មួយទៀត។ ក្រសួងកសិកម្មចូលក្នុង




លោកបានថ្លែងថា "ខ្ញុំដូចជាមិនដឹងថា ម៉េចទេ ក្រសួងសាធារណការ គឺជាក្រសួងដែលស្ពុយជាងគេបំផុត ។ស្ពុយណាស់ អាហ្នឹងនិយាយឱ្យពិត"។

ហ៊ុន សែន បានមានប្រសាសន៍ថា លោកនឹងពិចារណាផ្លាស់ប្តូរគណៈរដ្ឋមន្ត្រីនៅពេលឆាប់ៗហើយចាប់ផ្តើមដាក់ចំណាត់ថ្នាក់ជាសាធារណៈអំពីការការអនុវត្តការងាររបស់ក្រសួងនានា។ លោកបានរិះគន់ចំៗដល់លោក ត្រាំ អ៊ីវតឹក រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

លោក ហ៊ុន សែន បានលើកឡើងពីកិច្ចប្រជុំគណៈរដ្ឋមន្ត្រីកាលពីពេលថ្មីៗនេះ ដែលអំឡុងកិច្ចប្រជុំនេះ លោក ត្រាំ អ៊ីវតឹក បានរុញដាក់គ្នាជាមួយលោក ប៉ា សុជាតិវង្ស អភិបាលរាជធានីភ្នំពេញជុំវិញអ្នកដែលទទួលខុសត្រូវចំពោះការថែទាំផ្លូវក្នុងរាជធានី។

លោកបានបន្ថែមថា "ក្រសួងហ្នឹងមួយមិនធ្វើការតែម្តង។ ការបន្ទោសគ្នាទៅវិញទៅមកអំពីផ្លូវក្នុងរាជធានីនៅកិច្ចប្រជុំនៅទីស្តីការគណៈរដ្ឋមន្ត្រីថា ផ្លូវណាក្រសួងសាធារណការទទួលខុសត្រូវ ហើយផ្លូវណាសាលារាជធានីទទួលខុសត្រូវ។ លោក ប៉ា សុជាតិវង្ស បាននិយាយថា F ហើយយើងឃើតពេកស្ទក់ពេក"។ លោកបន្ថែមថា "ខ្ញុំគិតថា ខ្ញុំនឹងប្រកាសអំពីចំណាត់ថ្នាក់របស់ក្រសួងទាំងនេះគឺក្រសួងលេខ១ ក្រសួងលេខ២ ក្រសួងលេខ៣...។ ប្រសិនបើខ្ញុំមិនប្រកាសដូច្នេះទេ វានឹងប៉ះពាល់ដល់ការងាររបស់ខ្ញុំ"។

បន្ទាប់ពីគណបក្សប្រជាជនកម្ពុជាស្ទើរតែចាញ់គណបក្សសង្គ្រោះជាតិ ដែលមានកម្មវិធីនយោបាយសន្យាធ្វើកំណែទម្រង់ស្ថាប័នសំខាន់នៅក្នុងការបោះឆ្នោតជាតិក្នុងឆ្នាំ២០១៣នោះ លោក ហ៊ុន សែន បាននិយាយរយៈពេល៦ម៉ោងកន្លះជំរុញឱ្យមន្ត្រីជាន់ខ្ពស់របស់ខ្លួនរៀបចំខ្លួនដោយប្រើពាក្យថា ត្រូវដុះក្អែលតែម្តង។

លោកបាននិយាយនៅពេលនោះថា "ទី១ អស់លោកត្រូវយកកញ្ចក់ឆ្លុះមើលខ្លួនឯង។ ទី២ អស់លោកត្រូវមុជទឹកដុសក្អែល។ ទី៣អស់លោកត្រូវដុសក្អែលផងនៅពេលកំពុងមុជទឹក។ ទី៤ អស់លោកត្រូវដល់ពេលព្យាបាលជំងឺរបស់ខ្លួនហើយ"។

កាលពីម្សិលមិញលោក ហ៊ុន សែន បានថ្លែងថា រដ្ឋមន្ត្រីមួយចំនួនមិនទាន់បានព្យាបាលជំងឺខ្លួនឯងនៅឡើយទេ។ លោកបានថ្លែងថា "យើងទុកពេលឱ្យប៉ុន្មានឆ្នាំមកហើយឱ្យមុជទឹកដុសក្អែលឆ្លុះកញ្ចក់។ ឥឡូវនេះដល់ពេលត្រូវព្យាបាលជំងឺហើយ"។

លោកបានបន្ថែមថា "ខ្ញុំគិតថា តើខ្ញុំនឹងដោះដូរគណៈរដ្ឋមន្ត្រីនៅក្នុងឆ្នាំនេះ ឬទេ។ ខ្ញុំគិតថា បើទុកម្លឹងៗ មិនកើតទេ វាងាប់ឯខ្ញុំ"។

ដោយប្រើវោហារស័ព្ទខ្មែរដែលសំដៅដល់មិត្តភក្តិនិយម លោកបានថ្លែងថា "អាពាក្យគ្នាឯងៗហ្នឹង វាគ្រោះថ្នាក់ដល់ខ្លួនឯងទៀត"៕

**សារុន**

# HUN SEN BLASTS MINISTERS, THREATENS RESHUFFLE

**byKhuonNarim | February 26, 2016**

With the ruling CPP in the midst of an effort to improve public services and implement key reforms ahead of next year's commune elections, Prime Minister Hun Sen on Thursday ordered two of his cabinet ministers to improve their work or risk being sacked.

Speaking at the annual meeting of the Interior Ministry in Phnom Penh, Mr. Hun Sen said he would consider reshuffling his cabinet soon and begin issuing public rankings of ministries' performance. He singled out Public Works Minister Tram IvTek for a particularly blistering critique.

"I don't know how to say this, but the Ministry of Public Works is a ministry that is much slower than other ministries," he said. "Very slow. This is the truth."

Mr. Hun Sen cited a recent cabinet meeting during which Mr. IvTek apparently sparred with Phnom Penh municipal governor Pa Socheatvong over who was re-sponsible for maintaining the city's roads.

"This ministry does not work. To blame each other about city roads at a Council of Ministers meeting, which roads Public Works is responsible for and which roads City Hall is responsible for? Pa Socheatvong: Don't care about the Minis-try of Public Works. Please do it yourself."

Although Mr. Hun Sen reserved his harshest words for Mr. IvTek, he said Agriculture Minister Ouk Rabun was nearly as bad.

"Today, when I was having lunch, I ranked the ministries from A, B, C to F, and F is the Ministry of Public Works, as well as Ouk Rabun. The Ministry of Agriculture reaches rank F-very slow," he said.

"I think I will announce the ministries' rankings-number 1, 2 and 3…. If I don't announce it in this way, it won't affect their work," he added.

After the CPP nearly lost the 2013 national election to an insurgent CNRP, which ran on a platform promising extensive institutional reform, Mr. Hun Sen gave a six-hour speech exhorting his top officials to prepare for increased public scrutiny, using the metaphor of a person taking a bath.

"First, you need to use a mirror to look at yourself. Second, you have to take a bath to clean your body. Third, you have to scrub your body while bathing if it is plagued by dirty things. Fourth, you have to heal your disease," he said at the time.

On Thursday, he said that some ministers had not yet managed to heal themselves.

"[We] gave them several years to take a bath, look in the mirror and clean their bodies. Now is the time to treat the disease," he said.

"I am wondering whether I should reshuffle the cabinet this year or not. I am wondering because if we keep too many like this, it will make me die."

"Friends among friends are dangerous to me," he said, using a Khmer expression that refers to cronyism.

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ផែនការដ៏ចម្រូងចម្រាសលក់ដីស្រះទឹកវត្ត ត្រូវបោះបង់ចោល

**ដោយ បែន សុខហ៊ាន** | March 1, 2016

កាលពីម្សិលមិញ អភិបាលរងខណ្ឌពោធិ៍សែនជ័យក្នុងក្រុងភ្នំពេញបានបញ្ចប់ភ្លាមៗនូវផែនការរបស់ព្រះចៅអធិការវត្តលក់ដីស្រះទឹកមួយតម្លៃ ៤.៨លានដុល្លារ ដែលពាក្យចចាមអារ៉ាមអំពីផែនការនេះបានបង្កឱ្យមានការតវ៉ាជាច្រើនថ្ងៃពីសំណាក់អ្នកភូមិដែលផ្ទុះកំហឹង។

ប្រជាពលរដ្ឋនៅសង្កាត់ចោមចៅពឹងផ្អែកលើទឹកស្រះទំហំ៣ហិកតាដើម្បីដាំបន្លែបង្កា និងបន់ស្រន់ដល់អ្នកថែរក្សាស្រះទឹកនៅទីសក្ការមួយកន្លែងដែលនៅចម្ងាយពីរបីរយម៉ែត្រពីវត្តគោកបញ្ចាន់។ អ្នកភូមិរាប់រយនាក់បាននឹងកំពុងតវ៉ានៅខាងក្រៅវត្តនោះតាំងតែពីថ្ងៃសៅរ៍មក បន្ទាប់ពីមានការប្រជុំមួយរវាងព្រះចៅអធិការវត្តព្រះនាម សេង ថន និងក្រុមមន្ត្រីមូលដ្ឋានកាលពីថ្ងៃពុធដើម្បីពិភាក្សាការលក់ស្រះទឹកនេះតម្លៃ១៦០ ដុល្លារក្នុងមួយម៉ែត្រក្រឡា។

អំឡុងកិច្ចប្រជុំរយៈពេល៤ម៉ោងនៅវត្តនោះកាលពីម្សិលមិញ អភិបាលរងខណ្ឌលោក ឃឹម ស៊ុនសូដា បានមានប្រសាសន៍ថា មិនមានការយល់ព្រមឱ្យលក់ទេ ដើម្បីបំពេញតាមការទាមទាររបស់ប្រជាជន។

លោក ស៊ុនសូដា បានសួរព្រះចៅអធិការវត្តថា "យើងព្រមព្រៀងមិនលក់វាទេ ហើយរក្សាវាទុកជាសម្បត្តិសាធារណៈ។ តើព្រះតេជគុណយល់ឃើញយ៉ាងម៉េច?"។ ព្រះចៅអធិការវត្ត សេង ថន បានមានសង្ឃដីកាតបថា "អាត្មាយល់ស្រប"។

ក្នុងការការពារខ្លួន ព្រះចៅអធិការវត្តអង្គនេះបានមានសង្ឃដីកាថា ព្រះអង្គគ្រាន់តែពិចារណាការលក់ប៉ុណ្ណោះ។ ព្រះតេជគុណបានមានសង្ឃដីកាថា "ញាតិញោមមួយចំនួនបានចោទអាត្មាថា បានរួមគំនិតជាមួយអាជ្ញាធរមូលដ្ឋានដើម្បីលក់ដីតម្លៃរាប់លានដុល្លារ។ អាត្មាសូមបដិសេធការចោទប្រកាន់ដែលថា មានផែនការលក់ ឬដោះដូរវានោះ។ អាត្មាគ្រាន់តែមានគំនិតប៉ុណ្ណោះ...។ អាត្មាមិនទាន់បានទទួលប្រាក់ណាមួយនៅឡើយទេ"។

លោក ស៊ុត សាត ជាមេប៉ុស្តិ៍ដែលបានចូលរួមការប្រជុំកាលពីសប្តាហ៍មុននៅវត្តនេះ ក៏បាននិយាយដែរថា មានការផ្តើមគំនិតហើយឥឡូវបានបោះបង់ចោលហើយ។

លោកថ្លែងថា "យើងបានធ្វើការប្រជុំនេះបន្ទាប់ពីមានសំណើមួយពីព្រះចៅអធិការវត្ត ហើយយើងមិនបានថា ត្រូវលក់វាទេ ។ យើងគ្រាន់តែបានពិភាក្សាអំពីគំនិតនេះ ហើយបន្ទាប់ពីយើងបានទទួលការបដិសេធយើងបានបោះបង់វាចោលហើយ"។

ព័ត៌មានដែលថា ស្រះទឹកនេះនឹងទុកនៅជាទ្រព្យសម្បត្តិសាធារណៈបានទទួលការអបអរក្នុងចំណោមអ្នកភូមិប្រហែល៣០០នាក់ដែលបានមកជួបជុំគ្នានៅខាងក្រៅវត្តនេះកាលពីម្សិលមិញ ប៉ុន្តែអ្នកភូមិខ្លះចង់បញ្ជាក់អំពីការទាមទាររបស់ខ្លួនឱ្យដកព្រះតេជគុណ សេង ថន និងលោកសុខ លី ប្រធានភូមិចោមចៅចេញពីតំណែង។

លោកអភិបាលរងខណ្ឌ ស៊ុនសូដា បានបន្តថា លោកនឹងឱ្យបុគ្គលិករបស់លោកចុះពិនិត្យមើលការអះអាងរបស់ពួកគាត់ប្រឆាំងអ្នកទាំងពីរ ថាតើនិងពេលណាពួកគាត់បានដាក់ពាក្យបណ្តឹងជាផ្លូវការនោះ៕ **និត**



ប្រជាជននៅខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ តវ៉ានៅខាងក្រៅវត្តគោកបញ្ចាន់ កាលពីម្សិលមិញ ប្រឆាំងផែនការលក់ដីស្រះទឹករបស់វត្តក្នុងតម្លៃ៤.៨លានដុល្លារ ។ រូបថត: ស៊ីរ៉ំ ចាន់ណា, The Cambodia Daily

# PLANS TO SELL OFF PAGODA POND ABANDONED FOLLOWING PROTESTS

**by Ben Sokhean | March 1, 2016**

The deputy governor of Phnom Penh's PurSenchey district on Monday put an abrupt end to a pagoda chief's plans to sell off a nearby pond for $4.8 million, rumors of which have sparked days of protests by angry locals.

Residents of Choam Chao commune rely on the three-hectare body of water to grow vegetables, and pray at a local shrine to the spirit of the pond, which lies a few hundred meters from Wat KokBanhchoan. Hundreds have been protesting outside the pagoda since Saturday, following a meeting between chief monk Seng Thorn and local officials on Wednesday to discuss selling the pond for $160 per square meter.

During a four-hour meeting at the pagoda on Monday, deputy district governor Khem Sunsoda said the sale would not be approved in order to satisfy popular demand.

"We agree to not sell it and keep it as public property. What do you think about that?" Mr. Sunsoda asked the monk chief.

"I accept it," Seng Thorn replied.

In his defense, the chief monk said he had only been considering the sale.

"Some people accused me of conspiring with local authorities to sell the land for millions of dollars," he said. "I want to reject the accusation that there was a plan to sell or swap it. I just had an idea.… I have not received any money yet."

Commune chief Suth Sath, who attended last week's meeting at the pagoda, also said the idea had been in its infancy and would now be abandoned.

"We held the meeting following a request from the monk chief, and we did not say it must be sold. We just discussed the idea, and after we received objections, we abandoned it," he said.

News that the pond would remain public property was met with cheers among the roughly 300 villagers who had gathered outside the pagoda on Monday, but some wanted to press ahead with their demand that Seng Thorn, and Choam Chao village chief Sok Ly, be removed from their positions.

Mr. Sunsoda said he would have his staff investigate their claims against the pair if and when they submitted a formal complaint.

sokhean@cambodiadaily.com

© 2016, The Cambodia Daily. All rights reserved.No part of this article may be reproduced in print, electronically, broadcast, rewritten or redistributed without written permission.

ឌឺ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឺ ខេមបូឌា ដេលី

# រដ្ឋាភិបាលចុះកិច្ចព្រមព្រៀងតភ្ជាប់បណ្តាញខ្សែកាបអុបទិកក្នុងទឹកប្រាក់៧០លានដុល្លារ

**ដោយកង សុធា** | **March 3, 2016**

រដ្ឋាភិបាលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងវិនិយោគមួយដែលមានទឹកប្រាក់៧០លានដុល្លារជាមួយក្រុមហ៊ុនផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ចិនកាលពីម្សិលមិញ ដើម្បីតភ្ជាប់ប្រទេសកម្ពុជាទៅនឹងបណ្តាញខ្សែកាបអុបទិកក្រោមសមុទ្រប្រវែង២៥ ។០០០គីឡូម៉ែត្រកាត់ទ្វីបចំនួន៣ ។

យោងតាមបុគ្គលិកក្រុមហ៊ុន និងមន្ត្រីរដ្ឋាភិបាលបានឱ្យដឹងថា ហេដ្ឋារចនាសម្ព័ន្ធថ្មីដែលគេរំពឹងថា នឹងដំណើរការនៅឆ្នាំ២០១៧ នឹងធ្វើឱ្យប្រព័ន្ធអ៊ីនធឺណិតកាន់តែមានល្បឿនលឿន និងតម្លៃកាន់តែថោក ។

បណ្តាញខ្សែកាបអុបទិកកម្ពុជា (CFOCN) ជាបុត្រសម្ព័ន្ធកាន់កាប់ទាំងស្រុងដោយក្រុមហ៊ុន HyalRoute Group បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសាងសង់ ដំណើរការផ្ទេរ ដែលមានទឹកប្រាក់៦៩្ស៧លានដុល្លារជាមួយក្រសួងនេះនៅក្នុងពិធីមួយនាពេលរសៀល ។

ក្រុមហ៊ុននេះនឹងតភ្ជាប់ប្រទេសកម្ពុជាទៅកាន់ទ្វីបអាស៊ី អាហ្វ្រិក និងអឺរ៉ុប-១ (AAE-1) ជាបណ្តាញក្រោមសមុទ្រជាមួយនឹងបច្ចេកវិទ្យាកម្លាំង១០០ជីហ្គាបៃ (Gigabit) ក្នុង១វិនាទី និងមានសមត្ថភាពជាង៤០តេរ៉ាបៃ (terabits) តាមរយៈចំណុចតភ្ជាប់ក្នុងឈូងសមុទ្រថៃនៅក្នុងដែនសមុទ្រក្រុងព្រះសីហនុ ។

សេចក្តីប្រកាសព័ត៌មានពីក្រុមហ៊ុន Hyral Route មានខ្លឹមសារដូច្នេះថា "ការវិនិយោគរួម AAE-1 នឹងជាការតភ្ជាប់បណ្តាញខ្សែកាបថ្មីបំផុត និងធំបំផុត ដើម្បីតភ្ជាប់ទៅប្រទេសធំៗស្ថិតក្នុងទ្វីបអាស៊ីអាហ្វ្រិកមជ្ឈិមបូព៌ា និងប្រទេសនៅតំបន់អឺរ៉ុប ។ គេរំពឹងថា វានឹងភ្ជាប់ការចែករំលែកបច្ចេកវិទ្យាឌីជីថលរវាងប្រទេសកម្ពុជា និងតំបន់អភិវឌ្ឍន៍នានានៅក្នុងពិភពលោក" ។

យោងតាមសេចក្តីប្រកាសព័ត៌មានបានឱ្យដឹងថា ក្រុមហ៊ុនចម្រុះមួយក្នុងចំណោមក្រុមហ៊ុនទូរគមនាគមន៍១៩ក្នុងពិភពលោកបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងដើម្បីអភិវឌ្ឍបណ្តាញនេះក្នុងខែមករា ឆ្នាំ២០១៤ ។ បច្ចុប្បន្ននេះវាបានតភ្ជាប់ទៅកាន់ប្រទេសចំនួន១៩ ដោយគេរំពឹងថា សាខានៅប្រទេសកម្ពុជា នឹងដំណើរការនៅដំណាច់ឆ្នាំ២០១៧ ។

សេចក្តីប្រកាសព័ត៌មាននេះបន្ថែមទៀតថា "ក្រុមហ៊ុន HyralRoute បានតបណ្តាញខ្សែកាបអុបទិកលើផ្ទៃដីប្រវែង១០.២៤៨គីឡូម៉ែត្រ ដែលគ្របដណ្តប់ក្នុងខេត្តចំនួន២៥ក្នុងប្រទេសកម្ពុជា ។ ហើយចំនួនអតិថិជនប្រើប្រាស់បណ្តាញនេះមាន ៣០០.០០០គ្រួសារ" ។

លោក ខូវ មករា អ្នកនាំពាក្យក្រសួង



Prak Sokhon, left, minister of posts and telecommunications, and Huang Xinglong, chairman of HyalRoute Group, sign an agreement to connect Cambodia to a 25,000-km underwater fiber-optic network. (Siv Channa/The Cambodia Daily)

ប្រៃសណីយ៍ និងទូរគមនាគមន៍បានមានប្រសាសន៍ថា គម្រោងនេះនឹងធ្វើឱ្យអ៊ីនធឺណិតកាន់តែមានតម្លៃថោកនៅក្នុងប្រទេសកម្ពុជាដោយកាត់បន្ថយការពឹងផ្អែកទៅលើប្រទេសជិតខាង ។

លោក មករា បានថ្លែងថា "បន្ទាប់ពីរៀបចំបណ្តាញខ្សែកាបក្រោមសមុទ្ររួចអ៊ីនធឺណិតនឹងលែងត្រូវឆ្លងកាត់តាមប្រទេសវៀតណាម ឬប្រទេសថៃទៀតហើយ ។ ឧទាហរណ៍នៅពេលយើងចង់តបណ្តាញអ៊ីនធឺណិតពីហុងកុង ឬបារាំងយើងអាចតភ្ជាប់ដោយផ្ទាល់ ដូច្នេះតម្លៃនៃការតភ្ជាប់បណ្តាញនឹងកាន់តែមានតម្លៃថោក" ។

លោក Joseph Man Chue Chan ប្រធានគណៈកម្មាធិការគ្រប់គ្រង AAE-1 បានពន្យល់ថា ការតភ្ជាប់បណ្តាញខ្សែកាបនឹងធ្វើឱ្យប្រទេសកម្ពុជាអាចប្រើប្រាស់អ៊ីនធឺណិតនូវកម្រិតបញ្ជូនទិន្នន័យកាន់តែខ្ពស់ ។

លោកបានមានប្រសាសន៍ថា "ប្រព័ន្ធនេះនឹងគាំទ្ររាល់ទម្រង់នៃការទំនាក់ទំនងនិងការប្រើប្រាស់ទាំងអស់រួមទាំងអ៊ីនធឺណិតល្បឿនលឿន វីដេអូ សំឡេង ទិន្នន័យ... ក្នុងល្បឿនកាន់តែលឿន" ។ **តទៅទំព័រទី ២៣**

# GOVERNMENT SIGNS $70M DEAL FOR SUBMARINE INTERNET CABLE

**byKang Sothear | March 3, 2016 |**

The government signed a $70 million investment agreement with a Chinese-owned telecommunication infrastructure provider on Wednesday to connect Cambodia to a 25,000-km underwater fiber-optic network spanning three continents.

The new infrastructure, expected to be operational by 2017, will bring faster and cheaper Internet to the country, according to company and government officials.

The Cambodia Fiber Optic Communication Network (CFOCN), a wholly owned subsidiary of the HyalRoute Group, signed the 25-year, $69.7 million build-operate-transfer deal with the ministry in an afternoon ceremony.

The firm will link Cambodia to the Asia-Africa-Europe-1 (AAE-1)-a submarine network with 100-gigabit-per-second technology and capacity for more than 40 terabits-via a connection point in the Gulf of Thailand off the coast of Sihanoukville.

"The AAE-1 ventures are to be the largest, newest cable constructed, to link all major Asian, African, Middle Eastern and European nations," read a press release from HyalRoute. "It is expected to significantly bridge the digital divide between Cambodia and developed areas in the world."

A consortium of 19 global telecommunications firms signed an agreement to develop the network in January 2014. It currently links to 19 countries, with the Cambodia branch expected to be operational by the end of 2017, according to the press release.

"HyalRoute Group has constructed 10,248-km of terrestrial fiber optic cable that covers 25 provinces in Cambodia," it added. "And the number of customer access network coverage reaches 300,000 households."

Khov Makara, a spokesman for the Ministry of Posts and Telecommunications, said the project would bring cheaper Internet to Cambodia by reducing its reliance on neighboring countries.

"After the submarine cable is configured, the Internet will no longer need to pass through Vietnam or Thailand," Mr. Makara said. "When we want to connect to Internet from Hong Kong or France, for example, we can connect directly, so the cost of connection will be cheaper."

The cable connection would also give Cambodia access to the Internet at a much higher bandwidth, explained Joseph Man Chuen Chan, chairman of the AAE-1 management committee.

"The system would support all forms of communications and applications including broadband Internet, video, voice, data…at a faster speed," he said.

As of December, Cambodia had 6.7 million Internet users, representing slightly more than 40 percent of the population, according to the Telecommunications Ministry, up from just over 1 percent of the population in 2010.

Kan Channmeta, a secretary of state of the Telecommunications Ministry, said the submarine cable would help meet future demand from both retailers and consumers-including Prime Minister Hun Sen.

"We should be able to respond to increasing annual demand for the Internet from consumers," Mr. Channmeta said.

"But if we don't develop better connections, the people would be unable to use data up to their capacity and the speed would falter," he added.

"The prime minister uses Facebook every day…and so he wants fast-running Internet."

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# គណបក្សប្រឆាំងច្រានចោលខ្សែអាត់សំឡេងជាច្រើនទាក់ទិនរឿងអាស្រូវផ្លូវភេទរបស់លោក កឹម សុខា

**ដោយអូន ភាព** | March 2, 2016

អ្នកនាំពាក្យគណបក្សប្រឆាំងបានច្រានចោលខ្សែអាត់សំឡេងជាបន្តបន្ទាប់ចេញផ្សាយនៅសប្តាហ៍នេះ ដែលគេថា ជាសំឡេងរបស់លោក កឹម សុខា អនុប្រធានគណបក្សសង្គ្រោះជាតិ និយាយគ្នាជាមួយស្រីស្នេហ៍របស់លោក ហើយ លើកឡើងថា ខ្សែអាត់សំឡេងទាំងនេះមានបំណងបង្ក "បញ្ហា" ដល់គណបក្សរបស់លោក។

ខ្សែអាត់សំឡេងទាំងនេះដែលនីមួយៗមានរយៈពេលប្រហែលមួយនាទី ត្រូវបានបង្ហោះកាលពីថ្ងៃច័ន្ទលើទំព័រហ្វេសប៊ុករបស់ស្រីស្នេហ៍ម្នាក់នោះឈ្មោះ "ស្រីមុំ"។ ខ្សែអាត់ទាំងនេះបានធ្វើឱ្យសាធារណជនចាប់អារម្មណ៍យ៉ាងខ្លាំងកាលពីម្សិលមិញ បន្ទាប់ពីគេហទំព័រព័តិមានក្នុងស្រុកដើមអំពិល បានបង្ហោះអត្ថបទជាច្រើនអំពីវាដោយភ្ជាប់ Profile ហ្វេសប៊ុករបស់ ស្រីមុំ។

រឿងអាស្រូវនេះត្រូវបានចុះផ្សាយតាមក្រោយដោយស្ថាប័នប្រព័ន្ធផ្សព្វផ្សាយជាភាសាខ្មែរមួយចំនួនទៀតដែលគាំទ្ររដ្ឋាភិបាល និងត្រូវបានជជែកដេញដោលយ៉ាងទូលំទូលាយតាមបណ្តាញទំនាក់ទំនងសង្គម។

ក្នុងខ្សែអាត់នីមួយៗអាចស្តាប់ឮបុរសម្នាក់ដែលមានសំឡេងស្រដៀងនឹងសំឡេងរបស់លោក កឹម សុខា និយាយញ្ចែគ្នាជាមួយនារីម្នាក់ដែលគេហទំព័រដើមអំពិលបញ្ជាក់ថា ឈ្មោះ ស្រីមុំ។ នៅក្នុងការសន្ទនាមួយអាចស្តាប់ឮនារីនោះសួរទៅបុរសនោះទាក់ទិនទំនាក់ទំនងរបស់គាត់ជាមួយសកម្មជននយោបាយ ធី សុវណ្ណថា វ័យ ២០ ឆ្នាំ ។

នារីនោះសួរថា "បងឯងទាក់ទងគេមែនជាមួយ ធី សុវណ្ណថា? ឥឡូវគេល្បីថា បងឯងទាក់ទងជាមួយគេ និងទិញឡានឱ្យ"។

បញ្ឆិតបញ្ឆៀងដល់ជម្លោះរបស់សកម្មជនរូបនេះជាមួយកញ្ញា កឹម មនោវិទ្យា ដែលត្រូវជាកូនស្រីរបស់លោក កឹម សុខា និងជាអនុប្រធានកិច្ចការសាធារណៈរបស់គណបក្សប្រឆាំងបុរសនោះឆ្លើយថា "អត់មានទេ ព្រោះវាឈ្លោះជាមួយកូនខ្ញុំឈ្លោះជាមួយគណបក្សសង្គ្រោះជាតិ"។

បុរសនោះបាននិយាយអំពី ធី សុវណ្ណថា ដូច្នេះថា "វាប្រើប្រាស់គណបក្សសង្គ្រោះជាតិដើម្បីធ្វើនយោបាយបានលុយបានអីពីក្រៅ។ ខ្ញុំស្បថឱ្យរលាយបើខ្ញុំពាក់ព័ន្ធជាមួយ ធី សុវណ្ណថា"។

នៅក្នុងការសន្ទនាផ្សេងៗទៀត អ្នកទាំងពីរបាននិយាយបញ្ឆិតបញ្ឆៀងដល់ទំនាក់ទំនងផ្លូវភេទរបស់ខ្លួន។ ក្នុងខ្សែអាត់មួយ បុរសនោះសួរថា "អូនឯងចង់ឱ្យបងញាប់អញ្ចឹងហ្អេះ? ពីរថ្ងៃ១០ដងអញ្ចឹងហ្អេះ?"នារីនោះឆ្លើយថា "ចង់"។

បុរសនោះនិយាយទៀតថា "អូនឯងចង់អញ្ចឹងហ្អេះ?" នាងឆ្លើយថា "អូខេ អត់បញ្ហាបងសំឡាញ់"។

ទាក់ទិនបញ្ហានេះ លោក យ៉ែម បុញ្ញឫទ្ធិ អ្នកនាំពាក្យគណបក្សសង្គ្រោះជាតិបានមានប្រសាសន៍កាលពីម្សិលមិញថា បុរសនៅក្នុងខ្សែអាត់សំឡេងនោះមិនមែនជាលោក កឹម សុខា ទេ។

លោកបានបន្តថា "ខ្ញុំបានឮខ្សែអាត់សំឡេងដែលបង្ហោះតាមប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកហើយ ប៉ុន្តែខ្ញុំគិតថា វាមិនមែនជាសំឡេងរបស់ឯកឧត្តម កឹម សុខា ទេ។ ខ្ញុំគិតថា មានអ្នកណាម្នាក់បានបង្កើតខ្សែអាត់សំឡេងទាំងនេះឡើងដើម្បីបង្កបញ្ហាដល់គណបក្សសង្គ្រោះជាតិ" ហើយថា លោក [illegible]មិនព្រួយបារម្ភ" ចំពោះខ្សែអាត់ទាំងនេះឡើយ។

ទោះជាយ៉ាងណា លោក កឹម សុខា កញ្ញា កឹម មនោវិទ្យា និងកញ្ញា ធី សុវណ្ណថា មិនអាចទាក់ទងសុំការបំភ្លឺបានទេកាលពីម្សិលមិញ។

លោក អ៊ូ វីរៈ អ្នកវិភាគនយោបាយបានមានប្រសាសន៍ថា លោកជឿថា បញ្ហាចេញពីខ្សែអាត់សំឡេងទាំងនេះ មិនថាវាពិតឬមិនពិត គឺវានឹងមិនធំដុំឡើយ។ "បើយើងក្រឡេកមើលអតីតកាល គឺនៅមុនការបោះឆ្នោតឆ្នាំ២០១៣ មានការទម្លាយព័តិមានស្រដៀងគ្នា" នេះជាអ្វីដែលលោក អ៊ូ វីរៈ លើកឡើងអំពីការចោទប្រកាន់ថា លោក កឹម សុខា បានចំណាយប្រាក់ដើម្បីរួមភេទជាមួយក្មេងស្រីអាយុ១៥ឆ្នាំម្នាក់ ហើយក៏បានបោះបង់ស្រីស្នេហ៍ម្នាក់ចោលដែរ ដោយទុកឱ្យនាងចិញ្ចឹមកូនពីរនាក់តែម្នាក់ឯង។

លោកបានបន្តថា "អ្វីដែលខ្ញុំគិតគឺថា តើគាត់ឱ្យលោក កឹម សុខា" ដោះស្រាយវាតាមវិធីណា។ ឱ្យតែគាត់មិនអើពើនឹងវា ខ្ញុំគិតថា វាប្រហែលជាស្ងប់ស្ងាត់ទៅវិញក្នុងរយៈពេល១សប្តាហ៍ ឬ ២សប្តាហ៍ ហើយវានឹងមិនក្លាយជាបញ្ហាធំទេ"៕

**សុខុម (រាយការណ៍បន្ថែមដោយ Anthony Jensen)**

# ប្រេសិតអាមេរិកនិយាយថា មានការពិភាក្សាសិទ្ធិមនុស្សនៅជំនួបកំពូល

**ដោយគុច ណារ៉េន និង Anthony Jensen** | February 25, 2016




ប្រេសិតជាន់ខ្ពស់អាមេរិកប្រចាំអាស៊ាន បាននិយាយកាលពីថ្ងៃពុធថា ថ្វីបើបញ្ហាពាណិជ្ជកម្ម និងសន្តិសុខត្រូវគេយកចិត្តដាក់នៅជំនួបកំពូលអាមេរិក-អាស៊ានកាលពីសប្តាហ៍មុនក៏ដោយ ក៏ លោក បារ៉ាក់ អូបាម៉ា ប្រធានាធិបតីអាមេរិក បានប្រើជំនួបនោះដើម្បីលើកឡើងអំពីបញ្ហាសិទ្ធិមនុស្សរបស់តំបន់នេះដែរ។

ថ្លែងពីទីក្រុងហ្សាការតាក្នុងពេលធ្វើទូរសន្និសីទជាមួយអ្នកយកព័តិមានលោកស្រីនីណាហាឈីជាន (Nina Hachigian) បាននិយាយថា ជំនួបកំពូលដែលធ្វើឡើងនៅ រ៉ានឆូ មីរេជ រដ្ឋកាលីហ្វ័រញ៉ា ពីថ្ងៃទី១៥ដល់១៦ខែកុម្ភៈ ក៏ដូចជាទំនាក់ទំនងអាមេរិក-អាស៊ានជាទូទៅដែរ បានផ្តោតលើ "ការលូតលាស់ស្ថិរភាព ឱ្យនិងច្បាប់ជាច្រើន"។

ឆ្លើយតបទៅនឹងសំណួរអំពីថាតើការអញ្ជើញប្រទេសកម្ពុជាចូលរួមជំនួបកំពូលនេះ បានបង្ហាញការមើលឃើញសុទិដ្ឋិនិយមទាក់ទិននឹងស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសនេះដែរឬទេ លោកស្រីហាឈីជាន បាននិយាយថា "ខ្ញុំអាចប្រាប់លោកបានថា នៅគ្រប់ឱកាសទាំងអស់ក្នុងជំនួបកំពូលលោកប្រធានាធិបតីបានលើកឡើងនូវសារៈសំខាន់នៃសិទ្ធិមនុស្ស និងនីតិរដ្ឋ"។

លោកស្រីបាននិយាយថា "អាទិភាពសំខាន់របស់យើងគឺចង់មើលឃើញប្រទេសកម្ពុជាអភិវឌ្ឍទៅជាលទ្ធិប្រជាធិបតេយ្យរឹងមាំដែលគោរពសិទ្ធិមនុស្ស និងគាំទ្រសង្គមស៊ីវិលចម្រើនលូតលាស់"។

លោកស្រី ហាឈីជាន បានបន្ថែមថា "ការប្រឈមដ៏ច្រើន"នៅតែមាន។

លោកស្រីបាននិយាយថា "យើងជំរុញឱ្យរដ្ឋាភិបាលកម្ពុជាបន្តបង្កើតសង្គមប្រកបដោយយុត្តិធម៌ត្រឹមត្រូវថែមទៀត និងធ្វើឱ្យការប្តេជ្ញារបស់ខ្លួនប្រសើរឡើងចំពោះលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស"។

ក្នុងសន្ទរកថាបើកនៅជំនួបកំពូលកាលពីថ្ងៃទី១៥ខែកុម្ភៈ លោក អូបាម៉ា បានរំលងការនិយាយអំពីសិទ្ធិមនុស្ស និងឋានៈរបស់ខ្លួនក្នុងទំនាក់ទំនងអាមេរិក-អាស៊ាន។

លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា ដែលកាលពីសប្តាហ៍មុនបានចាត់ទុកការអញ្ជើញលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ទៅចូលរួមជំនួបកំពូលនេះជា "ដំបងឈើធ្ងន់ដ៏ធំវាយចំក្បាលអ្នកប្រឆាំង"នោះ បាននិយាយថា ការនិយាយអំពីសិទ្ធិមនុស្សរបស់លោក អូបាម៉ា គឺតិចតួចបំផុត។

លោក ឥសាន បាននិយាយថា "មុនដំណើរអញ្ជើញមកដល់របស់គណៈប្រតិភូជាន់ខ្ពស់កម្ពុជា ឱ្យក្រុមសង្គមស៊ីវិលនិងក្រុមអ្នកតវ៉ាប្រឆាំងរដ្ឋាភិបាល បានសំល្ងៀងកាំបិត ហើយហុចទៅឱ្យប្រធានាធិបតី អូបាម៉ាដើម្បីកាប់ចិញ្ច្រាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា"។

លោកបាននិយាយថា "ទោះជាយ៉ាងនេះក្តី យើងបានកត់សម្គាល់ឃើញថា គ្មាននរណានៅឯជំនួបកំពូលនោះបានលើកឡើងពីបញ្ហាអវិជ្ជមានទាំងនេះដាក់លើថ្នាក់ដឹកនាំរបស់រដ្ឋាភិបាលដែលដឹកនាំដោយសម្តេច តេជោ ហ៊ុន សែន នោះទេ។ ហេតុដូច្នេះ យើងចាត់ទុកការទៅចូលរួមរបស់គណៈប្រតិភូជាន់ខ្ពស់កម្ពុជានៅជំនួបកំពូលអាមេរិក-អាស៊ាន ថា ជោគជ័យសម្បើមមួយ"៕

**និត**

# តមកពីទំព័រទី ០១ បើ សម រង្ស៊ី អាចឃាត់បាតុករបាន..

មែនទៅវិញបានន័យថា "បាតុករជាអ្នកស្តាប់បញ្ជាដោយគ្មានលក្ខខណ្ឌពីមេបក្សរបស់ខ្លួន"។ ប្រៀបប្រដូច ទៅមេដឹកនាំខ្មែរ ហ៊ុន សែន វិញ បាតុកម្មថ្មីៗមួយបានផ្ទុះឡើងតាមបញ្ជា ហ៊ុន សែន ពីក្រុងប៉ារីស បណ្តាលសមាជិកសភា២រូប រងរបួសជាទម្ងន់ ក្រោមក្រសែភ្នែកនៃសមាជិកសភាគណបក្សប្រជាជន នឹងកងមានសមត្ថកិច្ចខ្មែរដែលគ្មានប្រតិកម្មណាមួយការពាររដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រទេ។ថ្មីៗនេះទៀត ក៏គ្រោងនឹងបញ្ជាបាតុកម្មមួយទៀត តែមិនបានបញ្ជាទៅវិញ ដោយទទួលពតិមានថា បាតុកម្មប្រឆាំងនឹងខ្លួន វាតូចពេក។

ប្រជាពលរដ្ឋខ្មែរនៅសហរដ្ឋអាមេរិកដែលមិនស្តាប់បញ្ជា សម រង្ស៊ី ពីព្រោះបញ្ជាបៀបនេះមិនស្របនឹងឆន្ទៈប្រជាពលរដ្ឋខ្មែរដែលទទួលបាននូវសេរីភាពពីការសម្តែងបតិពីច្បាប់នៃសហរដ្ឋអាមេរិកទេ ថែមទាំងជា "ការលើកទឹកចិត្តមេដឹកនាំផ្តាច់ការ" ឱ្យនៅក្នុងអំណាចដ៏ឃោឃៅរបស់ខ្លួនតទៅទៀតផង។ ក្នុងន័យនេះហើយបានជាយើងថា "បើ សម រង្ស៊ី ឃាត់បាតុករបានទៅវិញ នេះគឺជាការឃាត់មិនឱ្យឆន្ទៈប្រជាពលរដ្ឋផុសចេញមកក្រៅដោយសេរី"នោះទេ គឺជាទង្វើដូចគ្នានឹង ហ៊ុន សែន ដែរ។

លើកនេះបាតុករទៅពីឡូវែលពីកូណិចទីកិតពីញូយ៉ក ពីហ្វីឡាដែលហ្វៀ ពីហ្វ្លរីដា ក៏ដូចជាមកពីកាណាដា ពីអូស្ត្រាលី។។។សុទ្ធតែជិះយន្តហោះយកពេលវេលានឹងជំនឿទៅលើកម្ពុជាថ្មីរបស់ខ្លួន


លោក សម រង្ស៊ី



ឯងផ្ទាល់មកសម្តែងមតិដែលខ្លួនយល់ថា "ជាឱកាសដ៏វិសេសវិសាលដើម្បីជួយពលរដ្ឋកម្ពុជានាពេលនេះ"។ រីឯអ្នកនៅរដ្ឋវ៉ាស៊ីនតុន ឬនៅស្តុកតុន ឬនៅកាលីហ្វ័រញ៉ាសុទ្ធតែជិះបើសទាំងក្រុមៗ ឬជិះរថយន្តផ្ទាល់រាប់ម៉ោង ដើម្បីទៅជួបឱកាសដើម្បីនឹងបង្ហាញឆន្ទៈរបស់ខ្លួនពីប្រទេសដែលគេឱ្យតម្លៃខ្ពស់ដល់"មតិ"ពលរដ្ឋ។ នេះជាកាយវិការគួរគោរពមិនគួរខកខានដែលត្រូវតែលើកទឹកចិត្តដើម្បីបង្កើនកម្លាំងផ្លាស់ប្តូរនៅកម្ពុជាឱ្យបានរិតតែឆាប់បាន។ គឺមនុស្សដដែលនេះហើយដែលបានជម្រុញឱ្យ សម រង្ស៊ី មានសេចក្តីក្លាហាននឹងដឹកមុខចលនាប្រទាញយកជនផ្តាច់ការចេញពីអំណាចកាលពីឆ្នាំ២០១៣។ ចលនាមនុស្សធ្វើបាតុកម្មប្រមាណ១លានអ្នកកាលពីចុងឆ្នាំ២០១៣នៅកម្ពុជា ក៏មានការគាំទ្រគ្មានសំចៃពីមនុស្សដដែលនេះដែរ ហើយការតស៊ូរបស់ក្រុមមនុស្សដែលមិនស្គាល់គ្នាសោះតែចិត្តមូលគ្នានោះ ក៏ប្រមូលបានមតិពីភពលោកចូលជួយគាំទ្របានពលរដ្ឋកម្ពុជាឱ្យប្រមូលបានជាបាតុកម្មដ៏ធំជាងគេបង្អស់នាចុងឆ្នាំ២០១៣នោះដែរ។

ចាប់តាំងដើមឆ្នាំ២០១៤មក ថ្វីត្បិតតែមិនមានអ្វីផ្លាស់ប្តូរសម្រាប់ពលរដ្ឋនៅឡើយក្តីការលើកទឹកចិត្តពលរដ្ឋឱ្យចេញបះបោរ ពីគណបក្សសង្គ្រោះជាតិ ដោយសង្ឃឹមថា "គ.ជ.ប. នឹងជួយស្រោចស្រង់ជ័យជំនះនៃចលនាផ្លាស់ប្តូរថ្នាក់ដឹកនាំ"ជំនួសការតស៊ូដ៏ស្វិតស្វាញរបស់ពលរដ្ឋបានធ្លាក់ថយចុះជាលំដាប់... ថែមពីនេះទៅទៀត សញ្ញាខ្លាចគ្រោះថ្នាក់ចេះតែកើនធំឡើងបានជាប្រយោជន៏ដល់ ហ៊ុន សែន ដែលត្រូវការឱ្យ "ចំនួនមនុស្សធ្វើបាតុកម្មចុះ" ដែលត្រូវការឱ្យគ.ជ.ប. បាត់បង់ឯករាជ្យភាព។

តើឆ្នាំ២០១៧ នៃការបោះឆ្នោតឃុំសង្កាត់នឹងឆ្នាំ២០១៨នៃការបោះឆ្នោតសភាជាតិនឹងជួយប្រជាពលរដ្ឋឱ្យងើបមកគាំទ្រចលនាផ្លាស់ប្តូរនយោបាយបានដែរឬទេ? មានសង្ឃឹមតិចតួច ! ពីព្រោះ ហ៊ុន សែន ហាក់ដូចជាទទួលបាននូវអារម្មណ៏ថា១-គណបក្សប្រឆាំងខ្លាចអំណាចខ្លួន ២-ប្រជាពលរដ្ឋអ្នកបោះឆ្នោតក៏នៅក្នុងដង្ហៀបនៃអំណាច៣-គ.ជ.ប.ថ្មី ក៏ឱ្យសញ្ញាមកថា "គ្មានភាពរឹងប៉ឹង"ប្រឈមមុខនឹងអ្នកកាន់អំណាចនៅឡើយទេ។

រំលឹកពី"មហាបាតុកម្មប្រជារាស្ត្រ"ទាមទាឱ្យមានការរាប់សន្លឹកឆ្នោតសារជាថ្មី កាលពីចុងឆ្នាំ២០១៣ ពុំមែនកើតឡើងដោយឯកឯងភ្លាមៗ



នោះទេ គឺប្រាកដជាការខិតខំសន្សំកម្លាំងស្នេហាជាតិខ្មែរ តាំងពីមួយឆ្នាំទៅមួយឆ្នាំទៀត ហើយនៅឆ្នាំ២០១៣នោះ គឺតាំងពីមួយឆ្នាំមុនមកម្លេះ គឺ ១-ការអបអរសាទរនឹងការរួមបញ្ចូលគ្នារវាង "គណបក្សសិទ្ធមនុស្ស"នឹង"គណបក្សសមរង្ស៊ី" មនុស្សរួមប្រជុំគ្នាកាន់តែច្រើន២-ពលរដ្ឋឃើញគណបក្សប្រឆាំងយកអាសនៈឃុំសង្កាត់ពីគណបក្សប្រជាជនកម្ពុជាបានច្រើននាឆ្នាំ២០១២ ៣-ចលនាមនុស្សរីករាយនឹងឃើញ សម រង្ស៊ី ត្រឡប់ទៅកម្ពុជាវិញមុនថ្ងៃបោះឆ្នោត ៤-ពលរដ្ឋឃើញគណបក្សប្រឆាំងយកអាសនៈសភាជាតិបានច្រើនតែខឹងសម្បានឹងការលួចសន្លឹកឆ្នោតដោយគណបក្សប្រជាជន ៥-កំហឹងបានក្លាយទៅជាសាធារណចេញមុខបានជាបាតុករ១លាននាក់ នឹងអ្នកដែលមិនចេញមុខច្រើនលាននាក់ទៀត រង់ចាំលទ្ធផល

តទៅទំព័រទី ២០



# Lowell City Council Meeting: February 23, 2016



Richard Howe

Public hearing on rezoning along Pawtucket Blvd for benefit of Hamil Automotive, a longtime, family-owned business, presented on behalf of the business by Atty George Eliades. Sounds like a preliminary proposal was rejected by the planning board. Proponent wants to make its case to city's DPD and to the city council zoning subcommittee. Neighbors speaking in opposition. First one says Hamils have always been good neighbors but he's concerned about the long term consequences. Chair of Pawtucketville neighborhood group speaks in opposition. She says that despite this being a responsible business, the zoning change would change more than just this business but a larger part of the neighborhood. Councilor Milinazzo supports referring the change to the zoning subcommittee. Councilor Mercier pressing Atty Eliades on the reasons for the Planning Board's negative response (not sure how she'll vote). Councilor Rourke says he's ready to vote on it tonight. Councilor Leahy says he'll vote to send it to the subcommittee because they've been a good business and a good neighbor. Councilor Leary concurs with what Leahy just said, although he values preserving suburban areas. Councilors Elliott, Belanger, and Samaras all say they'll support sending it to the zoning subcommittee. Councilor Mercier now says she thinks it should be sent to the zoning subcommittee. Motion is to recess the public hearing pending a recommendation of the zoning subcommittee. Motion passes unanimously.

Public hearing to create grant-funded position of crime analyst for Lowell Police Department. Passes unanimously.

Public hearing to create grant-funded position of victim advocate for Lowell Police Department. Passes unanimously.

Public hearing on ordinance to expand number of members on city's Veterans' Commission. Passes unanimously.

Vote to transfer $40,000 to election department to staff polling locations for presidential primary. Passes unanimously.

Vote to transfer $240,000 to provide increased surgery costs for Police/Fire Dept (presumably worker's comp since the city is self-insured). Passes unanimously.

Amendment to ordinance on nuisance postings and a second ordinance regarding minimum maintenance of businesses. It's a comprehensive ordinance based on actual problems that have occurred around the city such as business postings on public spaces like telephone poles. Also includes minimum maintenance for all properties for weed and overgrowth. Also mandates business owners responsibility for the cleanliness of alleys, sidewalks, etc. Sent to a public hearing.

Report from Councilor Elliott on finance subcommittee meeting from earlier tonight. Discussed FY15, FY16, and independent audit. FY15 had surplus that went to free cash that went to pay off last year's snow and ice bill and also went into reserves. FY16, revenue is on target; snow and ice might have a surplus; discussed school teacher contract and its potential impact on future budgets. The independent audit had a good result but there are always ways to improve.

Resident of 494 Bridge Street makes a presentation regarding water runoff/plumbing issues. Manager Murphy says the city is not forcing any changes; it's a new tenant that wants to make the changes, not the city. Seems to have been a misunderstanding which gets cleared up and everyone seems happy.

Motion by Councilor Elliott to form an Ad Hoc Subcommittee to address numerous charter/election issues that have been recently raised. He explains that there is no existing subcommittee that is charged with election issues. He doesn't envision a standing subcommittee but one that just deals with the most recent issues that have already been sent to the personnel subcommittee. Motion passes.

Motion by Councilor Elliott that city council discuss changing to ward representation. No one seconds it. Motion fails for lack of a second.

Motion by Councilor Rourke to establish a preventative maintenance program for city school buildings. Ben Opara, chair of citywide parent council speaks in favor of the motion. He says many parents support this motion to help insure school facilities are repaired in a timely manner.

Motion by Councilor Rourke to have the Lowell Memorial Auditorium inspected for maintenance issues. Says that while at Auditorium events, other patrons have pointed out defects and problems.

Motion by Councilor Rourke for an update on events scheduled at Lowell Auditorium. Several councilors are critical of the lack or variety of events at the Auditorium. Councilor Milinazzo comments that the former management group (Mill City Management) got a percentage of the concession sales which may have given them an incentive to do more than just manage the building. The current management group doesn't have the same incentive.

Motion by Councilor Rourke for a report on 58 Mammoth Road.

Motion by Councilors Rourke and Belanger for an update on old water department building on Hampshire Street. Councilor Belanger says he brought this up a year ago but recently neighbors approached him and Councilor Rourke with complaints about the lack of upkeep of this building.

Motion by Councilor Belanger for an update on development plans for former Jeanne d'Arc Credit Union headquarters at Merrimack and Cabot.

Motion by Councilor Leary for report on status of city dog park. The existing one is going to have to be moved. He'd like there to be more than one so people throughout the city can use it.

Motion by Councilor Leary for report on feasibility of a new crosswalk on Stevens Street between Midland and Westchester Streets.

Announcements: Councilor Leahy says he received much positive feedback on this year's Winterfest. Heard nothing bad. Congratulates Manager Murphy and his team.

Council adjourns at 9:15 pm.

# កិច្ចប្រជុំគណក្រុមប្រឹក្សាក្រុងឡូវែល ថ្ងៃទី២៣ កុម្ភៈ ២០១៦

**ដោយ រីក ហាវ ជីអរ៉រ**

រីក ហាវ បានធ្វើសេចក្តីរាយការណ៍ជាភាសាអង់គ្លេសស្តីអំពីកិច្ចប្រជុំរបស់គណក្រុមប្រឹក្សាក្រុងឡូវែល ក្រោមអធិបតីភាពនៃអភិបាលក្រុងកេណ្ណឺឌី ផ្តោតទៅលើបញ្ហា "ហ្សូនីង"របស់ "ហាមីលអូតូមូទីវ"ដែលនៅលើ"ផទូខិតប៊ូលវ៉ា" - បង្កើតបុគ្គលិកខាងអ្នកវិភាគឧក្រិដ្ឋកម្មប្រចាំក្រុងប៉ូលីសក្រុង -អ្នកណែនាំជនរងគ្រោះនៅការយាល័យប៉ូលីសក្រុង -ការបង្កើនចំនួនគណកម្មការក្រុងខាងអតីតយុទ្ធជន -អនុញ្ញាតឱ្យចាយលុយ៤ម៉ឺនដុល្លាសម្រាប់បុគ្គលិកចៀបចំការបោះឆ្នោតបឋមប្រធានាធិបតី -អនុញ្ញាតិឱ្យចាយលុយ២៤ពាន់ដុល្លាសម្រាប់ការវះកាត់របស់បុគ្គលិកសង្គ្រោះអគ្គីភ័យ - ធ្វើវិសោធនកម្មលើបទបញ្ជាមួយចំនួន -សមាជិក អេលីយ៉ុត ស្នើឱ្យប្តូរច្បាប់ភាពជាដំណាងសង្កាត់នៅឡូវែលតែឥតមានសមាជិកផ្សេងទៀតគាំទ្រសំណើរទេ -សំណើរឱ្យមានកម្មវិធីបង្ការគ្រោះថ្នាក់នៅសាលារៀន -សំណើរឱ្យមានអភិវឌ្ឍន៍នៅអតីតអាគារ "ជេនឌាក ក្រេឌីតយូញូន" -សំណើឱ្យបង្កើតផ្លូវថ្មើជើងឆ្លងថ្នល់ថ្មីនៅ"ស្ទេវេនស្ទ្រីត" នឹងសេចក្តីប្រកាសរបស់សមាជិក លីហ៊ី ថាបានទទួលដំណឹងល្អពី"វិនទើហ្វេស"ថា បានប្រព្រឹត្តទៅប្រសើ ហើយសម្តែងការកោទសសើរដល់ម៉ររហ នាយកសាលាក្រុង។

សូមអញ្ជើញអានកិច្ចប្រជុំជាភាសាអង់គ្លេសភ្ជាប់មកជាមួយនេះ។





# បូស្តុនត្រូវបានជាប់ជាទីក្រុងដ៏ល្អបំផុតលេខពីរក្នុងសហរដ្ឋអាមេរិក

**ដកស្រង់ចេញពី**

**http://www.masslive.com/**

**បកប្រែដោយ តារាយុទ្ធ ហង្ស**

បូស្តុនបានជាប់ចំណាត់ថ្នាក់លេខពីរក្នុងការផ្តល់នូវគុណភាពល្អបំផុត នៃជីវិតនៅក្នុងសហរដ្ឋអាមេរិកនិងជាប់ចំណាត់ថ្នាក់ទី៣៤ នៅលើពិភពលោកបើយោងតាមការស្រាវជ្រាវថ្មីមួយ។

មឺរសៀរ Mercer ជាអង្គភាពមួយនៃក្រុមហ៊ុនម៉ាស (Marsh) និងមីកលីននាន់ (McLennan) បានលើកយកកត្តាទាំង៣៩ សម្រាប់ការសិក្សានេះដែលរួមមានបរិស្ថាននយោបាយសង្គមសេវាវេជ្ជសាស្ត្រសុខភាពលំនៅដ្ឋានបរិស្ថានធម្មជាតិការកម្សាន្តសាលារៀននិងការអប់រំ។

សំរាប់អ្នកដែលនៅមានមន្ទិលសង្ស័យ ទីក្រុង វេនខូវើរ (Vancouver) គឺជាទីក្រុងជាប់ចំណាត់ថ្នាក់ខ្ពស់បំផុតនៅអាមេរិកខាងជើង បើយោងទៅតាមរបាយការណ៍នេះ នឹងសានហ្វ្រាន់ ស៊ីស្កូ (San Francisco) បានជាប់ចំណាត់ថ្នាក់លេខ១នៅសហរដ្ឋអាមេរិក។

ហូណូលូលូ (Honolulu) ឈីកាហ្គោ (Chicago) និងក្រុងញូវយ៉ក (New York City) ត្រូវបានដាក់ឈ្មោះផងដែរថា ជាកន្លែងកំពូល។

Mercer ដែលមានមូលដ្ឋាននៅចក្រភពអង់គ្លេសបានវាយតម្លៃស្ថានភាពរស់នៅក្នុងស្រុកនឹងនៅក្នុងទីក្រុងជាង៤៤០នៅទូទាំងពិភពលោក។ គោលដៅនៃការសិក្សានេះ គឺដើម្បីជួយក្រុមហ៊ុនរបស់ខ្លួនក្នុងការសម្រេចចិត្តដើម្បីកំណត់នៅទីតាំងក្នុងការដាក់នៅទីស្នាក់ការកណ្តាល ឬក៏ទីតាំងផ្តាយរណបរបស់ខ្លួន។

ស្លាជីនប៉ារាកាទីល(SlaginParakatil)ដែលជានាយក និងជាប្រធាន ស្រាវជ្រាវគុណភាព Mercer នៃការរស់នៅបាននិយាយថា "ការគ្រប់គ្រងបញ្ហាសុវត្ថិភាព និងសុខភាពជាការសំខាន់បំផុតជាពិសេសសម្រាប់បុគ្គលិកដែលបានផ្លាស់ប្តូរទីលំនៅជាមួយនឹងក្រុមគ្រួសារ"។ "ហើយការស្ទង់មតិរបស់យើងបានអនុញ្ញាតឱ្យក្រុមហ៊ុនយើងត្រៀមនូវការប្រុងប្រយ័ត្នគ្រប់គ្រាន់សម្រាប់ពួកគេ"៕



តមកពីទំព័រទី ១៩

## បើ សម រង្ស៊ី អាចឃាត់បាតុករបាន..

ល្អពីការដួលរលំរបស់គណបក្សប្រវ័ញ្ចអំណាច។ ទាំងនេះសុទ្ធតែជាជំនឿទៅលើអំពើ "ធ្វើត្រូវ" នឹងជាការលើកទឹកចិត្តជាប្រចាំរបស់គណបក្សប្រឆាំងទៅលើជំនឿនោះជាមួយពលរដ្ឋ ។

ការឃាត់ ឬបង្អាក់ទឹកចិត្តពលរដ្ឋនៅបរទេសមិនឱ្យធ្វើបាតុកម្មប្រឆាំងនឹង ហ៊ុន សែន នៅលើទឹកដីអាមេរិក គឺជាការ "ឱ្យសញ្ញាអវិជ្ជមាន"ទៅដល់ពលរដ្ឋដែលរងគ្រោះគ្រប់ជំនាន់ ឱ្យបន្តទទួលយកបាបកម្មរបស់ខ្លួនតទៅទៀតទៅវិញ។

នៅមួយឆ្នាំទៅមុខទៀតសោះដល់ការបោះឆ្នោតឃុំសង្កាត់ហើយ លោក សម រង្ស៊ី គួរតែយល់ថាពេលវេលាបញ្ចេះម៉ាស៊ីនពលរដ្ឋ"យល់ត្រូវ" បានមកដល់កាលពីថ្ងៃទី១៥-១៦មុននេះហើយ ហ៊ុន សែន បានភ្លាត់ដោយចេញបញ្ជាឱ្យបាតុករខ្លួនទៅវាយតំណាងរាស្ត្រគណបក្សប្រឆាំងធ្វើឱ្យអ្នករងគ្រោះទាំង២នាក់បានក្លាយទៅជាវិរបុរសជាតិថ្មីក្នុងជួររបស់ខ្លួន ។ ឆ្នាំ២០១៧ ជាការសាកល្បងប្រសិទ្ធភាពនៃម៉ាស៊ិន គ.ជ.ប.ថ្មី បើវាមិនដើរ ក៏នៅកម្លាំងប្រជាពលរដ្ឋដដែលដែលត្រូវការ "ការដឹកនាំត្រូវ" ហើយគណបក្សប្រឆាំងក៏ត្រូវការកម្លាំងពលរដ្ឋនោះ សម្រាប់ការបោះឆ្នោតផ្តាច់ព្រាត់ឆ្នាំ២០១៨ម្តងទៀតយ៉ាងខ្លាំងដែរ។

ការយល់ថា"បាតុកម្មខ្មែរនៅបរទេសជាបាតុកម្មតូចតាច" ក៏អាចបកស្រាយបានថា "ជាការបារម្ភរបស់ ហ៊ុន សែន ចំពោះភ្នែកសហរដ្ឋអាមេរិកដែលសម្លឹងមកលើខ្លួនមិនដាក់"នោះដែរ ទៅវិញទេ... បើតែហ៊ាន "ឃើញថាធំ" ទៅវិញ អាចនឹងសម្រេចចិត្តខុសវាយលើជនរងគ្រោះខ្មែរមួយថ្មីទៀត រឿងកាន់តែធំដោយមិនត្រឹមតែយកខ្មែរគ្នាឯងជាសត្រូវថែមទាំងយកអាមេរិកជាសត្រូវថែមទៀត អារម្មណ៍ថា ចាញ់ឆ្នោតក៏កាន់តែច្រើន... ដូច្នេះពេលនេះ ហ៊ុន សែន អាចនឹងអរគុណ សម រង្ស៊ី ដែលមិនបានបញ្ចេះម៉ាស៊ីន"យល់ត្រូវ"របស់ពលរដ្ឋ ពីព្រោះជាឱកាសប្រសើរបំផុតនោះ បានកន្លងផុតមិនដឹងពេលណានឹងកើតម្តងទៀតទេ ។ "ម៉ាឡាឡា"អាយុ១៦ឆ្នាំតស៊ូការពារសិទ្ធកុមារនឹងស្ត្រីមូស្លីម បានត្រូវ "តាលិបាន"បាញ់សម្លាប់ ដើម្បីបំបិតមាត់តែនៅពេលដែលពេទ្យបានសង្គ្រោះនាងបានរួចជីវិតមកវិញ នាងបន្តនិយាយឡើងវិញនៅអង្គការសហ-ប្រជាជាតិ នៅអាមេរិក នៅអង់គ្លេសថា "គ្រាប់កាំភ្លើងមិនបានប្តូរម៉ាឡាឡាអ្វីបានទេ នាងនៅតែជាសម្លេងរបស់ស្ត្រីមូស្លីមនឹងកុមារដែលរងគ្រោះដោយសាសនាមូស្លីមរបស់ក្រុមតាលីបានតែដដែល"៕

"ព័ត៌មានអន្តរជាតិ"

# ភូមាកំពុងស្វែងរកប្រធានាធិបតី

**ដោយ ពិន សំខុន**

លោកស្រី អូន សាន់ស៊ូជី បានឈ្នះឆ្នោតដ៏ត្រចះត្រចង់នាឆ្នាំ២០១៥ជាថ្មីម្តងទៀត បន្ទាប់ពីបានឈ្នះឆ្នោតពីលើកមុននាឆ្នាំ១៩៩១ បានប្រមាណ ៥៩% តែក្រុមផ្តាច់ការនិយមយោធាឡើងកាន់អំណាចខ្លួនឯងដោយរដ្ឋប្រហារយ៉ាងឃោរឃៅបានចាប់លោកស្រីនឹងសមាជិកសំខាន់ៗរបស់លោកស្រីដាក់គុកជាង២០ឆ្នាំ។ ឆ្នាំ២០១៥នេះ បន្ទាប់ពីចេញពីគុកគណបក្សលោកស្រីបានឈ្នះឆ្នោត៦៧%សាជាថ្មីលើក្រុមយោធា (គ្រប់គ្រងអសនសភា៨៥% -ប៉ុន្តែកាលពីនៅពេលពួកយោធាទាំងនោះកាន់អំណាចបានធ្វើច្បាប់រាំងស្ទះលោកស្រី សាំនស៊ូជី កុំឱ្យឡើងកាន់ដំណែងបានដោយរដ្ឋធម្មនុញ្ញថ្មីភូមាមិនអនុញ្ញាត្តិឱ្យអ្នកឡើងជាប្រធានាធិបតីមានគ្រួសារជាជនបរទេសនោះទេ (លោកស្រី សាំនស៊ូជី មានប្តីជាជនអង់គ្លេស តែស្លាប់នឹងកូនពីរនាក់ជាជនជាតិអង់គ្លេស ហើយរស់នៅប្រទេសអង់គ្លេស) ហើយមាត្រាផ្សេងមួយទៀត បានអនុញ្ញាតិឱ្យយោធាមានសិទ្ធកាន់កាប់សម្លេងស្វ័យប្រវត្តិនៅសភាជាតិ ២៥%។





នៅខែមិនា២០១៦នេះ គេមិនដឹងថា តំណែងប្រធានាធិបតីនឹងបានទៅនរណានៅឡើយ អូន សាំនស៊ូជី ឬ ថាន សែន?

លោកស្រី សាំនស៊ូជី នៅតែនិយាយថា "លោកស្រីនឹងទៅកាន់ដំណែងជាប្រធានាធិបតីតែដដែល"។

ដើម្បីឱ្យងាយស្រួលយល់យើងគួរត្រឡប់ថយក្រោយបន្តិច ដើម្បីឱ្យឃើញថា "តើទិសដៅនៃដំណោះស្រាយនយោបាយភូមាវាបែរទៅខាងណា?"។

ឆ្នាំ២០១០រដ្ឋលេខាធិការអាមេរិកាំងនៃរដ្ឋបានអូបាម៉ា គឺលោកស្រី ហ៊ីឡារី ក្លីងតុន បានទៅជួប សាំនស៊ូជី នៅក្នុងគុក រួចទៅជួប ប្រធានាធិបតីយោធា ថាន សែន បណ្តាលឱ្យមានការដោះលែង សាំនស៊ូជី នឹងមន្ត្រីគណបក្សមួយចំនួនទៀតនៅមុនពេលបោះឆ្នោតភូមិភាគមួយ។ បន្ទាប់ពីការបោះឆ្នោតនោះ លោកស្រីនឹងសមាជិកគណបក្សមួយចំនួនបានឈ្នះឆ្នោត ហើយក៏ចូលទៅធ្វើការនៅសភាបើកការចរចារប្តូរច្បាប់បន្តបន្ទាប់ជាមួយគណបក្សយោធានិយម រីឯប្រទេសភូមាក៏ផ្តើមមានការទទួលស្គាល់ពីអាស៊ានពីសហគមន៏អឺរ៉ុបពីសហរដ្ឋអាមេរិកបើកទ្វាររកស៊ីទៅខាងក្រៅប្រទេសឡើងវិញបាន បន្ទាប់ពីទ្វារដដែលនោះបានត្រូវបិតជាង២០ឆ្នាំ មកហើយ។



ក្នុងពេលរួចមានសេរីភាព ហើយធ្វើការជាតំណាងរាស្ត្រថែមទៀតនោះ លោកស្រី អូន សាំនស៊ូជី បានធ្វើដំណើរទៅយកពានរង្វាន់ណូបែលនៅអឺរ៉ុប ដែលខ្លួនមិនបានមកទទួលកាលពី២១ឆ្នាំមុន -ធ្វើដំណើរទៅសាកលវិទ្យាល័យ "អុកស្វឹត" ដែលលោកស្រីធ្លាប់ជានិស្សិតនៅទីនោះ -ធ្វើដំណើរមក "វិមានកាពីតូល" នៃសហរដ្ឋអាមេរិកទាំងនេះបាននាំមកនូវការទទួលស្វាគមន៏នឹងការគាំទ្រចលនាកែរទម្រង់លទ្ធិប្រជាធិបតេយ្យយ៉ាងខ្លាំងខ្លាថា ជា "គំរូវិរភាពរបស់ពិភពលោក"។ បន្ថែមពីលើការគោរពកោតសសើរឆ្លងពិភពលោករួចមក លោកប្រធានាធីបតីបារ៉ាកអូបាម៉ាបានបង្ហាញពីទស្សនៈនយោបាយដ៏ត្រជាក់មួយដែលនិយាយពីការផ្លាស់ប្តូរ សម្រាប់ប្រយោជន៏ប្រជាជនក្រីក្រដោយមានការពិគ្រោះ ចរចារគ្នា ឱ្យមានទៅជួបសម្តែងការគោរពនូវវិរភាពលោកស្រី សាំនស៊ូជី នៅគេហដ្ឋានលោកស្រីនៅឆ្នាំ២០១៤តែម្តង ហើយដាក់សម្ពាតទៅរដ្ឋាភិបាលយោធាថា "លោកលើកទឹកចិត្តឱ្យរដ្ឋាភិបាលបន្តកែទម្រង់ថែមទៀត ពីព្រោះច្បាប់នៃរបបប្រជាធិបតេយ្យតម្រូវឱ្យមនុស្សមានសិទ្ធស្មើគ្នា"។

ទន្ទឹមគ្នានឹងការគាំទ្រពីក្រៅប្រទេសនៅក្នុងប្រទេស ការឃោសនារបស់គណបក្សលោកស្រីការយល់ព្រមរួម ទើបមានសន្តិភាព ជឿនលឿនទៅបាន។ នៅពេលអ្នកកាសែតសួរថា "នៅពេលដែលអ្នកឈ្នះ អ្នកនឹងបណ្តេញគេចេញឬ?" លោកស្រីឆ្លើយតបថា "អ្នកឈ្នះនឹងអ្នកចាញ់ជាសាស្ត្រភូមាដែលត្រូវរស់ជាមួយគ្នាជារៀងរហូតតទៅ អ្នកឈ្នះនឹងអ្នកចាញ់ ត្រូវចរចារគ្នាដើម្បីអភិវឌ្ឍន៏ស្រុកភូមិខ្លួនឯង"... លោកស្រីមិនបាន

**តទៅទំព័រទី ២៣**





តមកទំព័រទី ១២

# ក្រុមសិល្បៈ១៩៧៥

គូរគំនូរលើក្រដាសបាយដែលគេប្រើសំរាប់ការបរិភាគដូចជា "សាយរ" អគារផ្ទះល្វែងក្នុងស្រុក និងវិមានស្ថាបត្យកម្មនៅពេលបច្ចុប្បន្ននៅឯទីក្រុងភ្នំពេញដោយរួមបញ្ចូល បន្ទាលួស នឹងល្បែងតួត្រត្នាជាស្នាដៃសិល្បៈ។ នាងចង់បង្ហាញថា ដោយមានរូបភាពពណ៌នា ការជាប់ពន្ធនាគារ គឺជាការចូលរួមរបស់ជនរងគ្រោះដែលត្រូវបានគេបង្ខំអោយចាកចេញពីផ្ទះដោយសារតែពួកប្រឆាំងនឹងមូលធនខ្មែរក្រហម។

"អាលី" ក៏ដូចគ្នាដែរបានបង្ហាញពីស្នាដៃសិល្បៈរបស់នាងដែលដកស្រង់ពីតែស៊ុមវីដេអូរបស់នាងដែលហៅថា "កំហុសព្រះពុទ្ធសាសនា"។ បើទោះជានាងជាស្ត្រីម៉ូស្លីមខ្មែរ ហើយដោយមានការជំរុញពីព្រះសង្ឃព្រះពុទ្ធសាសនាពាក់ស្បង់ជីពរពណ៌ទឹកក្រូចប៉ុន្តែភាពមិនទំនងនិងសំលៀកបំពាក់ពណ៌ទឹកក្រូចបែបកំប្លែងរបស់នាងជាដង្ហូវយក្សដែលបានបង្ហាញជុំវិញតំបន់សាធារណៈនៅក្នុងរាជធានីភ្នំពេញដែលធ្វើឱ្យជនស៊ីវិលក្នុងស្រុកជជែកពីរូបរាងចម្លែករបស់នាងនៅក្នុងភោជនីយដ្ឋានសួនកម្សាន្តក្លិបរាត្រី។ គោលបំណងរបស់នាងគឺដើម្បីចែករំលែកអត្តសញ្ញាណរបស់នាងដែលជាស្ត្រីម៉ូស្លីមខ្មែរខណៈពេលដែលមានការបរិយាយនូវបទដ្ឋានសង្គមនៃពុទ្ធសាសនានៅពេលដែលនាងបញ្ចេញនូវការអាក់អន់ស្រពន់ចិត្តរវាងអត្តសញ្ញាណរបស់នាងនិងសាសនាពេញនិយមបំផុតនៅក្នុងប្រទេសកម្ពុជា។

សិល្បករទាំងបីបានពន្យល់អំពីសិល្បៈសហសម័យនិងការខ្វះខាតនៃការបញ្ចេញស្នាដៃសិល្បៈរបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា ។ សិល្បៈហត្ថកម្មរបស់បុរសនៅក្នុងប្រទេសកម្ពុជាដូចជា ឆ្លាក់ សូន ស្ថាបត្យកម្មពិតប្រាកដនឹងសិល្បៈដែលមិនមានការទាក់ទងទៅនឹងសាសនា គឺពិតជាលើសលប់ណាស់ ខណៈពេលសិល្បៈសហសម័យនឹងសិល្បៈករស្ត្រីដែលគេមិនអើពើដោយសារតែមានការទាក់ទងទៅនឹងវប្បធម៌របស់ប្រទេសនេះ។

"សាផាន់" បានមានប្រសាសន៏ថា "បើយោងទៅតាមច្បាប់ទូន្មានខ្លួនស្ត្រីនៅក្នុងប្រទេសកម្ពុជាត្រូវតែចេះស្តាប់បង្គាប់នឹងគោរពបុរស ប៉ុន្តែពួកយើងចង់ធ្វើពួកគេមានឧត្តមគតិផ្សេងទៀត។ "ទីក្រុងមួយចំនួននៅក្នុងទីក្រុងញូវយ៉ក ដូចជាទីក្រុង ខ្វីន (Queen) នឹងប្រូកខ្លីន (Brooklyn) ឡុងបេច (Long Beach) ខាលីហ្វញ៉ា (California) នឹង វែសលេសលី មាសាឈូសេត (Wellesley, MA) គឺជាកន្លែងដែលគួរឱ្យកត់សំគាល់មួយដើម្បីបង្ហាញការងារសិល្បៈរបស់ពួកគេ។ សិល្បៈករស្ត្រីទាំងបីរនេះ កាលពីមុនមកធ្លាប់បានបង្ហាញសិល្បៈរបស់ពួកគេជាឯករាជ្យមួយ នៅឯទីក្រុងដូចជា ឈីការគូ (Chicago) ប៊ូស្តុន (Boston) ឡុងដុង (London) ផារីស (Paris) នឹងទីក្រុងភ្នំពេញ (Phnom Penh) ។ ១៩៧៥ គឺជាក្រុមការតាំងពិព័រណ៏ រៀបចំដឹក នាំដោយ (ជួងដាយវ៉ៃ Chuong Dai Vo) និងការឧបត្ថម្ភដោយអង្គការសិល្បៈ (តូពេស Topaz) ដែលមានទីតាំងស្ថិតនៅ "វូដសាយ Woodside" ទីក្រុងញូវយ៉ក៕

Continued from page 12

# 1975 Group Exhibition...

inspired by Buddhist monks wearing an orange robe, had been showcase around the public area in Phnom Penh - making the local civilians questioning her strange appearance in restaurants, amusement parks, night clubs, etc. Her purposes were to share her identity as a Muslim Khmer woman while depicting the social norm of Buddhism as she is subjectively exposing her everyday resentments between her identity and the most popular religion in Cambodia.



These three artists explained how contemporary artsand women artists have the lack of exposure in Cambodia. Male artists crafting traditional arts such as sculptures, authentic architectures, and non-secular artworks have been predominated in Cambodia while contemporary arts and women artists have been neglected for cultural reasons.

"Cambodian women must be submissive and obedience to men according to the 'code of conduct'," said Saphan. "We want to impact women to a different ideal."

Some cities in New York like Queen and Brooklyn were their notable places to showcase their artistic works, and alsowith Long Beach, CA and Wellesley, MA.These three women artists, sometime, had exposed their artworksindependently in the past such as Chicago, Boston, London, Paris, Phnom Penh, etc. 1975 is group exhibit curated by Chuong Dai Vo and sponsors by TOPAZ ARTS located in Woodside, New York.

AccuCare
Home Care Agency
Group Adults Foster Care Program

**កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ**

*កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើងតាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។*

*ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :*
- *រស់នៅផ្ទះរដ្ឋ*
  *អាយុ ២២ ឆ្នាំឡើងទៅ*
- *មាសហែលស្តង់ដា*

*ផលប្រយោជន៏ទទួលបាន :*
- *ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការ រស់នៅប្រចាំថ្ងៃ*
- *ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក*
- *ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ*
- *វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់*
- *សមាជិកអាចទាក់ទងមក ២៤ម៉ោង*

***To be eligibled for GAFC you must:***
- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***
- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

ដើម្បីចុះឈ្មោះសូមទាក់ទងមក
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

## តមកទំព័រទី ១៦ រដ្ឋាភិបាលចុះកិច្ចព្រមព្រៀងតភ្ជាប់...

យោងតាមក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានឱ្យដឹងថា គិតត្រឹមខែធ្នូ ប្រទេសកម្ពុជាមានអ្នកប្រើប្រាស់អ៊ីនធឺណិត៦.៧លាននាក់ គឺជាង៤០ភាគរយនៃប្រជាជនសរុប កើនឡើងតែជាង១ភាគរយប៉ុណ្ណោះបើធៀបនឹងចំនួនប្រជាជនសរុបក្នុងឆ្នាំ២០១០។

លោក កាន ច័ន្ទមេត្តា រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានមានប្រសាសន៍ថា ខ្សែកាបក្រោមសមុទ្រនេះនឹងជួយបំពេញតាមតម្រូវការនាពេលអនាគតទាំងសម្រាប់ក្រុមហ៊ុនចែកចាយ និងអ្នកប្រើប្រាស់រួមទាំងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ផងដែរ។

លោក ច័ន្ទមេត្តា បានមានប្រសាសន៍ថា "យើងអាចឆ្លើយតបចំពោះតម្រូវការប្រចាំឆ្នាំដែលមានការកើនឡើងសម្រាប់ការប្រើប្រាស់អ៊ីនធឺណិតពីអ្នកប្រើប្រាស់"។

លោកបានបន្ថែមថា "ប៉ុន្តែប្រសិនបើយើងមិនអភិវឌ្ឍការតភ្ជាប់បណ្តាញឱ្យបានកាន់តែល្អប្រសើរទេនោះ ប្រជាពលរដ្ឋនឹងមិនអាចប្រើប្រាស់ទិន្នន័យទៅតាមសមត្ថភាពរបស់ខ្លួនបានឡើយ ហើយល្បឿននឹងរអាក់រអួល"។

លោកបានថ្លែងថា "លោកនាយករដ្ឋមន្ត្រីប្រើប្រាស់ហ្វេសប៊ុករាល់ថ្ងៃ...ដូច្នេះហើយលោកចង់បានអ៊ីនធឺណិតដែលមានល្បឿនលឿន"៕

**សារុន**


# រកជាងធ្វើក្រចក

Nail technician wanted in Wilmington Ma

នៅ"វិលមិនតុន" រកជាងធ្វើក្រចកភេទស្រីមានបទពិសោធន៍

-ហើយអាចប្រស្រ័យទាក់ទងជាមួយភ្ញៀវជាភាសាអងគ្លេសបានខ្លះ ។

សូមទូរស័ព្ទរក អាន់ **(617-602-6183)** ឬរក ប្រាយិន **(617-669-6689 )**


## តមកទំព័រទី ២១ ភូមាកំពុងស្វែងរកប្រធានាធិបតី...

សម្តែងការខឹងសម្បារនឹងការដាក់គុកចំពោះរូបលោកស្រីទេ តែបានសម្តែងការអាណិតអាសូរដ៏ជ្រាលជ្រៅនឹងជាប្រចាំដល់ប្រជាជនក្រីក្រជាច្រើន ដែលមិនបានទទួលភាគផលនៃការជឿនលឿនចូលអ្នកដ៏ទៃ លោកស្រីបន្ទោសដល់ប្រព័ន្ធសិក្សាធិការមិនទាន់សម័យ ដែលមិនបានផ្តល់ឱ្យកុមារភូមាតាំងតែពី៥០ឆ្នាំមកហើយ ដែលជាបុព្វហេតុនៃសេចក្តីក្រីក្រនោះ។

មានទុន២៥%នៃសម្លេងសភា គឺក្រុមយោធានិយម អាចនឹងកាន់កាប់ដំណែងជាប្រធានាធិបតីបាន បើគណបក្សទី១មិនមានបេក្ខជនស្របច្បាប់ទេនោះ តែលោកស្រី សាំនស៊ូជី សង្ឃឹមថានឹងអាចប្តូរច្បាប់នេះបានដោយសារច្បាប់នេះវាផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញដែរ ហើយពិសេសទៅទៀតនោះ លោកស្រី សាំនស៊ូជី មិនដែលបង្ហាញពីការគុំគួន ឬសងសឹកដល់ក្រុមរដ្ឋអំណាចយោធាម្តងណាទេ ។ ទស្សនៈនយោបាយលោកស្រីស្ថិតនៅរឹងមាំចំពោះគោលការប្រជាធិបតេយ្យនឹងការគោរពច្បាប់ជាធរមាននៅក្នុងនិតិរដ្ឋដែលទោះជាគម្រាមដោយកាំភ្លើងក៏មិនអាចធ្វើឱ្យលោកស្រីភ័យខ្លាចដែរ ។

ក្នុងរូបភាពនេះ លោកស្រីបានជំនួស "ការបះបោរ" ឱ្យទៅជា "ដំណោះស្រាយនយោបាយ" នឹងកែប្រែច្បាប់ឱ្យស្របតាមគោលការប្រជាធិប-តេយ្យ ដែលក្នុងនោះមនុស្សត្រូវមានសិទ្ធស្មើគ្នាឡើងកាន់ដំណែងដោយមានការព្រមព្រាងគ្នាហើយទាំងអស់គ្នានឹងទទួលផលចំណេញរៀងៗខ្លួនក្នុងប្រជាជាតិតែមួយ។

បរិយាកាសនោះបានកើតឡើងខ្លះទៅហើយដោយលទ្ធផលនៃសន្លឹកឆ្នោត បានឱ្យជ័យជំនះដល់គណបក្សលោកស្រី អូន សាំនស៊ូជី ខាងកងទ័ពក៏និយាយថា ខ្លួននឹងប្រគល់អំណាចជូនអ្នកឈ្នះ រីឯលោកស្រី សាំនស៊ូជី ក៏បាននិយាយថា "នឹងទៅកាន់អំណាចដោយសារច្បាប់ដែលរៀបចំឡើងដោយគណបក្សលោកស្រីជាមួយនឹងគណបក្ស យោធាលោក ធាន សែន"។

ដូច្នេះអ្នកដែលឈ្នះ ពិតប្រាកដនាចុងខែមិនាឆ្នាំ២០១៦នេះ គឺប្រជាជាតិទាំងមូលដែលរង់ចាំមើលសន្តិភាពនឹងមកដល់រង់ចាំរួមចំណែកអភិវឌ្ឍន៍របស់ប្រទេសរង់ចាំអនាគតគ្រួសារដែលខ្លួនអាចមើលឃើញច្បាស់ជាងពេលមុនៗ ៕

## តមកទំព័រទី ១១ "សប្តាហ៍សម្រាប់ក្មេងឡូវែល "...

ម្តាយនិងអ្នកលក់បានពិពណ៌នាពីសកម្មភាពរបស់ពួកគេដែលបានផ្សារភ្ជាប់ទៅនឹងសកម្មភាព តែមិនបានយល់ពីអត្ថន័យពិតប្រាកដទេ។

អ្នកស្រី "ឡេសលី វ៉ុង Leslie Wong" ដែលជាប្រជាជននៅទីនេះ និងជាម្តាយម្នាក់ផងដែរបាននិយាយថា" ក្មេងៗមិនបានមកទីនេះ ដើម្បីយល់ពីអង្គការសហគមន៍ទេ តែពួកគេមកដើម្បីទទួលយកភាពសប្បាយរីករាយពីពួកគេ"។ អ្នកស្រីបានពន្យល់ថា អង្គការជាច្រើនមកទីនេះដើម្បីមានឱកាសក្នុងការបង្កើតទំនាក់ទំនងពីគ្នាទៅវិញទៅមក។

"អូរូរាអេរិកសាន់ Aurora Erickson" ដែលជាអ្នក "សំរបសំរួលកម្មវិធីតំបន់អេ គឺបានប្រសើរ Coalition for a Better Acre" បានមានប្រសាសន៍ថា" មនុស្សជាច្រើនមិនបានដឹងពីធនធានដែលមាននៅទីនេះទេ ហើយពួកគេក៏មិនបានដឹងពីឪកាសជាច្រើនដើម្បីធ្វើឱ្យក្មេងៗបានចូលរួមដែរ" ។ សកម្មភាពតាមតូបរបស់ពួកគេ គឺតំរូវឱ្យឪពុកម្តាយ ឬក្មេងៗសរសេរ ឬគូរអ្វីមួយលើផ្ទាំងរូបភាពពីរផ្សេងគ្នាពីអ្វីដែលពួកគេចូលចិត្ត ឬមិនចូលចិត្តពីតំបន់ដែលពួកគេរស់នៅ។ "អេរិកសាន់" ចូលចិត្តធ្វើការជាមួយក្មេងៗពីតំបន់ផ្សេងៗគ្នា ហើយវាពិតជាមានន័យ ចំពោះនាងដែលបានឃើញមានការចូលរួមពីសហគមន៍ផ្សេងៗគ្នានៅក្នុងព្រឹត្តិការណ៍នេះ។

"សប្តាហ៍ក្មេងក្នុងទីក្រុងឡូវែល" បានបញ្ចប់នៅថ្ងៃទី ១៤ ដល់ ២០ ខែកុម្ភៈ។ "សប្តាហ៍ក្មេងក្នុងទីក្រុងឡូវែល"លើកក្រោយនឹងចាប់ផ្តើមនៅវិស្សមកាលខែមេសា -កាលវិភាគនឹងបិទផ្សាយក្នុងពេលឆាប់ៗ៕


# បន្ថយចំណាយថ្លៃភ្លើង និងហ្គាស

ខែរងាមកដល់ ចំណាយថ្លៃភ្លើង និងហ្គាស និងឡើងថ្លៃគួរឱ្យបារម្ភ

-ចង់បញ្ចុះតម្លៃពី២០-៤០% សូមទូរស័ព្ទមក

**Alex: 978-569-6034**

**Pin Samkhon: 978-942-1641**



# ទូលព្រះបង្គំមិនហ៊ានរាយការណ៍ទេ ទាន ! (ភាគ៧)

**តពីលេខមុន**



នាងប្រមូលបានសេវាទាំងប៉ុន្មានយកមកថ្វាយអាត្មាអញទាំងអស់ទេ តើចែកនាងតាមនាងចង់បានទៅវាល្មតើចាំទៅលំបាកគិតអី...។ ស្រាប់តែរូបភាពទេវតាក្បាលរឹងហ៊ានមកស្លាប់ដើម្បីឱ្យតែបានទូលរឿងពិតនោះពិតជាមិនធម្មតាទេ អានេះប្រហែលជានាំទុក្ខមកឱ្យអាត្មាអញប្រាកដហើយ វាក្លាហានណាស់ ម៉ឺងម៉ាត់ណាស់ វាពឹតជាទូលព្រះសក្កទេវរាជពីរឿងរញ៉ីរញ៉ៃនៃអាត្មាអញមិនខានឡើយ!!! ធ្វើយ៉ាងណាអេះឱ្យរួចផុតពីទម្ងន់ទុកនេះ? សម្លាប់វាបំបាត់តាងទៅ! ឱ្យត្វាតទេ ពហែកចែកគ្នាស៊ីននៅឯល្ហាងទេពឥន្ទ្រីទៅ វាពិតជា"អេមរ៉ូហើយ" តែវិចារណញ្ញាណរបស់អាត្មាអញទៅឯណាអស់ហើយ។ "ទេពលេខាធិការដ៏កំសត់នៃអាត្មាអញអើយ!!!ទេ...ទេ...មុននឹងធ្វើអ្វីមួយត្រូវគិតឱ្យបានល្អិតល្អន់ពីផលវិបាករបស់វា!...ទេទេ...កម្មនឹងផល...ផលនឹងកម្ម។ ទេពអគ្គលេខាធិការបានភាវនាទាន់នូវប៉ាវច្ចនាដែលបញ្ចៀសព្រះអង្គចេញពីសតិទោសៈមោហៈនេះបានដែលនាំឱ្យចាកផុតពីមាគ៌ាឆ្ពោះទៅរកប្រែតនរកអាវិចីឬអាបាយអាភូមិបាន។ ស្រាប់តែពេលនោះព្រះអង្គទ្រង់នឹកឃើញទាំងព្រមដែរ នូវអ្វីដែលព្រះអង្គខំកកាយរកសឹងតែចេញផ្សែងក្នុងខួរក្បាលរបស់ព្រះអង្គទៅហើយ។ ព្រះអង្គយាងឆ្ពោះទៅកាន់ទេវតាកំសត់នោះពីក្រោយខ្នង ហើយយកព្រះហត្ថាស្តាំដាក់ថ្នមៗលើស្មាស្តាំរបស់ទេវតាកំសត់ ទេវតាអង្គនេះយកព្រះហត្ថាខ្លួនចាប់ជាប់ព្រះហត្ថានោះហើយបែរមួយជុំមកក្រោយក៏យល់ច្បាស់ថា ទេពអគ្គលេខាធិការកំពុងដាក់ហត្ថាព្រះអង្គលើស្មាខ្លួន ទើបទេវតាអង្គនេះលុតជង្គង់ចុះប្រណមដោយគោរពនឹងបីតិញាប់ញ័រហួសពីការទ្រាំទ្ររបស់ខ្លួនទឹកព្រះនេត្រហូររហាមហារស្ទីមិនចេញ... ទេពអគ្គលេខាធិការឱនចុះខ្សឹបដាក់ព្រះកានតិចៗមិនឱ្យឮដល់ទេវតាតំណាងផ្សេងៗ "ឃ្លាំងមឿងជាទីស្រឡាញ់នឹងគោរព! ហេតុអ្វីបានទៅជាយ៉ាងណឹង? ហេតុម៉េចទៅ??" ទេវតាកំសត់នេះក៏លូនទៅឱបព្រះបាទាទាំងទ្វេរបស់ទេពអគ្គលេខាធិការដោយខ្សឹកខ្សួលឃាត់មិនឈ្នះសោះ។

ទេពអគ្គលេខាធិការទតសង្កេតយ៉ាងយកព្រះទ័យទុកដាក់ចំពោះទេវតាអង្គនេះជាលើកដំបូងដែលព្រះង្គហាក់មិនដែលធ្លាប់សង្កេតពិនិត្យយ៉ាងនេះម្តងណាសោះឡើយ។ ក្នុងដួងហឫទ័យរបស់ព្រះអង្គកំពុងតែនឹកឃើញរឿងអ្វីមួយស្រពេចស្រពិលមិនច្បាស់ទេវតាអង្គនេះជាទេវតាតំណាងមកពីក្រុងទេពមហាណាក់ខនទៅវិញ ហើយមកតាំងទីនៅប្រាសាទព្រះវិហាដើម្បីអភិរក្សប្រាសាទនានាលើប្រទៃប្រទេសនៃនគរគោកធ្លកទៅវិញ??? វាម៉េចចឹងទៅវិញ? ធម្មតាត្រូវតាំងទីនៅឯរាជធានីអង្គរឬយ៉ាងហោចណាស់ក៏ត្រូវនៅឯក្រុងចតុមុខទើបត្រូវ។ ព្រះអង្គមិនព្រមចោទ សួរទេវតាអង្គនេះឱ្យបកស្រាយនូវចំងល់នេះថ្វាយព្រះអង្គទេ ព្រោះហាក់ដូចមានរឿងអ្វីអាថ៌កំបាំងផ្សេងទៀតបង្កប់នៅក្នុងទេវតាអង្គនេះ។ គេនេះជានរណាឱ្យពឹតប្រាកដទៅអេះ? អាត្មាអញហាក់ដូចចាំច្បាស់ថា គេនេះធ្លាប់មានរូបរាងសង្ហា, ឫកពារអង់អាច, ក្លាហាន, ភ្នែកមុត, សំដីម៉ឺងម៉ាត់តែពីរោះ ពេលបញ្ចេញវាចារម្តងៗអង្គប្រជុំតែងស្ងាត់ជ្រាប...។ ឥឡូវនេះគេមែនជាទេវតាអង្គណឹងឬទេ? ម៉េចក៏ឫកពារខាងក្រៅមិនដូចពីមុនសោះអញ្ចឹង? ការស្លៀកពាក់គ្រប់ដណ្តប់សំពត់អាវស្បៃដូចជាទេវតាជាប់ពិរុទ្ធៈពិរុទ្ធជនទេវៈឬយ៉ាងណាអញ្ចេះ?...ជាទេវតាបែបជា...ដោយខំកកាយរក, ត្រិះរិះក្នុងខួរក្បាលសឹងតែហុយផ្សែងព្រះអង្គកាត់មិនយល់សោះក៏ទ្រង់យាងចេញពីអាសនៈ ហើយចុះមកកាន់ទេវតាទាំងឡាយនោះ **តទៅលេខក្រោយ**


LOWELL ELDER CARE
978-596-1111

## មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

**345 Chelmsford St. Lowell, MA 01851/ – www.lowelleldercare.com**

### អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ៏កក់ក្តៅមួយ ដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

### ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។





### មណ្ឌលផ្តល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

### Our Services

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips

**សូមហៅលេខទូរស័ព្ទ (978) 596-1111**

**State of Rhode Island**
**DEPARTMENT OF TRANSPORTATION**

The State of Rhode Island has the following opportunity available within The DEPARTMENT OF TRANSPORTATION:
***BRIDGE MAINTENANCE WORKER***

***Salary:*** ***$17.39 - $18.29 Hourly * $36,171.20 - $38,043.20 Annually***
***Location:*** ***Warwick, Rhode Island***
***Schedule:*** ***Monday-Friday; 7:00 AM - 3:30 PM; 40 hour work week; Overtime 1.5x***

The Bridge Maintenance Workers Duties include: To assist in the field supervision of and to participate in the work of a crew engaged in the repair, cleaning sandblasting, sealing, painting, alteration and construction of highway bridges; and to do related work as required.

***Qualifications:***

- **Education:** Such as may have been gained through: graduation from a senior high school; and
- **Experience:** Such as may have been gained through: employment in heavy construction or in the maintenance of highway bridges or similar structures or employment in the fabrication of materials for bridge or similar structure repairs.
- **SPECIAL REQUIREMENTS:** Must possess and maintain a valid Commercial Driver's License, Class B with airbrake and tanker endorsements. Compliance with the USDOT Federal Regulations of the Omnibus Transportation Employee Testing Act of 1991 and the State of Rhode Island's Drug & Alcohol Testing Program Policy & Procedures is a mandatory requirement and a condition of continued employment.

Incumbents in this class are exposed to extremes of weather, to lifting of heavy materials, to dangerous road and traffic conditions, including exposure to heights, poison plants, insect bites and allergy irritants, and to loud and potentially dangerous machinery. At the time of appointment must have adequate physical strength, stamina, physical agility, visual and auditory acuity, and must maintain such physical fitness as to be able to perform assigned duties. A physical examination, with spirometry and respiratory clearance, as evidenced by a physician's certificate, is required.

**TO APPLY:** Please visit the APPLY RI Website at: www.Apply.RI.gov

**An Equal Opportunity Employer**

***State of Rhode Island***
**DEPARTMENT OF TRANSPORTATION**

The State of Rhode Island has the following opportunity available within The DEPARTMENT OF TRANSPORTATION: **HIGHWAY MAINTENANCE OPERATOR I** (*Equipment Operator/Driver*)

***Salary:*** ***$16.63 - $17.44 Hourly *** $34,590 - $36,275 Annually***
***Location:*** ***Opportunities Available Statewide-Visit Site for Exact Locations***
***Schedule:*** ***Monday thru Friday, 7:00 AM - 3:30 PM; 40 hour work week; 1.5x Overtime***

To perform skilled labor and specialized operation of a variety of heavy construction and maintenance equipment used in the repair of highway pavements, shoulders, roadsides, and drainage, signage, and in the control of snow and ice; may be assigned a variety of skilled maintenance tasks in support of bridge, traffic, roadside, and facility maintenance programs; also performs preventive maintenance on assigned equipment; and performs related work as required.

***Qualifications:***

- **Education:** Education: Such as may have been gained through: possession of a high school degree or equivalency, and supplemented by courses in mechanics: and
- **Experience:** Such as may have been gained through: considerable employment in the operation of highway maintenance, construction, or other heavy equipment in excess of 36,000 lbs GVW with airbrakes and manual transmissions.
- **OR, any combination of education and experience** that shall be substantially equivalent to the above education and experience.
- **SPECIAL REQUIREMENTS:** At the time of appointment must possess and maintain a valid Rhode Island Commercial Driver's License, **Class B** with tanker endorsements. Compliance with the USDOT Federal Regulations of the Omnibus Transportation Employee Testing Act of 1991 and the State of Rhode Island's Drug & Alcohol Testing Program Policy & Procedures is a mandatory requirement and a condition of continued employment. Incumbents in this class are exposed to extremes of weather, to lifting of heavy materials, to dangerous road and traffic conditions, including exposure to heights, poison plants, insect bites and allergy irritants, and to loud and potentially dangerous machinery. At the time of appointment must have adequate physical strength, stamina, physical agility, visual and auditory acuity, and must maintain such physical fitness as to be able to perform assigned duties. Must be physically qualified to perform assigned duties as evidenced by a physician's certificate.

**TO APPLY:** Please visit the APPLY RI Website at: www.Apply.RI.gov

**An Equal Opportunity Employer**

## NOTICE OF PUBLIC MEETING

The Northern Middlesex Metropolitan Planning Organization (NMMPO) will meet on March 8th at 2:00 PM at NMCOG offices, 40 Church Street, Suite 200, in Lowell. The meeting is open to the public and will include a discussion of comments received on a draft amendment to the Transportation Improvement Program (TIP). The NMMPO will vote on whether to endorse the amendment. The NMMPO will also vote on whether to release a draft Public Participation Plan for public comment. For more information, go to www.nmcog.org.

Notice: This meeting location is accessible to people with disabilities and is near public transportation. NMCOG offers secure bicycle parking on the second floor. The NMMPO provides reasonable accommodations and/or language assistance free of charge upon request (including but not limited to interpreters in American Sign Language and languages other than English, open or closed captioning for videos, assistive listening devices and alternate material formats), as available. For assistance, please contact Justin Howard at (978) 454-8021, ext 121 or at jhoward@nmcog.org. Requests should be made as soon as possible for services requiring advanced arrangements, including signlanguage, CART or language translation or interpretation.

## ជូនដំណឹងសាធារណៈ ពីកិច្ចប្រជុំ

"អង្គការផែនការរៀបចំគំរោងទីក្រុងនៅមិដរសិចប៉ែកខាងជើង"The Northern Middlesex Metropolitan Planning Organization (NMMPO) នឹងបើកការប្រជុំនៅថ្ងៃទី៨ ខែមីនា វេលាម៉ោង២ នៅឯការិយាល័យ NMCOG ផ្លូវ៤០ Church, Suite ២០០ ក្នុងទីក្រុងឡូវែល។ ការប្រជុំនេះនឹងបើកជាសាធារណៈ ហើយ និងរួមបញ្ចូលការពិភាក្សាទាក់ទងពីមតិដែលបានទទួលពីវិសោធនកម្មព្រាងមួយច្បាប់ដែលបានផ្ញើរទៅកាន់ "កម្មវិធីកែរលំអការធ្វើដំណើរTransportation Improvement Program (TIP) ។ "អង្គការផែនការរៀបចំគំរោងទីក្រុងនៅមិដរសិចប៉ែកខាងជើង" The NMMPO នឹងធ្វើការបោះឆ្នោតសម្រេចគាំទ្រវិសោធនកម្មនោះ។ The NMMPO ក៏នឹងធ្វើការបោះឆ្នោតផងដែរ សម្រេចត្រូវបញ្ចេញសេចក្ដីព្រាងផែនការចូលរួមសាធារណPublic Participation Plan សំរាប់ឱ្យសាធារណៈជនបញ្ចេញមតិ ។ សំរាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ www.nmcog.org ។

**សេចក្ដីកត់ចំណាំ:** ទីតាំងនៃការប្រជុំនេះ ផ្ដល់ភាពងាយស្រួលដល់ជនពិការ និងនៅជិតការដឹកជញ្ជូនសាធារណៈ។ NMCOG ផ្ដល់កន្លែងចតកង់ដែលមានសុវត្ថិភាពនៅជាន់ទីពីរ។ The NMMPO ផ្ដល់កន្លែងស្នាក់នៅដែលមានតំលៃសមរម្យ និងមិនគិតថ្លៃចំពោះការស្នើសុំជំនួយផ្នែកភាសា(រួមបញ្ចូល ប៉ុន្តែមិនមានកំណត់ចំពោះការបកប្រែ ភាសា KrAmerican Sign Language ហើយ និងភាសាក្រៅពីភាសាអង់គ្លេស។ ផ្ដល់ជូននៅការបើក ឬបិទការបរិយាយសំរាប់វីដេអូ ផ្ដល់ជូនសំភារៈជំនួយការស្ដាប់ និងសំភារៈជំនួសផ្សេងៗទៀត។ (សំរាប់ផ្នែកជំនួយ សូមទាក់ទងលោក Justin Howard ដែលមានលេខទូរស័ព្ទ (៩៧៨) ៤៥៤-៨០២១, ខេត ១២១ឬតាមរយៈអ៊ីម៉ែល jhoward@nmcog.org ។ ការស្នើរសុំគួរតែធ្វើឱ្យបានកាន់តែឆាប់សំរាប់សេវាកម្មដែលតំរូវឱ្យមានការរៀបចំជាមុន រួមបញ្ចូលទាំងភាសាកាយវិកា CART ការបកប្រែភាសា ឬការបកប្រែផ្ទាល់មាត់៕



# ម្ជូរត្រកួនត្រីពង

**+គ្រឿងផ្សំ**

- ត្រីពង
- ត្រកួន
- ម្អម
- ខ្ទឹមស
- ម្ទេស
- អម្ពិលទុំ
- ប្រហុក
- អំបិល ស្ករ ប៊ីចេង

**+វិធីធ្វើ**

មុនដំបូងលោកអ្នកគ្រាន់តែដាំទឹកឱ្យពុះទើបបង់ខ្ទឹមចិញ្រ្ចាំ និងត្រីពងចូលដំណាលគ្នា រួចនៅពេលដែលសម្លពុះម្តងទៀត សឹមជ្រំម្ជូរ អម្ពិលទុំ និងប្រហុកតិច ឬច្រើនតាមចំណូលចិត្ត ។ បន្ទាប់មកទៀតត្រូវបន្ថែមគ្រឿងផ្សំរសជាតិមាន អំបិល ស្ករ ប៊ីចេង ជាដើម រួចភ្លក្សសាបប្រៃតាមការគួរ មុននឹងបង់ត្រកួនចូលនោះជាការស្រេច ៕


B&M DISPOSAL 978-569-6062

ក្រុមហ៊ុនដឹកជញ្ជូនសំរាម ប៊ីអឹម



កុងទីន័រដាក់សម្រាម 30 YARD CONTAINER
រហូតដល់ ៤ តោន $549

កុងទីន័រដាក់សម្រាម 20 YARD CONTAINER
រហូតដល់ ៣ តោន $449

កុងទីន័រដាក់សម្រាម 15 YARD CONTAINER
រហូតដល់ ២ តោន $349

*សូមបង់ថែម $100 ក្នុង ១000 ផោនបន្ថែម ។ អនុញ្ញាតឱ្យដាក់បន្ថែមលើសទម្ងន់អតិបរមានៅលើកុងទីន័រណាមួយខាងលើបាន ។

សូមទាក់ទងឈ្មោះ ប៊ុន ឥឡូវនេះ!
មានផ្តល់សេវាជូនដល់ហាងទំនិញ និងតាមផ្ទះ




BUSINESS – RESIDENTIAL

*1687 Middlesex St. Lowell, MA 01851*

*CAll BUN* 978-569-6062

Neighborhood Physical Therapy




337 Westford Street. Lowell, MA 01851

978-455-4320

- Auto Accident Injuries
- Work Injuries
- We provide transportation

- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅកន្លែងធ្វើការ
- យើងខ្ញុំមានផ្តល់ការជញ្ជូនសម្រាប់លោកអ្នក

# វិធីងាយៗបំបាត់ក្លិនក្នុងផ្ទះ

ការសម្អាត និងការបំបាត់ក្លិនក្នុងផ្ទះ គឺជារឿងងាយស្រួលទេ សម្រាប់ស្រ្តីទូទៅតែបើចង់ឱ្យផ្ទះរបស់អ្នកមានក្លិនកាន់តែក្រអូបប្រកបដោយផាសុខភាពនោះ អ្នកអាចប្រើវិធីដូចតទៅ :



-ប្រសិនបើក្លិនសម្លអាហារពេលល្ងាចនៅតែជះភាយនៅក្នុងផ្ទះអ្នកគួរចាក់ប្រេងក្រអូបក្លិនវ៉ានីឡាប្រមាណ២-៣ស្លាបព្រាទៅក្នុងចានចង្កឹះ រួចយកទៅដាក់ក្នុងផ្ទះបាយ ហើយការធ្វើបែបនេះ វានឹងជួយស្រូបយកក្លិនអាក្រក់បាត់អស់ ។

-ដើម្បីឱ្យក្រណាត់ ឬខោអាវស្អាត ក្រអូបអ្នកត្រូវប្រាកដថា ទឹកក្នុងម៉ាស៊ីនបោកខោអាវរបស់អ្នកស្អាត ហើយអ្នកគួរសម្អាតថតសម្រាប់ដាក់សាប៊ូបោកខោអាវផងដែរ រួចបន្តក់ប្រេងក្រអូបក្លិនវ៉ានីឡា ទៅក្នុងទឹកថ្នាំបន្ទន់សាច់ក្រណាត់ ។ បន្ថែមពីលើនេះអ្នកអាចប្រើក្លិនវ៉ានីឡាទៅក្នុងទឹកថ្នាំបាញ់ពេលអ៊ុតខោអាវ ដើម្បីបន្ថែមក្លិនក្រអូបស្រស់ស្រាយផងដែរ ។

-បន្តក់ប្រេងក្លិនឡាវេនដឺរ ក្រូចឆ្មារ ឬក្រូច២-៣តំណក់ទៅក្នុងទឹកសម្រាប់ជូតផ្ទះ ព្រោះវាអាចជួយសម្លាប់មេរោគ និងបន្ថែមភាពក្រអូបស្រស់ស្រាយក្នុងផ្ទះថែមទៀត ។

-ដើម្បីកម្ចាត់ក្លិនក្នុងទូទឹកកក អ្នកគួរយកចានចង្កឹះមួយដាក់សូដាំប៊ីកាបូណាត ដើម្បីស្រូបយកក្លិន ហើយកុំភ្លេចរោយ





វាលើបាតនៃថតរក្សាទុកអាហាររបស់ទូទឹកកកផង ។

-នៅពេលចុចទឹកបង្គន់ អ្នកគួរបិទគម្របបង្គន់ជានិច្ច ព្រោះរាល់ពេលចុច ទឹកបង្គន់ អាចធ្វើឱ្យមានទឹកខ្ទាតចេញបាន ។ ដើម្បីបង្កើនភាពស្រស់ដល់បន្ទប់ទឹក អ្នកគួរប្រើប្រេងក្រអូបក្លិនរ៉ូសមេរីប្រមាណ១០តំណក់លាយជាមួយទឹកស្អាត១០០មីលីលីត្រ បាញ់ឱ្យសព្វបន្ទប់ទឹក ព្រោះក្រៅពីជួយឱ្យមានក្លិនក្រអូបវាថែមទាំងជួយសម្លាប់មេរោគទៀតផង ៕

# បន្លែបៃតងល្អបំផុត សម្រាប់អ្នកទឹកនោមផ្អែម



ការសិក្សាថ្មីបានរកឃើញថា ការប្រឈមខ្ពស់ចំពោះជំងឺទឹកនោមផ្អែមនឹងមានការថយចុះប្រសិនបើអ្នកបានទទួលទានបន្លែពណ៌បៃតងក្នុងបរិមាណច្រើន ។ ការសិក្សាស្រាវជ្រាវថ្មីនេះ បានធ្វើចំពោះមនុស្សប្រហែល១0000ម៉ឺននាក់អាយុចន្លោះពី៣0 ទៅ៧៤ឆ្នាំនៅអាមេរិក ចិន និងហ្វាំងឡង់ដ៍ ដើម្បីសិក្សាពីទំនាក់ទំនង រវាងបន្លែពណ៌បៃតងនឹងការថយចុះនៃជំងឺទឹកនោមផ្អែម ។

លទ្ធផលបានបង្ហាញថា អ្នកដែលទទួលទានបន្លែ និងផ្លែឈើដូចជា ស្ពៃ ផ្កាស្ពៃប្រូក ខូលី ស្ពៃក្តោប ។ល។ គួបផ្សំនឹងការហាត់ប្រាណជាប្រចាំអ្នកទាំងនោះនឹងថយចុះការប្រឈមនឹងជំងឺទឹកនោមផ្អែមប្រភេទ២ដល់ទៅ១៤ភាគរយ ។ មូលហេតុទាំងនេះ ក៏ដោយសារតែផ្លែឈើ និងបន្លែពណ៌បៃតងមានសារធាតុប្រឆាំងវ៉ាឌីកាល់សេរីច្រើន ដូចជាម៉ាញ៉េស្យូម អាស៊ីដខ្លាញ់អូមេហ្គា៣ដែលជួយឱ្យសុខភាពរឹងមាំល្អ ៕

# ចេកណាំវ៉ា ជួយបំបាត់ក្លិនមាត់



ចេកណាំវ៉ានៅពេលគេប្រៀបធៀបគ្នាជាមួយចេកអំបូង ព្រមទាំងចេកពងមាន់នោះ ចេកណាំវ៉ាវាផ្តល់ឱ្យគុណប្រយោជន៍ច្រើនជាង គេដូចជាផ្តល់ឱ្យថាមពលការងារខ្ពស់មានធាតុ ដែកជួយការពាររោគខ្វះឈាម មានកាល់ស្យូម ហ្វូសហ្វ័រស ព្រមទាំងវីតាមីន C ជួយប៉ូវបំប៉ន ឆ្អឹង ធ្មេញ និងអញ្ចាញ ។ លើសពីនេះទៅទៀត វាជួយសំរួលដល់ប្រព័ន្ធបន្ទោរបង់ឱ្យមានដំណើរកាន់តែស្រួលទៀតផង ។

ក្រៅពីចេកណាំវ៉ាមានប្រយោជន៍ដល់រាងកាយហើយនោះ នៅក្នុងរឿងសោភ័ណភាពចេកណាំវ៉ាជួយធ្វើឱ្យពណ៌សម្បុរស្បែកមានសុខភាពកាន់តែល្អប្រសើរទៀតផង ។ មួយវិញទៀតចេកណាំវ៉ាវាអាចជួយបំបាត់ក្លិនមាត់ដោយណែនាំឱ្យទទួលទានចេកណាំវ៉ាមុនពេលដុសធ្មេញរាល់លើក ។ វិធីនេះវា នឹងបង្ហាញឱ្យឃើញនូវលទ្ធផលក្រោយពេលព្យាយាមធ្វើមួយសប្តាហ៍ ៕

# ដែនជំរកសត្វស្លាបទឹក







●●●ដែនជំរកសត្វស្លាបទឹកនៅកម្ពុជា មានពាកន្លែងគឺ:

**១- ព្រែកទាល់ :** ស្ថិតនៅភូមិកំពង់ប្រហុក ភូមិអន្លង់តាអួរ ភូមិថាង ( ត្រង់ចំនុចឡូត៍នៃសាទ លេខ២) ក្នុងឃុំកោះជីវាំង ស្រុកឯកភ្នំ ជាប់ព្រំប្រទល់ ស្រុកសង្កែ តាមបណ្តោយព្រែកដា និងព្រែកស្តោត។ តំបន់នេះ គេសង្កេតឃើញមានសត្វព្រៃរស់នៅផ្តុំគ្នាដូចជា :សត្វស្លាបមាន ៦៤ ប្រភេទថនិកសត្វ១៤ប្រភេទ និងល្មូន១៩ ប្រភេទ។ ក្រុមទាំងនេះរស់នៅលើផ្ទៃដី ៩ គ.ម²

**២- បឹងឆ្មារ :**

ស្ថិតនៅក្នុងស្រុកស្ទោង ខេត្តកំពង់ធំ។ តំបន់នេះមានប្រភេទសត្វស្លាបដែលច្រើនគេប្រទះ ញឹកញាប់នៅរដូវប្រាំង...

**៣- ត្រពាំងថ្ម :** ស្ថិតនៅក្នុងស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យមានប្រភេទសត្វក្រៀល រស់នៅដែលជាប្រភេទសត្វជិតផុតពូជនៅលើពិភពលោក។ សត្វក្រៀលផ្លាស់ទីកន្លែងរស់នៅ១ឆ្នាំ២ដងពី ខេត្តរតនគិរីមកខេត្តបន្ទាយមានជ័យ ៕



# ភូមិបណ្តែតទឹក កំពង់ភ្លុក

កំពង់ភ្លុករួមឡើងដោយភូមិចំនួនបី ចូលគ្នាស្ថិតក្នុងបឹងទន្លេសាប ដែលមានចំងាយប៉ុន្មានប្រហែល១៦ គម ពីខេត្តសៀមរាបនៃប្រទេសកម្ពុជាដែលហ៊ុមព័ទ្ធដោយដើមកោងកាងលិចទឹកដើមកោងកាងទាំងនោះជាជម្រកសត្វព្រៃច្រើនប្រភេទ។

ភូមិនេះមានអ្នកស្រុករស់នៅចំនួន៣000នាក់។ ក្នុងបឹងទន្លេសាបសំបូរដោយបក្សីទឹកច្រើនជាង១00 ប្រភេទ និងមានត្រីចំនួនច្រើនជាង២00ប្រភេទ រួមទាំងក្រពើ អណ្តើក ស្វា ភេ ទៀតផង។ នៅខែវស្សាផ្ទៃទឹកបឹងទន្លេសាបមានទំហំដល់ទៅ១២000 គីឡូម៉ែត្រក្រឡា តែនៅខែប្រាំងវិញមានទំហំត្រឹមតែ២៥00 គីឡូម៉ែត្រក្រឡាតែប៉ុណ្ណោះ។

នៅរដូវប្រាំងផ្ទះរបស់ពួកគេនៅលើគោក ដូច្នេះហើយពួកគេត្រូវតែធ្វើផ្ទះបណ្តោះអាសន្នតាមទឹកដែលស្រកទៅនោះ តែនៅខែវស្សានៅពេលទឹកឡើងពួកគេប្តូរទីលំនៅមករស់នៅផ្ទះពួកគេវិញ ព្រោះទឹកបឹងបានឡើង មកដល់ និងលិចដល់ភូមិរបស់ពួកគេ ៕



# 2016 Print Schedules and Ad Rates

KhmerPost USA is the only Cambodian newspaper that has the highest circulation and is most read in the Cambodian communities in the Greater Merrimack Valley, Boston and beyond. It provides important news and information to a market that is often isolated from the larger community due to a language barrier. This includes the national and international news, and the practical local information concerning health, education, politics, businesses and community involvement.

## Publication Frequency

24 times a year. Prints on every other Friday

## General Information

Circulations: 12,000 free copies per month.

Distributions:

- 70+ locations in Lowell, MA (5,000 copies per issue)
- 25 locations in Lynn and Revere, MA (500 copies per issue)
- 25 locations in Cranston and Providence, RI (1,000 copies per issue)

## 2016 Publication Dates

- January 8th & 22nd, 2016
- February 5th & 19th, 2016
- March 4th & 18th, 2016
- April 8th & 22nd, 2016
- May 6th & 20th, 2016
- June 3rd & 17th, 2016
- July 8th & 22nd, 2016
- August 5th & 19th, 2016
- September 9th & 23rd, 2016
- October 7th & 21st, 2016
- November 4th & 18th, 2016
- December 2nd & 16th, 2016

* all ad materials are due one due one week prior to the publishing date.


KHMERPOST USA Issue 189 Nov.26th. to Dec.07th. 2015 Page.1

KhmerPost USA

E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

Free

Issue 189 Nov.26th. to Dec.07th. 2015

Office: Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852

Miss Massachusetts USA & Miss Massachusetts Teen USA

Deb Belanger, Executive Director

Congratulations to Whitney Sharpe, Miss Massachusetts USA winner and Alexis Franca, Miss Massachusetts Teen USA winner!

Lowell, MA -This past weekend, November 21st and 22nd the Lowell Memorial Auditorium was home to the Miss Massachusetts USA and Miss Massachusetts Teen USA competitions. With over 100 contestants competing for this year's crown the auditorium was filled with friends and families cheering these women on.

Both pageant had representatives from across the state who were judged in three areas: Continued to Page 08

Alexis Franca

Whitney Sharpe

## Advertising Rates

| Ad Size | 1 issue | 3 month<br>5% off | 6 month<br>7,5% off | 12 month<br>10% off |
|---|---|---|---|---|
| full | 460.00 | 874.00 | 851.00 | 828.00 |
| 1/2 | 310.00 | 589.00 | 573.50 | 558.00 |
| 1/4 | 165.00 | 313.50 | 305.25 | 297.00 |
| 1/8 | 90.00 | 171.00 | 166.50 | 162.00 |

## Ads Sizes & Dimensions

| | |
|---|---|
| 1 Full page inside | (13"x10") |
| 1/2 page color | (6.5"x10") |
| 1/4 page color | (6.5"x5") |
| 1/8 page color | (3.25"x5") |

**Office:** 45 Merrimack Street. Suite 218A. Lowell, MA 01852
**Tel:** 978.677.7163. **Cell:** 978. 656.8141. Fax: 978.677.7092
Email: sobenpin@khmerpost.us | www.khmerpost.us

# INTRODUCING LRTA BUS TRACKER

## A Great New Benefit for LRTA Riders!

## 2 Ways to Get Real-Time Bus Information




**VIEW INTERACTIVE GPS BUS ROUTE MAPS ON YOUR COMPUTER**

**Visit LRTA.com and Click on the LRTA Bus Tracker Link**

Track Buses on All 18 LRTA Bus Routes in Real-Time on Our Regional Map

Select a Bus Stop to Get Live Departure Times

LRTA BUS TRACKER

**GET REAL-TIME LRTA BUS STOP ARRIVAL & DEPARTURE TIMES ON YOUR SMART PHONE**

**Download the Free Smart Phone App**

RouteShout

Download on the App Store | GET IT ON Google play

Find Times by Your Location, Address or LRTA Bus Route

# សូមនាំមកជូននូវ LRTA បើសដែលតេតាមដានបាន

## ផលចំណេញដ៏ប្រសើរថ្មីទៀត សម្រាប់អ្នកជិះរថយន្តបើស

## វិធី២យ៉ាងសម្រាប់យកព័តិមានពីម៉ោងពិតប្រាកដរបស់ផ្លូវបើស

**មើលចលនាសកម្មរបស់បើស តាម“ជីភីអេស” មានផ្លូវនៅលើផែនទីក្នុងកុំព្យូទ័រ**

Visit LRTA.com and Click on the LRTA Bus Tracker link

តាមដានបើសនៅគ្រប់ផ្លូវបើស RLTAទាំង១៨ នឹងម៉ោង ពិតប្រាកដ នៅលើផែនទីភូមិភាគជ្រើសរើសចំណតបើស ដើម្បីឱ្យបានម៉ោងបើស មកដល់ណាហើយ!

ទទួលបានម៉ោងបើស LRTA មកដល់ពិតប្រាកដ ម៉ោងពេលមកដល់នឹងពេលចេញដំណើរ នៅលើទូរស័ព្ទដៃ"ស្មាតហ្វូន"

RouteShout

Download on the App Store | GET IT ON Google play

រកពេលតាមរយកន្លែងដែលអ្នកកំពុងនៅ, អស័យដ្ឋាន ឬ ផ្លូវ LRTA បើស

Lowell Regional Transit Authority

**FOR MORE DETAILS ABOUT LRTA BUS TRACKER VISIT LRTA.com**